# ទស្សនៈយល់ច្រលំអំពីរេដបូក

មានការទទួលព័ត៌មានខុសគ្នាជាច្រើនអំពីរេដបូក។ ខាងក្រោមនេះគឺជាចម្លើយ ដែលឆ្លើយតបទៅនឹងចម្ងល់ដែលកើតមានឡើងជាញឹកញាប់៖

**១. ប្រសិនបើប្រទេសកម្ពុជាអនុវត្តន៍រេដបូក ប្រជាពលរដ្ឋដែលរស់នៅក្នុង ឬ នៅជិតព្រៃឈើ នឹងមិនអាចធ្វើទាញផលបន្លែបង្កា ឬ ធនធានផ្សេងៗ ពីព្រៃឈើបានទៀតទេ។**

ព្រៃឈើ ដូចជាដីកសិកម្ម អាចត្រូវបានគ្រប់គ្រងតាមបែបចិរន្តផលយូរអង្វែង។ នេះត្រូវបានគេហៅថា "គ្រប់គ្រងនិរន្តរភាព" ។ រេដបូក គឺជាយន្តការមួយក្នុងការគាំទ្រឲ្យមានការគ្រប់គ្រងព្រៃឈើយូរអង្វែង។ ការប្រមូលផលបន្លែ ឬ ធនធានផ្សេងៗ សម្រាប់ការផ្គត់ផ្គង់គ្រួសារ ឬ ការប្រើប្រាស់ក្នុងមូលដ្ឋាន គឺមានភាពស្របគ្នាទៅនឹងការគ្រប់គ្រងយូរអង្វែង ហើយដែលនឹងត្រូវបានអនុញ្ញាតឲ្យប្រមូលផល នៅក្នុងការអនុវត្តកម្មវិធីរេដបូក។

**២. នៅក្នុងការអនុវត្តកម្មវិធីរេដបូកកម្ពុជា ដើមឈើមិនត្រូវបានអនុញ្ញាតឲ្យកាប់នោះទេ។**

ដូចដែលបានបកស្រាយខាងលើ គោលទៅរបស់កម្មវិធីរេដបូក គឺដើម្បីធ្វើការគាំទ្រការគ្រប់គ្រងព្រៃឈើឲ្យមាននិរន្តភាព។ ប្រសិនបើដើមឈើត្រូវបានកាប់ដោយប្រុងប្រយ័ត្ន ហើយទៅតាមអត្រាដែលកំណត់ និងមិនលើសពីចំនួននៃការរីកលូតលាស់នៃព្រៃឈើនោះ ព្រៃឈើនឹងមាននិរន្តរភាព ពីព្រោះដើមឈើតូចៗ នឹងរីកលូតទៅជំនួសចំនួនដើមឈើដែលបានចាប់។ ជារួម នៅក្នុងកម្មវិធីរេដបូក ដើមឈើអាចកាប់បាន ដោយគោរពទៅតាមគោលការណ៍ច្បាប់ដែលបានកំណត់ឲ្យអនុវត្តន៍តាម។

**៣. សហគមន៍មិនមានតួនាទីអ្វីនោះទេ នៅក្នុងការអនុវត្តរេដបូក។**

សហគមន៍ជាច្រើន គឺធ្វើការគ្រប់គ្រងព្រៃឈើ និងមានសហគមន៍ជាច្រើនដែលមានសគមន៍ព្រៃឈើ ប៉ុន្តែធ្វើការទាញប្រយជន៍ពីតំបន់ព្រៃ ដូចជា ធ្វើការរកម្ហូបអាហារ និងធនធានផ្សេងៗ។ ដោយសារតែកម្មវិធីរេដបូក គឺគ្រប់គ្រងនូវរាល់ព្រៃឈើនៅក្នុងប្រទេស អ្នកដែលធ្វើការជួយក្នុងការគ្រប់គ្រងព្រៃឈើ នឹងមានតួនាទីក្នុងការអនុវត្តន៍នេះ។

**៤. រាល់ផលប្រយោជន៍ពីការអនុវត្តរេដបូក នឹងបានទៅតែរដ្ឋាភិបាលតែប៉ុណ្ណោះ។**

ប្រទេសអភិវឌ្ឍន៍ជាច្រើន នឹងធ្វើការផ្តល់ថវិកាក្នុងការអនុវត្តរេដបូកនៅកម្ពុជា។ បច្ចុប្បន្ន ម្ចាស់ជំនួយគាំទ្រលើភាពត្រៀមជាស្រេចក្នុងការអនុវត្តរេដបូក គឺកំពុងតម្រូវ និងទាមទារឲ្យមានដំណើរការដែលច្បាស់លាស់ និងមានប្រសិទ្ធភាពរួចជាស្រេច ដើម្បីធានាថា រាល់ភាគីអ្នកពាក់ព័ន្ធទាំងឡាយ ដែលធ្វើការចូលរួមក្នុងការកាត់បន្ថយ

ឧស្ម័នផ្ទាំងកញ្ចក់ពីព្រៃឈើ នឹងទទួលបាននូវផលចំណែកសមរម្យ។ នេះ គឺអាចជាករណីបែងចែកផលនៅក្នុងការអនុវត្តរេដបូក។

**៥. វាមិនអាចទៅរួចនោះទេក្នុងការបញ្ឈប់ការកាប់ព្រៃឈើ ឬ ការយកដីខុសច្បាប់ ដោយអ្នកមានអំណាច។**

ទាំងការកាប់ឈើ និងយកដីខុសច្បាប់ គឺមានភាពលំបាកក្នុងការបញ្ឈប់ ពីព្រោះតែនេះជាការដែលអាចរកលុយបានជាច្រើន និង ដែលមានការចូលរួមដោយបុគ្គលដែលមានអំណាច។ ទោះបីជាយ៉ាងនេះក៏ដោយ ដំណើរការទាំងនេះ អាចត្រូវបានបញ្ឈប់ ដោយសារប្រទេសជាច្រើនដែលអនុវត្តន៍រេដបូក គឺបានបញ្ឈប់អំពីខុសច្បាប់នេះដោយជោគជ័យ។ ផ្នែកនៃដំណោះស្រាយ គឺរួមមាន ការពង្រឹងការកែទម្រង់ច្បាប់ព្រៃឈើ និងបង្កើតដំណើរការដែលមានតម្លាភាព ក្នុងការរាយការណ៍ និងផ្តន្ទាទោសបទឧក្រិដ្ឋទាំងនោះទៅតាមច្បាប់។

**៦. ប្រសិនបើសិទ្ធិមនុស្សមិនត្រូវបានគោរព ពួកគេនឹងមិនអាចធ្វើអ្វីបាននោះទេទៅលើបញ្ហាទាំងនេះ។**

ដូចដែលការយល់ច្រលំទៅលើផលប្រយោជន៍ ប្រទេសអភិវឌ្ឍន៍ជាច្រើនដែលនឹងផ្តល់ថវិកាសម្រាប់ការអនុវត្តរេដបូក គឺធ្វើការទាមទារថា ប្រទេសកម្ពុជានឹងធានាការចូលរួមដែលមានប្រសិទ្ធភាព និងការចូលរួមពេញលេញ ពីភាគីពាក់ព័ន្ធទាំងឡាយ។ យន្តការដោះស្រាយជម្លោះ នឹងត្រូវបានបង្កើតក្នុងការគាំទ្រឲ្យមានការចូលរួមពេញលេញ និងមានប្រសិទ្ធភាព ដែលនឹងអនុញ្ញាតឲ្យភាគីអ្នកពាក់ព័ន្ធទាំងឡាយ ក្នុងការប្រាប់នូវករណីទាំងឡាយណា នៅពេលដែលសិទ្ធិរបស់ពួកគេមិនត្រូវបានគោរព។

**៧. ការអនុវត្តរេដបូក នឹងមានផលប៉ះពាល់អវិជ្ជមានទៅលើជីវចម្រុះ (សត្វព្រៃ)។**

ប្រសិនបើព្រៃឈើត្រូវបានគ្រប់គ្រងកាន់តែមានប្រសិទ្ធភាពដោយការអនុវត្តរេដបូក គុណភាពព្រៃឈើនឹងមានភាពប្រសើរឡើង ដែលនឹងធ្វើឲ្យមានការបង្កើនជីវចម្រុះ។ ជារួម ព្រៃឈើដែលមានសុខភាពល្អ នឹងធ្វើឲ្យមានការបង្កើនផលប្រយោជន៍ដល់អ្នកដែលពឹងផ្អែកទៅលើព្រៃឈើ។

**៨. រេដបូក នឹងមិនអាចអនុវត្តន៍ទៅបាននោះទេនៅប្រទេសកម្ពុជា ពីព្រោះរដ្ឋាភិបាលនឹងមិនយល់ព្រមក្នុងការ "លក់" ឥណទាន។**

បើទោះបីជារេដបូក គឺមិនដូចគ្នានឹងទីផ្សារកាបោនស្ម័គ្រចិត្តក៏ដោយ វាអាចទៅរួចដែលថារដ្ឋាភោបាល ប្រហែលជាមិនយល់ព្រមទទួលការបង់ថវិកាពីប្រទេសអភិវឌ្ឍន៍។ ទោះជាយ៉ាងណា បើតាមការតាំងចិត្តរបស់រដ្ឋាភិបាលក្នុងការត្រៀមខ្លួនអនុវត្តន៍រេដបូក គ្រោះថ្នាក់ដែលអាចកើតមានឡើងគឺតិចបំផុត។

**Positive Incentives under REDD+**

Video Script produced by REDD+ Taskforce Secretariat for

Awareness Raising on REDD+ in Cambodia

**ការលើកទឹកចិត្ត នៅក្រោមការអនុវត្តរេដបូកកម្ពុជា**

ការសរសេរសាច់រឿងវីដេអូ គឺផលិតដោយក្រុមការងារលេខាធិការដ្ឋានកម្មវិធីរេដបូកកម្ពុជា សម្រាប់

ការលើកកម្ពស់ការយល់ដឹង អំពី កម្មវិធីរេដបូក នៅប្រទេសកម្ពុជា

| Scene<br>ឈុត | Audio/Script<br>សម្លេង | Video Graphic<br>រូបភាពវីដេអូ | Duration<br>រយៈពេល |
|---|---|---|---|
| 1 | Under REDD+, developing countries like Cambodia, which contribute to reducing deforestation and better management of forests will be entitled to receive incentives in the form of financial resources | Graphic of people and forests with title caption fading in | 15 secs |
| | ក្រោមគម្រោងរេដបូក ប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាប្រទេសកម្ពុជា ដែលរួមចំណែកដល់ការកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ និងការធ្វើឲ្យប្រសើរឡើងលើផ្នែកគ្រប់គ្រងព្រៃឈើ នឹងត្រូវបានទទួលការលើកទឹកចិត្តនៅក្នុងទម្រង់ជាការធនធានហិរញ្ញវត្ថុ | ក្រាហ្វិកនៃមនុស្ស និងព្រៃឈើ ជាមួយនឹងចំណងជើង ប្លង់រត់ចូល | ១៥ វិនាទី |
| 2 | Countries must report to the international community on progress they have made, thus generating the financial resources from developed countries | Graphic of  international meeting | 15 secs |
| | បណ្តាប្រទេសទាំងឡាយ ត្រូវតែរាយការណ៍ទៅសហគមន៍អន្តរជាតិលើដំណើរការរីកចម្រើនដែលពួកគេបានធ្វើ ដូច្នេះនឹងទទួលបានធនធានហិរញ្ញវត្ថុពីប្រទេសអភិវឌ្ឍន៍ | ក្រាហ្វិកនៃកិច្ចប្រជុំអន្តរជាតិ | ១៥ វិនាទី |
| 3 | A proportion of these finances will be needed to cover the costs of measuring progress, reporting, and administering the REDD+ programme | Graphic of forest inventory activities (people measuring trees) | 15 sec |

| | | | |
|---|---|---|---|
| | សមាមាត្រនៃហិរញ្ញវត្ថុទាំងនេះ នឹងត្រូវការដើម្បីប្រើប្រាស់លើការចំណាយនៃដំណើរការវាស់ស្ទង់ រាយការណ៍ និងគ្រប់គ្រងកម្មវិធីរេដបូកនេះ | ក្រាហ្វិកនៃសកម្មភាពសារពើភ័ណ្ឌព្រៃឈើ (មនុស្សកំពុងវាស់ដើមឈើ) | ១៥ វិនាទី |
| 4 | However, the finance will also be used to provide benefits to stakeholders. Benefits may take various forms, not necessarily cash | Graphic of a community forests with villagers working in the forest | 15 secs |
| | ទោះជាយ៉ាងណា ហិរញ្ញវត្ថុក៏នឹងត្រូវបានប្រើដើម្បីផ្តល់ប្រយោជន៍ដល់អ្នកពាក់ព័ន្ធនានា។ អត្ថប្រយោជន៍ទាំងនោះ អាចតាមទម្រង់ជាច្រើន មិនចាំបាច់តែជាក្នុងទម្រង់ផ្តល់ជាសាច់ប្រាក់ | ក្រាហ្វិកនៃសហគមន៍ព្រៃឈើមួយដែលមានអ្នកភូមិកំពុងធ្វើការនៅក្នុងព្រៃ | ១៥ វិនាទី |
| 5 | Deciding how to share the benefits is complicated … it is far too expensive to measure carbon at a scale useful for deciding who has contributed how much … | Graphic of people in forests, looking puzzled | 20 secs |
| | ការសម្រេចពីរបៀបក្នុងការចែករំលែកផលប្រយោជន៍ គឺមានភាពស្មុគស្មាញ ... វាមានតម្លៃថ្លៃពេកក្នុងការវាស់កាបូននៅខ្នាតមួយសំខាន់ក្នុងការសម្រេចចិត្តថាតើ អ្នកបានចូលរួមចំណែកច្រើនប៉ុណ្ណា ... | ក្រាហ្វិកនៃប្រជាជននៅក្នុងព្រៃដែលមើលមានភាពងឿយឆ្ងល់ | ២០ វិនាទី |
| 6 | … so some other measure will need to be used – such as the amount of effort different stakeholders have made. | Split-screen: graphics of villagers patrolling or planting trees | 15 secs |
| | ... ដូច្នេះ វិធានការមួយចំនួនផ្សេងទៀត នឹងត្រូវបានប្រើ - ដូចជា ចំណែកនៃការខិតខំប្រឹងប្រែងពីភាគីពាក់ព័ន្ធផ្សេងគ្នាដែលបានចូលរួម។ | ចែកអេក្រង់៖ ក្រាហ្វិកអ្នកភូមិដើរល្បាត ឬ ដាំដើមឈើ | ១៥ វិនាទី |
| 7 | In order to ensure that the process is transparent and equitable, there needs to be broad agreement on how it will work … | Graphic of Taskforce or CG meeting | 15 secs |
| | ដើម្បីធានាថា ដំណើរការនេះមានតម្លាភាព និងប្រកបដោយសមធម៌ វាត្រូវការកិច្ចព្រមព្រៀងទូលំ | ក្រាហ្វិកនៃកិច្ចប្រជុំក្រុមការងាររេដបូក ឬ ក្រុមប្រឹក្សាយោបល់ | ១៥ វិនាទី |

| | | | |
|---|---|---|---|
| | ទូលាយនៅលើដំណើរការអនុវត្តន៍នេះ ... | | |
| 8 | … and all the information needs to be freely available … | Graphic of someone looking at REDD+ Cambodia web-site | 15 secs |
| | ... ហើយព័ត៌មានទាំងអស់នេះ គឺអាចរកបានដោយសេរី ... | ក្រាហ្វិកនៃមនុស្សម្នាក់សម្លឹងមើលគេហទំព័ររបស់កម្មវិធីរេដបូកកម្ពុជា | ១៥ វិនាទី |
| 9 | … therefore your representatives on the Consultation Group will be working hard to help design a benefit sharing system appropriate for Cambodia | Graphic of CG meeting | 20 secs |
| | ... ដូច្នេះ តំណាងរបស់អ្នកដែលជាសមាជិកក្នុងក្រុមពិគ្រោះយោបល់ នឹងត្រូវធ្វើការជាច្រើន ក្នុងការជួយបង្កើតប្រព័ន្ធចែករំលែកផលប្រយោជន៍ដ៏សមរម្យសម្រាប់ប្រទេសកម្ពុជា | ក្រាហ្វិកនៃកិច្ចប្រជុំក្រុមប្រឹក្សាយោបល់ | ២០ វិនាទី |
| 10 | It is important to understand that benefits may not be provided in the form of money … | Graphic of villagers sharing money | 15 secs |
| | វាជាការសំខាន់ក្នុងការយល់ថា ផលប្រយោជន៍អាចនឹងមិនត្រូវបានផ្តល់ជូននៅក្នុងទម្រង់ជាទឹកប្រាក់ ... | ក្រាហ្វិកនៃការចែកប្រាក់ដល់អ្នកភូមិប្រាក់ ជាមួយនឹងសញ្ញា x | ១៥ វិនាទី |
| 11 | … benefits may take the form of improved social infrastructure … | Split-screen: graphics of new village bridge or school | 10 secs |
| | ... អត្ថប្រយោជន៍អាចទទួលបានជាទម្រង់ ដើម្បីធ្វើឱ្យប្រសើរឡើងលើផ្នែកហេដ្ឋារចនាសម្ព័ន្ធសង្គម ... | បំបែកអេក្រង់៖ ក្រាហ្វិកនៃស្ពាន ឬសាលាថ្មីក្នុងភូមិ | ១០ វិនាទី |
| 12 | … training in new or improved livelihoods … or other types of benefits | Graphic of villagers being trained | 10 secs |
| | ... ការបណ្តុះបណ្តា ការចិញ្ចឹមជីវិតថ្មី ឬ មានភាពប្រសើរឡើង ... ឬ ប្រភេទអត្ថប្រយោជន៍ដទៃទៀត | ក្រាហ្វិកនៃអ្នកភូមិដែលកំពុងទទួលការបណ្តុះបណ្តាល | ១០ វិនាទី |
| | How local stakeholders wish to receive | Still shot from village meeting | 15secs |

| | | | |
|---|---|---|---|
| 13 | benefits will be closely linked to the process of "Free, Prior and Informed Consent | scene with "Free, Prior and Informed Consent" | |
| | របៀបដែលអ្នកពាក់ព័ន្ធក្នុងមូលដ្ឋានមានបំណងចង់ទទួលបាននូវអត្ថប្រយោជន៍ នឹងត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងដំណើរការ នៃ ""ដោយសេរី ការផ្តល់ព័ត៌មានជាមុន និងដោយមានការព្រមព្រៀង" ឬ FPIC | ប្លង់ពីកន្លែងប្រជុំភូមិ ជាមួយនឹងប្លង់ "ដោយសេរី ការផ្តល់ព័ត៌មានជាមុន និងដោយមានការព្រមព្រៀង" | ១៥ វិនាទី |
| 14 | If you would like to learn more, or want to contribute, please contact the REDD+ Taskforce Secretariat | Forest still shot with REDD+ Cambodia logo and RTS contact information | 20 secs |
| | ប្រសិនបើអ្នកចង់រៀនបន្ថែមទៀត ឬ ចង់រួមចំណែកក្នុងដំណើរការនេះ សូមទាក់ទងទៅ ក្រុមការងារលេខាធិការដ្ឋានរេដបូកកម្ពុជា | រូបភាពពីព្រៃឈើ ជាមួយនឹង Logos របស់រេដបូកកម្ពុជា និង ព័ត៌មានទំនាក់ទំនងរបស់លេខាធិការដ្ឋានរេដបូកកម្ពុជា | ១៥ វិនាទី |
| Total<br>សរុប | | | 3 mins 35 secs (៣នាទី និង ៣៥ វិនាទី) |

Co-benefits under REDD+

Video Script produced by REDD+ Taskforce Secretariat for

Awareness Raising on REDD+ in Cambodia

**សហអត្ថប្រយោជន៍នៅក្រោមការអនុវត្តរេដបូកកម្ពុជា**

ការសរសេរសាច់រឿងវីដេអូ គឺផលិតដោយក្រុមការងារលេខាធិការដ្ឋានកម្មវិធីរេដបូកកម្ពុជា សម្រាប់ការលើកកម្ពស់ការយល់ដឹង អំពី កម្មវិធីរេដបូក នៅប្រទេសកម្ពុជា

| Scene<br>ឈុត | Audio<br>សម្លេង | Video Graphic<br>រូបភាពវីដេអូ | Duration<br>រយៈពេល |
|---|---|---|---|
| 1 | You may have heard that REDD+ is all about carbon and climate change, and indeed this is what the international community is very concerned about | Graphic of people and forests with title caption fading in | 15 secs |
| | អ្នកប្រហែលជាបានឮថា រេដបូក គឺសុទ្ធតែអំពីកាបោន និងការផ្លាស់ប្តូរអាកាសធាតុ ហើយពិតណាស់នេះគឺជាអ្វីដែលសហគមន៍អន្តរជាតិ មានការព្រួយបារម្ភយ៉ាងខ្លាំងលើបញ្ហាទាំងនេះ | ក្រាហ្វិកនៃមនុស្ស និងព្រៃឈើ ជាមួយនឹងចំណងជើងចំណងជើងប្លង់រត់ចូល | ១៥ វិនាទី |
| 2 | However, forest are valuable for many other reasons, besides carbon | Graphic of a forest with people | 15 secs |
| | ទោះជាយ៉ាងណា ព្រៃឈើគឺមានតម្លៃជាខ្លាំងសម្រាប់ផ្នែកផ្សេងជាច្រើនទៀត ក្រៅពីកាបោន | ក្រាហ្វិកនៃព្រៃឈើ ជាមួយនឹងមនុស្ស | ១៥ វិនាទី |
| 3 | Forests provide habitat for wildlife, which may be useful for local communities … | Graphic wild pigs or other species that are eaten | 15 sec |
| | ព្រៃឈើផ្តល់នូវជម្រកសម្រាប់សត្វព្រៃ ដែលអាចមានប្រយោជន៍សម្រាប់សហគមន៍មូលដ្ឋាន ... | ក្រាហ្វិកនៃសត្វជ្រូកព្រៃ ឬ ប្រភេទសត្វផ្សេងទៀត ដែលត្រូវបានគេចាប់មកបរិភោគ ឬ ធ្វើជាអាហារ | ១៥ វិនាទី |
| 4 | Forests make water supply more regular and reliable … | Graphic of a stream running from a forest into farmland | 15 secs |
| | ព្រៃឈើធ្វើឱ្យការផ្គត់ផ្គង់ទឹក មានជាទៀងទាត់ និងអាចជឿទុកចិត្តបាន ... | ក្រាហ្វិកនៃទន្លេដងអូរ ដែលកំពុងធ្លាក់ចុះ ឬ ចរន្តពីព្រៃមួយចូលទៅក្នុងដីស្រែ | ១៥ វិនាទី |

| | | | |
|---|---|---|---|
| 5 | Forests provide a means for local people to earn a living … | Graphic of people harvesting NTFPs | 10 secs |
| | ព្រៃឈើផ្តល់នូវមធ្យោបាយសម្រាប់ប្រជាជនមូលដ្ឋាន ដើម្បីរកប្រាក់ចំណូលចិញ្ចឹមជីវិតគ្រួសារ ... | ក្រាហ្វិកនៃប្រជាជនប្រមូលផលអនុផលព្រៃឈើ | ១០ វិនាទី |
| 6 | Forests may provide spiritual support … and there are many other benefits that are provided by forests | Graphic of Buddhist monks in the forest | 15 secs |
| | ព្រៃឈើអាចផ្តល់ការគាំទ្រខាងផ្នែកស្មារតី ឬជំនឿ ... ហើយក៏មានអត្ថប្រយោជន៍ជាច្រើនផ្សេងទៀតដែលត្រូវបានផ្តល់ដោយព្រៃឈើ | ក្រាហ្វិកនៃព្រះសង្ឃនៅក្នុងព្រៃ | ១៥ វិនាទី |
| 7 | Once forests have gone, it is very difficult to restore them, and all of these benefits will be no longer be available | Graphic of deforestation (similar to "Introduction to REDD+" video) | 15 secs |
| | នៅពេលដែលព្រៃឈើបាត់បង់ វាមានភាពលំបាកខ្លាំងណាស់ក្នុងការស្តាឡើងវិញ ហើយអត្ថប្រយោជន៍ដែលធ្លាប់មានទាំងអស់នេះ នឹងលែងមានតទៅទៀត | ក្រាហ្វិកនៃការកាប់បំផ្លាញព្រៃឈើ (ស្រដៀងគ្នាទៅនឹងវីដេអូ "ការណែនាំអំពីរេដបូក") | ១៥ វិនាទី |
| 8 | … and although local people are most directly affected, even those living in town and cities suffer due to higher food prices, flooding and other problems | Graphic of floods affecting a city | 15 secs |
| | ... ហើយបើទោះបីជាប្រជាជនក្នុងតំបន់រងផលប៉ះពាល់ដោយផ្ទាល់ សូម្បីតែអ្នកដែលរស់នៅទីប្រជុំជន និងទីក្រុង គឺទទួលរងដោយសារតម្លៃម្ហូបអាហារឡើងថ្លៃខ្ពស់ជាងមុន គ្រោះទឹកជំនន់ និងបញ្ហាផ្សេងទៀត | ក្រាហ្វិកនៃទឹកជំនន់ប៉ះពាល់ដល់ទីក្រុងមួយ | ១៥ វិនាទី |
| 9 | So, while Cambodia stands to benefit from international efforts on climate change, conserving and sustainably managing forests will yield many | Graphic of forest with multiple benefits (wildlife, water, cultural, etc.) | 20 secs |

| | | | |
|---|---|---|---|
| | forms of benefits | | |
| | ដូច្នេះ ខណៈពេលដែលប្រទេសកម្ពុជា ទទួលបានផលប្រយោជន៍ពីការខិតខំប្រឹងប្រែងរបស់អន្តរជាតិស្តីពីការផ្លាស់ប្តូរអាកាសធាតុ ការអភិរក្ស និងការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព នឹងផ្តល់នូវ អត្ថប្រយោជន៍ក្នុងទម្រង់ជាច្រើន | ក្រាហ្វិកនៃព្រៃឈើជាមួយនឹងអត្ថប្រយោជន៍ជាច្រើន (សត្វព្រៃ ទឹក វប្បធម៌ ជាដើម) | ២០ វិនាទី |
| 10 | The Cambodia National REDD+ Programme will therefore prioritize efforts in areas where these multiple benefits are largest | Graphic of planning – identifying forest areas providing the most benefits | 15 secs |
| | ដូច្នេះ កម្មវិធីជាតិរេដបូកកម្ពុជា នឹងផ្តល់អាទិភាពដល់កិច្ចខិតខំប្រឹងប្រែងនៅតំបន់ ដែលកន្លែងមានប្រយោជន៍ជាច្រើនជាងគេបំផុត | ក្រាហ្វិកនៃការធ្វើផែនការ - ការកំណត់តំបន់ព្រៃឈើ ដែលផ្តល់អត្ថប្រយោជន៍ច្រើនបំផុត | ១៥ វិនាទី |
| 11 | Healthy forests provide many benefits to the people living in them or nearby … and those living far away from the forest | Graphic of villagers working in the forest | 15 secs |
| | ព្រៃឈើដែលមានសុខភាពល្អ ផ្តល់នូវអត្ថប្រយោជន៍ជាច្រើន ដល់ប្រជាជនដែលរស់នៅក្នុងឬ នៅជិតព្រៃទាំងនោះ ... និងអ្នកដែលរស់នៅឆ្ងាយពីព្រៃឈើ | ក្រាហ្វិកនៃអ្នកភូមិកំពុងធ្វើការនៅក្នុងព្រៃ | ១៥ វិនាទី |
| 12 | Therefore, it is only fair that society as a whole contribute to the costs of conserving and sustainably managing forests because everyone benefits | Graphic of natural forest, rural village and city | 20 secs |
| | ដូច្នេះ យុត្តិធម៌តែមួយគត់ គឺសង្គមទាំងមូលរួមចំណែកដល់ការចំណាយនៃការអភិរក្ស និងគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ដោយសារតែមនុស្សគ្រប់គ្នាមានផលប្រយោជន៍ពីនេះ | ក្រាហ្វិកនៃព្រៃឈើធម្មជាតិ ភូមិជនបទនិងទីក្រុង | ២០ វិនាទី |
| 13 | If you would like to learn more, or want to contribute, please contact the REDD+ Taskforce Secretariat | REDD+ Cambodia logo and RTS contact information | 20 secs |

| | | | |
|---|---|---|---|
| | ប្រសិនបើអ្នកចង់រៀនបន្ថែមទៀត ឬ ចង់រួមចំណែកក្នុងដំណើរការនេះ សូមទាក់ទងទៅក្រុមការងារលេខាធិការដ្ឋានរេដបូកកម្ពុជា | រូបភាពពីព្រៃឈើ ជាមួយនឹង Logos របស់រេដបូកកម្ពុជា និងព័ត៌មានទំនាក់ទំនងរបស់លេខាធិការដ្ឋានរេដបូកកម្ពុជា | ២០ វិនាទី |
| Total<br>សរុប | | | 3 mins 25 secs<br>(៣ នាទី និង ២៥ វិនាទី) |

REDD+ MRV and Monitoring

Video Script produced by REDD+ Taskforce Secretariat for

Awareness Raising on REDD+ in Cambodia

**ការវាស់ស្ទង់ រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV) និងត្រួតពិនិត្យ ក្នុងការអនុវត្តរេដបូក**

ការសរសេរសាច់រឿងវីដេអូ គឺផលិតដោយក្រុមការងារលេខាធិការដ្ឋានកម្មវិធីរេដបូកកម្ពុជា សម្រាប់

ការលើកកម្ពស់ការយល់ដឹង អំពី កម្មវិធីរេដបូក នៅប្រទេសកម្ពុជា

| Scene<br>ឈុត | Audio<br>សម្លេង | Video Graphic<br>រូបភាពវីដេអូ | Duration<br>រយៈពេល |
|---|---|---|---|
| 1 | REDD+ is all about reducing emissions of $CO_2$ from forests. But how do we know how much $CO_2$ is being emitted from forests? | Graphic of people and forests with title caption fading in | 15 secs |
| | រេដបូក គឺអំពីការកាត់បន្ថយការបំភាយឧស្ម័នកាបូនិច ចេញពីព្រៃឈើ។ ប៉ុន្តែ តើយើងអាចដឹងថាតើ ឧស្ម័នកាបូនិចប៉ុន្មានដែលបានសាយភាយចេញពីព្រៃឈើនោះ ដោយរបៀប? | ក្រាហ្វិកនៃ មនុស្ស និងព្រៃឈើ ជាមួយនឹងចំណងជើងចំណងជើង រត់ចូលប្លង់ | ១៥ វិនាទី |
| 2 | Measuring emissions of $CO_2$ is technically quite difficult. It requires two types of information … | Graphic of a forest with people | 10 secs |
| | ការវាស់ស្ទង់ការបំភាយឧស្ម័នកាបូនិច គឺមានបច្ចេកទេសលំបាក។ វាតម្រូវឱ្យមានព័ត៌មានពីរប្រភេទ ... | ក្រាហ្វិកនៃ ព្រៃឈើជាមួយនឹង មនុស្ស | ១០ វិនាទី |
| 3 | The first is how land use changes over time, for example forest becoming non-forest. This information comes from analysis of remote sensing data, especially satellite images | Example of satellite image and graphic of technician analyzing remote sensing data | 20 sec |
| | ដំបូង គឺពីរបៀបដែលការប្រើប្រាស់ដីធ្លីមានការផ្លាស់ប្តូរទៅរយៈពេល ឧទាហរណ៍ ព្រៃឈើក្លាយជាមិនមែនជាព្រៃឈើ។ ព័ត៌មាននេះ បានមកពីការវិភាគទិន្នន័យពីលំហអាកាស ជាពិសេសរូបភាពតាមផ្កាយរណប | ឧទាហរណ៍នៃរូបភាពផ្កាយរណប និងក្រាហ្វិកនៃអ្នកបច្ចេកទេសកំពុងវិភាគទិន្នន័យពីលំហអាកាស | ២០ វិនាទី |
| 4 | The second type of information is how much carbon is gained or lost for each type of land use change. This information comes from | Graphic of NFI team in action in the forest (measuring trees) | 20 secs |

| | | | |
|---|---|---|---|
| | ground surveys | | |
| | ប្រភេទព័ត៌មានទីពីរ គឺថាតើកាបោនត្រូវបានកើនឡើង ឬបាត់បង់ប៉ុន្មាន ទៅលើប្រភេទនៃការផ្លាស់ប្តូរលើការប្រើប្រាស់ដីធ្លី។ ព័ត៌មាននេះ គឺបានមកពីការស្ទង់មតិមូលដ្ឋាន | ក្រាហ្វិកនៃក្រុម NFI ជាមួយសកម្មភាពនៅក្នុងព្រៃ (កំពុងវាស់ដើមឈើ) | ២០ វិនាទី |
| 5 | By combining these two types of information, it is possible to calculate how much $CO_2$ is emitted | Graphic of expert workshop | 15 secs |
| | ដោយមានការរួមបញ្ចូលគ្នារវាងព័ត៌មានទាំងពីរប្រភេទនេះ គេអាចធ្វើការគណនាបាន ថាតើឧស្ម័នកាបូនិចបានសាយភាយប៉ុន្មាន | ក្រាហ្វិកនៃសិក្ខាសាលាអ្នកជំនាញ | ១៥ វិនាទី |
| 6 | Every 4 years, the government must submit a report on $CO_2$ emissions from forests to an international body which checks the methodology and accuracy of the data | Graphic of international meeting, with a report superimposed | 20 secs |
| | រៀងរាល់បួនឆ្នាំ រដ្ឋាភិបាលត្រូវដាក់របាយការណ៍ ស្តីពី ការបំភាយឧស្ម័នឧស្ម័នកាបូនិច ដែលចេញពីព្រៃឈើ ទៅភាគីអន្តរជាតិ ដែលពិនិត្យលើវិធីសាស្រ្ត និងភាពត្រឹមត្រូវនៃទិន្នន័យទាំងនេះ | ក្រាហ្វិកនៃកិច្ចប្រជុំអន្តរជាតិ ជាមួយនឹងការដាក់របាយការណ៍មួយ | ២០ វិនាទី |
| 7 | Once the report is approved, the amount of emissions reductions achieved is confirmed | Graphic of calculations being made | 15 secs |
| | ពេលដែលរបាយការណ៍នេះត្រូវបានអនុម័ត ចំនួននៃការកាត់បន្ថយការបំភាយឧស្ម័នដែលសម្រេចបាននេះ នឹងត្រូវបានបញ្ជាក់ | ក្រាហ្វិកនៃការគណនាដែលត្រូវបានធ្វើឡើង | ១៥ វិនាទី |
| 8 | This process is called MRV … Measuring, Reporting, and Verification | Graphic of forest, with M (Measurement), R (Reporting) and V (Verification) superimposed | 15 secs |
| | ដំណើរការនេះ ត្រូវបានគេហៅថា MRV ... ការវាស់ស្ទង់ ការរាយការណ៍ និងការផ្ទៀងផ្ទាត់ | ក្រាហ្វិកនៃព្រៃឈើដោយមាន M (ការវាស់ស្ទង់) R (ការរាយការណ៍) និង V (ការផ្ទៀងផ្ទាត់) ដាក់ស្មើ | ១៥ វិនាទី |
| | However, while MRV is very important for | Graphic of people planting | 15 secs |

| | | | |
|---|---|---|---|
| 9 | REDD+, it is not sufficient, because it is also important to know who contributed to the reduction in emissions | trees | |
| | ទោះជាយ៉ាងណា ខណៈពេលដែល MRV គឺមានសារៈសំខាន់សម្រាប់រេដបូក វាមិនគ្រប់គ្រាន់នោះទេ ព្រោះវាក៏មានសារសំខាន់ផងដែរ ដើម្បីដឹងថាអ្នកដែលបានរួមចំណែកដល់ការកាត់បន្ថយការបំភាយឧស្ម័ន | ក្រាហ្វិកនៃប្រជាជនដាំដើមឈើ | ១៥ វិនាទី |
| 10 | This is because the incentives that Cambodia will receive by reducing emissions need to be shared fairly with those who achieved the reductions | Graphic of a village meeting | 10 secs |
| | នេះគឺដោយសារតែ ការលើកទឹកចិត្តដែលប្រទេសកម្ពុជានឹងទទួលបានពីការកាត់បន្ថយការបំភាយឧស្ម័ន ត្រូវបានចែករំលែកដោយស្មើភាពគ្នា ជាមួយនឹងអ្នកដែលសម្រេចបានក្នុងការកាត់បន្ថយទាំងនេះ | ក្រាហ្វិកនៃការប្រជុំភូមិ | ១០ វិនាទី |
| 11 | Therefore it is also necessary to monitor what is going on in the forests | Graphic of people collecting information from the forest | 10 secs |
| | ដូច្នេះ វាគឺជាការចាំបាច់ក្នុងការត្រួតពិនិត្យមើលពីអ្វីដែលកើតឡើងនៅក្នុងព្រៃទាំងនោះ | ក្រាហ្វិកនៃប្រជាជនកំពុងប្រមូលព័ត៌មានពីព្រៃឈើ | ១០ វិនាទី |
| 12 | Monitoring can cover many topics besides carbon – things like forest health; biodiversity; socio-economic activities, safeguards, and so on … | Split screen – graphics of wildlife, dying trees, villagers collecting NTFPs … | 15 secs |
| | ការត្រួតពិនិត្យ អាចគ្របដណ្តប់ប្រធានបទជាច្រើន ក្រៅពីកាបោន - ដូចជា សុខភាពព្រៃ ជីវចម្រុះ សកម្មភាពសង្គមសេដ្ឋកិច្ច និងការការពារសុវត្ថិភាព ជាដើម ... | អេក្រង់បំបែក - ក្រាហ្វិកនៃសត្វព្រៃ, ដើមឈើងាប់ អ្នកភូមិប្រមូលអនុផលព្រៃឈើ ... | ១៥ វិនាទី |
| 13 | … and can rely on many sources of information, including information collected and provided by communities | Graphic of villagers measuring trees | 15 secs |
| | ... និងអាចពឹងផ្អែកលើប្រភពព័ត៌មានជាច្រើន រួមទាំងព័ត៌មានដែលបានប្រមូល និងផ្តល់ដោយសហគមន៍ | ក្រាហ្វិកនៃអ្នកភូមិកំពុងវាស់ដើមឈើ | ១៥ វិនាទី |
| 14 | Cambodia is currently developing both its MRV | Scene of remote sensing | 15 secs |

| | | | |
|---|---|---|---|
| | system and a national forest monitoring system. Together they will provide information both on carbon and on other attributes of the nation′s forests | laboratory | |
| | បច្ចុប្បន្ននេះ ប្រទេសកម្ពុជា កំពុងធ្វើការបង្កើតប្រព័ន្ធ MRV និងប្រព័ន្ធត្រួតពិនិត្យតាមដានព្រៃឈើជាតិ។ ជាមួយគ្នានេះ ពួកគេនឹងផ្តល់នូវព័ត៌មានទាំងទៅលើផ្នែកកាបោន និងទៅលើគុណលក្ខណៈដទៃទៀតនៃព្រៃឈើជាតិ | ប្លង់នៃទីតាំងលើការវិភាគទិន្នន័យព្រៃឈើពីលំហអាកាស | ១៥ វិនាទី |
| 15 | All stakeholders will be involved in the development of these systems and will have access to the information that is collected | Graphic of Cambodian forests and people | 15 secs |
| | អ្នកពាក់ព័ន្ធទាំងអស់ នឹងត្រូវបានចូលរួមនៅក្នុងការបង្កើតប្រព័ន្ធទាំងនេះ ហើយនឹងអាចទទួលព័ត៌មានដែលបានប្រមូល | ក្រាហ្វិកនៃព្រៃកម្ពុជា និងប្រជាជន | ១៥ វិនាទី |
| 16 | If you would like to learn more, or want to contribute, please contact the REDD+ Taskforce Secretariat | Forest still shot with REDD+ Cambodia logo and RTS contact information | 20 secs |
| | ប្រសិនបើអ្នកចង់រៀនបន្ថែមទៀត ឬ ចង់រួមចំណែកក្នុងដំណើរការនេះ សូមទាក់ទងទៅ ក្រុមការងារលេខាធិការដ្ឋានរេដបូកកម្ពុជា | រូបភាពពីព្រៃឈើ ជាមួយនឹង Logos របស់រេដបូកកម្ពុជា និងព័ត៌មានទំនាក់ទំនងរបស់លេខាធិការដ្ឋានរេដបូកកម្ពុជា | ២០ វិនាទី |
| Total<br>សរុប | | | 4 mins 05 secs<br>(៤នាទី និង ០៥ វិនាទី) |

REDD+ Safeguards and FPIC

Video Script produced by REDD+ Taskforce Secretariat for

Awareness Raising on REDD+ in Cambodia

**ការការពារសុវត្ថិភាព និង FPIC ក្នុងកម្មវិធីរេដបូក**

ការសរសេរសាច់រឿងវីដេអូ គឺផលិតដោយក្រុមការងារលេខាធិការដ្ឋានកម្មវិធីរេដបូកកម្ពុជា សម្រាប់

ការលើកកម្ពស់ការយល់ដឹង អំពី កម្មវិធីរេដបូក នៅប្រទេសកម្ពុជា

| Scene<br>ឈុត | Audio<br>សម្លេង(សាច់រឿង) | Video Graphic<br>រូបភាពវីដេអូ | Duration<br>រយៈពេល |
|---|---|---|---|
| 1 | For REDD+ to be implemented effectively and equitably, there need to be safeguards to ensure stakeholder rights are respected | Graphic of people and forests with title caption fading in | 15 secs |
| | ដើម្បីឲ្យរេដបូក ត្រូវបានអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព និងសមធម៌ គឺចាំបាច់ត្រូវការពារសុវត្ថិភាព ដើម្បីធានាថាសិទ្ធិអ្នកពាក់ព័ន្ធ ត្រូវបានគោរព | ក្រាហ្វិកនៃមនុស្ស និងព្រៃឈើ ជាមួយនឹងចំណងជើងចំណងជើង រត់ចូល | ១៥ វិនាទី |
| 2 | The international community has agreed on safeguards that countries, including Cambodia, must respect | Graphic of international meeting, shaking hands | 15 secs |
| | សហគមន៍អន្តរជាតិ បានយល់ព្រមលើការការពារសុវត្ថិភាពថា ប្រទេសទាំងឡាយ រួមទាំងប្រទេសកម្ពុជា ត្រូវតែគោរព | ក្រាហ្វិកនៃកិច្ចប្រជុំអន្តរជាតិ និងសមាជិកចាប់ដៃគ្នា | ១៥ វិនាទី |
| 3 | These include … ensuring that REDD+ actions are consistent with national policies and international agreements … | Graphic of people consulting documents with "consistent with national policies and international agreements" fading in | 15 sec |
| | ទាំងនេះរួមបញ្ចូល ... ធានាថា សកម្មភាពរេដបូកគឺមានភាពស្របទៅនឹងគោលនយោបាយជាតិនិងកិច្ចព្រមព្រៀងអន្តរជាតិ ... | ក្រាហ្វិកនៃមនុស្សកំពុងពិគ្រោះយោបល់លើឯកសារ ដែល "ស្របទៅនឹងគោលនយោបាយជាតិ និងកិច្ចព្រមព្រៀងអន្តរជាតិ" ដោយមានរូបរត់ចូល | ១៥ វិនាទី |
| 4 | … ensuring that REDD+ actions are long-lasting and do not result in | Graphic showing conservation in one area yielding forest | 15 secs |

| | | | |
|---|---|---|---|
| | forest destruction elsewhere … | clearance in another area with an X through the clearance with "long-lasting and avoid causing forest destruction elsewhere" fading in | |
| | ... ធានាថា សកម្មភាពរេដបូក គឺមានយូរអង្វែងនិងមិនបណ្តាលឲ្យមានការកាប់បំផ្លាញព្រៃឈើនៅកន្លែងផ្សេងណាមួយ ... | ក្រាហ្វិក បង្ហាញ ការអភិរក្សនៅក្នុងតំបន់ណាមួយ ដែលធៀបនឹងរូបភាពកាប់រានព្រៃឈើនៅក្នុងតំបន់មួយផ្សេងទៀត ជាមួយសញ្ញា X តាមរយៈការកាប់រានជាមួយ "ភាពយូរអង្វែងនិងជៀសវាងការបង្កឱ្យមានការកាប់បំផ្លាញព្រៃឈើនៅកន្លែងផ្សេង" ជារូបរត់ចូលប្លង់ | ១៥ វិនាទី |
| 5 | … conserving biodiversity and natural forests … | Graphic of forests with wildlife with "conserve biodiversity and natural forests" fading in | 20 secs |
| | ... ការអភិរក្សជីវចម្រុះ និងព្រៃឈើធម្មជាតិ ... | ក្រាហ្វិកនៃព្រៃឈើ ជាមួយនឹងសត្វព្រៃនិង" អភិរក្សជីវចម្រុះ និងព្រៃឈើធម្មជាតិ" ជារូបភាពរត់ចូលប្លង់ | ២០ វិនាទី |
| 6 | … respecting traditional knowledge and rights of local and indigenous people … | Graphic of Cambodian indigenous peoples working in the forest with "respect for traditional knowledge and rights of local people" fading in | 15 secs |
| | ... គោរពចំនេះដឹងប្រពៃណី និងសិទ្ធិរបស់ប្រជាជនក្នុងតំបន់ និងជាតិដើមភាគតិច ... | ក្រាហ្វិកនៃជនជាតិដើមភាគតិចកម្ពុជាកំពុងធ្វើការនៅក្នុងព្រៃជាមួយ "គោរពប្រពៃណីចំណេះដឹងនិងសិទ្ធិរបស់ប្រជាជនក្នុងតំបន់" តិចនៅក្នុង | ១៥ វិនាទី |
| 7 | … promoting transparent and fair governance … | Graphic of local meeting with "transparent and fair governance" fading in | 15 secs |
| | ... ការលើកកម្ពស់តម្លាភាព និងអភិបាលកិច្ចល្អ ... | ក្រាហ្វិកនៃកិច្ចប្រជុំមូលដ្ឋាន ជាមួយនឹង " អភិបាលកិច្ចដែលតម្លាភាព និងយុត្តិធម៌" ប្លង់រត់ចូល | ១៥ វិនាទី |

| | | | |
|---|---|---|---|
| 8 | … and promoting full and effective participation of all relevant stakeholders | Graphic of a meeting of diverse stakeholders with "full and effective participation" fading in | 15 secs |
| | ... និងជំរុញការចូលរួមពេញលេញ និងមានប្រសិទ្ធិភាពនៃភាគីពាក់ព័ន្ធទាំងអស់ | ក្រាហ្វិកនៃកិច្ចប្រជុំមួយរបស់អ្នកពាក់ព័ន្ធចម្រុះជាមួយនឹង "ការចូលរួមពេញលេញនិងមានប្រសិទ្ធិភាព" ប្លង់រត់ចូល | ១៥ វិនាទី |
| Total on safeguards<br>នាទីសរុបផ្នែកការការពារសុវត្ថិភាព | | | 2 mins 05 secs<br>(២ នាទី និង ០៥ វិនាទី) |
| 9 | One important way in which rights can be respected and effective participation ensured is through "Free, Prior and Informed Consent" or FPIC | Graphic of forest with "Free Prior and Informed Consent" fading in | 15 secs |
| | វិធីដ៏សំខាន់មួយដែលនៅក្នុងនោះសិទ្ធិ អាចត្រូវបានគោរព និងការចូលរួមដ៏មានប្រសិទ្ធិភាពត្រូវបានធានា គឺតាមរយៈ "ដោយសេរី ការផ្តល់ព័ត៌មានជាមុន និងដោយមានការព្រមព្រៀង" ឬ FPIC | ក្រាហ្វិកនៃព្រៃឈើជាមួយ "ដោយសេរី ការផ្តល់ព័ត៌មានជាមុន និងយល់ព្រម" ប្លង់រត់ចូល | ១៥ វិនាទី |
| 10 | This means that Indigenous Peoples and other stakeholders can decide whether REDD+ actions that might affect their rights are acceptable | Graphic of a village meeting | 15 secs |
| | នេះមានន័យថា ជនជាតិដើមភាគតិច និងអ្នកពាក់ព័ន្ធផ្សេងទៀត អាចសម្រេចថាតើសកម្មភាពរេដបូក ដែលអាចប៉ះពាល់ដល់សិទ្ធិរបស់ពួកគេ គឺអាចទទួលយកបានឬទេ | ក្រាហ្វិកនៃការប្រជុំភូមិ | ១៥ វិនាទី |
| 11 | "Free" means that no-one is subjected to threats or other means of coercion | Still shot from village meeting scene with "Free" caption | 10 secs |
| | "សេរី" មានន័យថា គ្មាននរណាម្នាក់ត្រូវបានទទួលរងនូវការគំរាមកំហែង ឬ ការបង្ខិតបង្ខំដោយមធ្យោបាយណាមួយនោះទេ | ប្លង់ពីកន្លែងប្រជុំភូមិ ជាមួយនឹងចំណងជើង "ដោយសេរី" | ១៥ វិនាទី |
| 12 | "Prior" means that no actions can take | Still shot from village meeting | 10 secs |

| | | | |
|---|---|---|---|
| | place before stakeholders can voice their opinion | scene with "Prior" under "Free" | |
| | "ជាមុន" មានន័យថា គ្មានសកម្មភាពណាមួយអាចកើតឡើង មុនពេលភាគីពាក់ព័ន្ធអាចសំដែងមតិចូលរួមរបស់ពួកគេនោះទេ | ប្តូរពីកន្លែងប្រជុំភូមិ ជាមួយនឹងចំណងជើង "ជាមុន" ក្រោម "ដោយសេរី" | ១០ វិនាទី |
| 13 | "Informed" means that stakeholders must have access to all relevant information | Still shot from village meeting scene with "Informed" under "Prior" | 10 secs |
| | "ផ្តល់ព័ត៌មាន" មានន័យថា ភាគីពាក់ព័ន្ធត្រូវតែមានលទ្ធភាពទទួលបានព័ត៌មានពាក់ព័ន្ធទាំងអស់ | ប្តូរពីកន្លែងប្រជុំភូមិ ជាមួយនឹងចំណងជើង "ផ្តល់ព័ត៌មាន" ក្រោម "ជាមុន" | ១០ វិនាទី |
| 14 | "Consent" means that this is more than just consultation – stakeholders may agree or disagree | Still shot from village meeting scene with "Consent" under "Prior" | 10 secs |
| | "ដោយមានការព្រមព្រៀង" មានន័យថា នេះគឺលើសពីការពិគ្រោះយោបល់ - ភាគីពាក់ព័ន្ធអាចយល់ស្រប ឬ មិនយល់ព្រម | ប្តូរពីកន្លែងប្រជុំភូមិ ជាមួយនឹងចំណងជើង "ដោយមានការព្រមព្រៀង" ក្រោម "ជាមុន" | ១០ វិនាទី |
| 15 | Procedures to ensure FPIC have rarely been applied before in Cambodia … | Graphic of villagers working in the forest | 15 secs |
| | នីតិវិធីដើម្បីធានាបានថា FPIC កម្រនឹងត្រូវបានគេអនុវត្តពីមុន នៅក្នុងប្រទេសកម្ពុជា ... | ក្រាហ្វិកនៃអ្នកភូមិធ្វើការនៅក្នុងព្រៃ | ១៥ វិនាទី |
| 16 | … therefore your representatives on the Consultation Group will be working hard to help design a FPIC process appropriate for Cambodia, as well as ensuring that all other safeguards are respected | Graphic of meeting | 20 secs |
| | ... ដូច្នេះ តំណាងរបស់អ្នកដែលនៅក្នុងក្រុមពិគ្រោះយោបល់ នឹងត្រូវបានធ្វើកាជាច្រើន ដើម្បីជួយបង្កើតដំណើរការ FPIC មួយ សមរម្យសម្រាប់ប្រទេសកម្ពុជា ក៏ដូចជាការធានាថាការការពារសុវត្ថិភាពផ្សេងទៀតទាំងឡាយត្រូវបានគោរព | ក្រាហ្វិកនៃកិច្ចប្រជុំ | ២០ វិនាទី |

| | | | |
|---|---|---|---|
| 17 | If you would like to learn more, or want to contribute, please contact the REDD+ Taskforce Secretariat | REDD+ Cambodia logo and RTS contact information | 20 secs |
| | ប្រសិនបើអ្នកចង់រៀនបន្ថែមទៀត ឬ ចង់រួមចំណែកក្នុងដំណើរការនេះ សូមទាក់ទងទៅក្រុមការងារលេខាធិការដ្ឋានរេដបូកកម្ពុជា | រូបភាពពីព្រៃឈើ ជាមួយនឹង Logos របស់រេដបូកកម្ពុជា និងព័ត៌មានទំនាក់ទំនងរបស់លេខាធិការដ្ឋានរេដបូកកម្ពុជា | ១០ វិនាទី |
| Total for FPIC<br>នាទីសរុបផ្នែក FPIC | | | 2 mins 05 secs<br>(២ នាទី និង ០៥ វិនាទី) |
| Grand Total<br>នាទីសរុប | | | 4 mins 10 secs<br>(៤ នាទី និង ១០ វិនាទី) |

# MRV និងការត្រួតពិនិត្យព្រៃឈើ

MRV មានន័យថា ៖ **ការវាស់វែង** ជាវិធានការវាស់កាបូនព្រៃឈើនៅថ្នាក់ជាតិ, **ការរាយការណ៍** គឺដើម្បីរាយការណ៍ទៅ អនុសញ្ញាក្របខ័ណ្ឌសហប្រជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នៅលើការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា និង**ការផ្ទៀងផ្ទាត់** គឺជាដំណើរការអន្តរជាតិដែល UNFCCC វាយតម្លៃទៅលើគុណភាព និងភាពត្រឹមត្រូវនៃព័ត៌មាននៅក្នុងរបាយការណ៍ដែលបានដាក់។

**ការត្រួតពិនិត្យ** ៖ គឺសំដៅលើការតាមដានអ្វីគ្រប់យ៉ាងលើកលែងតែទៅលើកាបូន... ទំហំនៃការសង្កេតដើមឈើ នៃសត្វព្រៃ ឬ តម្លៃនៃផលិតផលដែលទទួលបានពីព្រៃឈើនេះ។

Drawing to Explain

ដូច្នេះ តើយើងអាចដឹងថាតើឧស្ម័នកាបូនិច (CO2) ប៉ុន្មាន ដែលកំពុងសាយភាយចេញពីព្រៃឈើ? ការវាស់ស្ទង់ការបំភាយឧស្ម័នCO2 ជាបច្ចេកទេសគឺមានការលំបាក។ វាតម្រូវឱ្យមានព័ត៌មានពីរប្រភេទ ដូចខាងក្រោម៖

- ទីមួយ ៖ គឺពីរបៀបនៃការផ្លាស់ប្តូរការប្រើប្រាស់ដីធ្លី ហើយព័ត៌មាននេះគឺបានមកពីទិន្នន័យរយៈចម្ងាយ ជាពិសេសរូបភាពតាមផ្កាយរណប។
- ទីពីរ ៖ គឺថាតើកាបូនចំនួនប៉ុន្មាន ដែលបានកើនឡើង ឬ បាត់បង់ លើប្រភេទនៃការផ្លាស់ប្តូរការប្រើប្រាស់ដីធ្លីនីមួយ? ហើយព័ត៌មាននេះ គឺបានមកពីការសិក្សាស្ទង់មតិលើផ្ទៃដី។ តាមរយៈការបញ្ចូលព័ត៌មានទាំងពីរប្រភេទនេះ គឺយើងអាចធ្វើការគណនាថាតើឧស្ម័ន CO2 ប៉ុន្មានដែលបានសាយភាយចេញ។

ប្រទេសកម្ពុជា គឺកំពុងរៀបចំបង្កើតប្រព័ន្ធ MRV និងប្រព័ន្ធត្រួតពិនិត្យព្រៃឈើរបស់ខ្លួនជាមួយគ្នានេះដែរ ព័ត៌មានសំខាន់អំពីព្រៃឈើជាតិ នឹងត្រូវបានផ្សព្វផ្សាយ។


សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង
**លេខាធិការដ្ឋានរេដបូកកម្ពុជា**
លេខទូរស័ព្ទ៖ (+855) 23 224 251
អ៊ីម៉ែល៖ redd.secretariat@cambodia-redd.org
គេហទំព័រ៖ www.cambodia-redd.org
ទំព័រ Facebook៖ **Cambodia REDD+ National Programme**

# ផលប្រយោជន៍នៅក្រោមរេដបូក

នៅក្រោមការអនុវត្តរេដបូក អ្នកដែលរួមចំណែកក្នុងការកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ និងការគ្រប់គ្រងព្រៃឈើឲ្យបានប្រសើរឡើង នឹងត្រូវទទួលបានផលប្រយោជន៍។ ប្រទេសកម្ពុជា ត្រូវរាយការណ៍ទៅសហគមន៍អន្តរជាតិលើការរីកចម្រើនដែលបានធ្វើ ដូច្នេះ នឹងទទួលបានធនធានហិរញ្ញវត្ថុពីបណ្តាប្រទេសអភិវឌ្ឍន៍។

Drawing to Explain

- ការសម្រេចទៅលើការចែករំលែកផលប្រយោជន៍ គឺមានភាពស្មុគស្មាញ... គឺត្រូវចំណាយថវិកាជាច្រើនក្នុងការវាស់កាបូន ដើម្បីសម្រេចថានរណាបានរួមចំណែកប៉ុន្មានទៅក្នុងការអនុវត្ត។
- វិធានការមួយចំនួនផ្សេងទៀតនឹងត្រូវប្រើ- ដូចជា កិច្ចខិតខំប្រឹងប្រែងដែល ភាគីពាក់ព័ន្ធផ្សេងគ្នាបានធ្វើ។
- ដើម្បីធានាថាដំណើរការនេះ មានតម្លាភាព និងប្រកបដោយសមធម៌ គឺចាំបាច់ត្រូវមានកិច្ចព្រមព្រៀងទូទៅមួយទៅលើរបៀបនៃការអនុវត្ត។
- ព័ត៌មានទាំងអស់ ត្រូវផ្សព្វផ្សាយឲ្យបានទូលំទូលាយ។
- វាមានសារសំខាន់ក្នុងការយល់ថា ផលប្រយោជន៍ទាំងនេះនឹងមិនត្រូវបានផ្តល់ជូនក្នុងទម្រង់ជាទឹកប្រាក់។
- ផលប្រយោជន៍ទាំងនេះ អាចធ្វើតាមរយៈការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសង្គម ការបណ្តុះបណ្តាលលើការពង្រឹងជីវភាពរស់នៅថ្មី ឬ ក្នុងទម្រង់ផ្សេងៗទៀត។


សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង

**លេខាធិការដ្ឋានរេដបូកកម្ពុជា**

លេខទូរស័ព្ទ៖ (+855) 23 224 251

អ៊ីម៉ែល៖ redd.secretariat@cambodia-redd.org

គេហទំព័រ៖ www.cambodia-redd.org

ទំព័រ **Facebook**៖ **Cambodia REDD+ National Programme**

# បញ្ហាដែលបណ្ដាលឲ្យមានការបាត់បង់ និង រេចរឹលព្រៃឈើ

រេដបូក គឺជាយន្តការក្នុងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីព្រៃឈើ។ វិធានការដើម្បីកាត់បន្ថយ គឺត្រូវដោះស្រាយនូវបញ្ហាដូចខាងក្រោម។

Drawing to Explain

- ការកែប្រែព្រៃឈើទៅជាការប្រើប្រាស់ផ្សេងៗ ជាពិសេសផលិតកសិកម្មខ្នាតធំ។ សម្បទានដីសេដ្ឋកិច្ច ដើរតួនាទីដ៏សំខាន់មួយនៅក្នុងរឿងនេះ។
- ការកាប់ឈើខុសច្បាប់ - បើទោះបីជាមានតែដើមឈើមួយចំនួនត្រូវបានកាប់ក្នុងកំឡុងពេលកាប់ឈើខុសច្បាប់ ប៉ុន្តែបញ្ហានេះ គឺបណ្ដាលឱ្យមានការរេចរឹលព្រៃឈើ។
- ការពង្រីកទំហំដីកសិកម្មខ្នាតតូច - ជាធម្មតា កសិកម្ម គឺធ្វើក្នុងទំហំដី ខ្នាតតូច ប៉ុន្តែនៅក្នុងតំបន់ទីវាលធំមួយ។
- ភ្លើងឆេះព្រៃ - ជាញឹកញាប់បានកើតឡើងដោយសារអ្នកបរបាញ់ ឬ កសិករ ដែលដុតវាលស្រែរបស់ពួកគេ។
- បញ្ហាទាំងនេះ ត្រូវបានកើតឡើងដោយអំពើពុករលួយ និងការអនុវត្តច្បាប់ទន់ខ្សោយ។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង
**លេខាធិការដ្ឋានរេដបូកកម្ពុជា**
លេខទូរស័ព្ទ៖ (+855) 23 224 251
អ៊ីម៉ែល៖ redd.secretariat@cambodia-redd.org
គេហទំព័រ៖ www.cambodia-redd.org
ទំព័រ Facebook៖ Cambodia REDD+ National Programme

# កិច្ចការពារសុវត្ថិភាពរេដបូក

ដើម្បីឲ្យការអនុវត្តរេដបូក ប្រកបដោយប្រសិទ្ធភាព និងសមធម៌ គឺចាំបាច់ត្រូវការកិច្ចការពារសុវត្ថិភាព ដើម្បីធានាឲ្យបានថាសិទ្ធិត្រូវបានគោរព។ សហគមន៍អន្តរជាតិ បានយល់ព្រមលើកិច្ចការពារសុវត្ថិភាពដែលប្រទេសនានាត្រូវតែគោរព រួមទាំងប្រទេសកម្ពុជា។ ទាំងនេះរួមមាន៖

Drawing to Explain

- សកម្មភាពរេដបូក គួរតែស្របទៅនឹងគោលនយោបាយជាតិ និងកិច្ចព្រមព្រៀងអន្តរជាតិ។
- សកម្មភាពរេដបូក គួរតែយូរអង្វែង និងមិនបណ្តាលឲ្យមានការកាប់បំផ្លាញ ព្រៃឈើនៅតំបន់ណានោះទេ
- សកម្មភាពរេដបូក គួរអភិរក្សជីវចម្រុះ និងព្រៃធម្មជាតិ
- សកម្មភាពរេដបូក គួរតែគោរពប្រពៃណី និងសិទ្ធិរបស់ប្រជាជនមូលដ្ឋាន និងជនជាតិដើមភាគតិច
- សកម្មភាពរេដបូក គួរតែលើកកម្ពស់តម្លាភាព និងអភិបាលកិច្ចត្រឹមត្រូវ
- សកម្មភាពរេដបូក គួរតែលើកកម្ពស់ការចូលរួមពេញលេញ និងមានប្រសិទ្ធិភាពនៃភាគីពាក់ព័ន្ធទាំងអស់។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង
**លេខាធិការដ្ឋានរេដបូកកម្ពុជា**
លេខទូរស័ព្ទ៖ (+855) 23 224 251
អ៊ីម៉ែល៖ redd.secretariat@cambodia-redd.org
គេហទំព័រ៖ www.cambodia-redd.org
ទំព័រ **Facebook**៖ **Cambodia REDD+ National Programme**

# សហប្រយោជន៍ និងរេដបូក

រេដបូក គឺអំពីការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីព្រៃឈើ។ ប៉ុន្តែ ព្រៃឈើផ្តល់នូវប្រយោជន៍ជាច្រើនទៀត ក្រៅពីការរក្សាទុកនូវកាបូន និងស្រូបពីក្នុងបរិយាកាស។ ទាំងនេះត្រូវបានសំដៅទៅលើ "សហប្រយោជន៍" នៃព្រៃឈើ។ តើមានអ្វីខ្លះ?

Drawing to Explain

- សហប្រយោជន៍ រួមមាន៖
- ធនធានផលិតផលដែលប្រមូលផលបានពីព្រៃឈើសម្រាប់ការប្រើរបស់សហគមន៍។ ទាំងនេះរួមបញ្ចូលទាំងឈើ ក៏ដូចជាអនុផលព្រៃឈើ មានដូចជា៖ ផ្លែឈើ បន្លែ ឫស្សី ផ្តៅ ជាដើម។
- ការអភិរក្សជីវចម្រុះ - ព្រៃឈើផ្តល់នូវជម្រកសម្រាប់ប្រភេទសត្វព្រៃជាច្រើន។
- សេវាកម្មប្រព័ន្ធអេកូឡូស៊ី ដូចជា ការរក្សាទឹក ការការពារឆ្នេរ ជាដើម។
- សោភ័ណ្ឌ - ព្រៃឈើគឺជាកន្លែងដែលអាចទៅទស្សនាដើម្បីបន្ធូរអារម្មណ៍តានតឹង។

នៅក្នុងការអនុវត្តរេដបូក វាជាការសំខាន់ដើម្បីធានាថាសហប្រយោជន៍ទាំងនេះ ត្រូវបានរក្សា និងអភិរក្ស។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង
**លេខាធិការដ្ឋានរេដបូកកម្ពុជា**
លេខទូរស័ព្ទ៖ (+855) 23 224 251
អ៊ីម៉ែល៖ redd.secretariat@cambodia-redd.org
គេហទំព័រ៖ www.cambodia-redd.org
ទំព័រ Facebook៖ **Cambodia REDD+ National Programme**

## ឧបសម្ព័ន្ធទី១ ៖ ប្រធានបទសម្រាប់ចាក់ផ្សាយ

| លរ | ប្រធានបទ | បញ្ហាត្រូវដោះស្រាយ | ពិធីករទូរទស្សន៍ |
|---|---|---|---|
| ១ | តើរេដបូកជាអ្វី | ជាមូលដ្ឋាន៖ ឧស្ម័នផ្ទះកញ្ចក់ ការប្រែប្រួលអាកាសធាតុ ព្រៃឈើជាអាងស្តុកកាបូនដ៏ធំដែលអាចបញ្ចេញឧស្ម័នកាបូនិច រួមចំណែកធ្វើឱ្យមានការប្រែប្រួលអាកាសធាតុ | - ឯ.ប. ជា សំអាង (រដ្ឋបាលព្រៃឈើ)/ លោក អ៊ុយ កាម៉ាល (ក្រសួងបរិស្ថាន) ៖ អាចសម្ភាសជាមួយគាត់អំពីការប្រែប្រួលអាកាសធាតុ<br>- រាយការណ៍ករណីពីខេត្តមួយ |
| ២ | ការបាត់បង់ និងរេចរឹលព្រៃឈើ | អត្រាបាត់បង់ព្រៃឈើនៅថ្នាក់ជាតិ និងពិភពលោក (មូលហេតុ) | វេទិកាជជែកពិភាក្សារបស់សិស្សនិស្សិត |
| ៣ | សកម្មភាពរេដបូក | តើអ្វីអាចធ្វើបាន៖ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | - លោក ឃុន វឌ្ឍនា (រដ្ឋបាលព្រៃឈើ)៖ សម្ភាសអំពីរេដបូកកម្ពុជា និងដំណើរការរីកចម្រើន<br>- អាចរាប់បញ្ចូលរូបភាព និងបទសម្ភាសជាមួយ សហគមន៍ និង អង្គការមិនមែនរដ្ឋាភិបាល |
| ៤ | ការចំណាយ និងផលចំណេញ ពីរេដបូក | តម្លៃឱកាស ចំណាយក្នុងការអនុវត្តសកម្មភាព និងផលចំណេញពីមានព្រៃឈើ ជីវភាពប្រជាពលរដ្ឋ អនុផលព្រៃឈើ ជាដើម។ | - ឯ.ប ជា សំអាង លោក/ អ៊ុយ កាម៉ាល (ក្រសួងបរិស្ថាន) (រដ្ឋបាលព្រៃឈើ)៖ បទសម្ភាសរេដបូកកម្ពុជា និងការរីកចម្រើន<br>- របាយការណ៍ពីខេត្តមួយ |
| ៥ | រេដបូកផ្អែកលើលទ្ធផល | តើវាមានន័យដូចម្ដេច? កម្រិតយោង និងការត្រួតពិនិត្យព្រៃឈើ ដើម្បីវាយតម្លៃលទ្ធផល | - លោក ឃន សារ៉េត / លោកឡេង ជីវិន (រដ្ឋបាលព្រៃឈើ)៖ ពន្យល់អំពីកម្រិតយោង និងការត្រួតពិនិត្យព្រៃឈើ<br>- អាចធ្វើទស្សនកិច្ចគម្រោងរេដបូកមួយនៅថ្នាក់មូលដ្ឋាន |

| | | | |
|---|---|---|---|
| ៦ | ការបែងចែកផលប្រយោជន៍ | តើអ្វីជាការបែងចែកផលប្រយោជន៍? តើវាមានដំណើរការយ៉ាងដូចម្តេច? និងតើនរណាជាអ្នកទទួលផល? | - លោក ឡុង រត្តនៈកុមារ (រដ្ឋបាល ព្រៃឈើ)៖ ពន្យល់អំពីការងារដែលគាត់បានចូលរួមក្នុងការងារបែងចែកផលប្រយោជន៍ |
| ៧ | ប្រព័ន្ធការពារសុវត្ថិភាព | តើអ្វីជាប្រព័ន្ធការពារសុវត្ថិភាព? ហេតុអ្វីយើងត្រូវការវា? | - លោក ឈុន ឌីលុច (រដ្ឋបាលព្រៃឈើ)៖ ពន្យល់អំពីប្រព័ន្ធការពារសុវត្ថិភាព និងដំណើរការដែលបានអនុវត្ត |
| ៨ | ផលប្រយោជន៍មិនមែនជាកាបូន (ក្រៅពីកាបូន) | តម្លៃនៃការរក្សាព្រៃឈើ មានពាក់ព័ន្ធបន្តិចជាមួយតំលៃចំណាយនិងផលចំណេញពីរេដបូក | - កញ្ញា តេង រិទ្ធី (NGOF) និងលោក យាង ដូណាល (FFI) ៖ ចែករំលែកអំពីតម្លៃព្រៃឈើ និងថាតើរេដបូកមានសារៈសំខាន់យ៉ាងដូចម្តេចខ្លះ<br>- បទសម្ភាសជាមួយសហគមន៍ |
| ៩ | បញ្ហាប្រឈមក្នុងការអនុវត្តរេដបូក | មូលហេតុនៃការបាត់បង និងរេចរឹលព្រៃឈើមិនអាចលុបបំបាត់បាន ហើយតម្រូវការដី (សម្រាប់កសិកម្ម និងអភិវឌ្ឍទីក្រុង) នៅតែបន្តបង្កើនសម្ពាធលើព្រៃឈើ | - ឯ.ប. ជា សំអាង, លោក គីម ណុង (ក្រសួងបរិស្ថាន) និងលោក វ៉ា មឿន (ម្លប់បៃតង)៖ ពិភាក្សាអំពីបញ្ហាប្រឈមនានា និងមធ្យោបាយដែលអាចដោះស្រាយ |
| ១០ | កាចូលរួមរបស់ភាគីអ្នកពាក់ព័ន្ធ | តើអ្នកពាក់ព័ន្ធនានាអាចចូលរួមក្នុងការអនុវត្តរេដបូកយ៉ាងដូចម្តេច | ការចូលរួមពីក្រុមផ្សេងៗគ្នា ឧទាហរណ៍៖ សមាជិកក្រុមប្រឹក្សាយោបល់ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ, អង្គការសង្គមស៊ីវិល (ថ្នាក់ខេត្ត), គ្រឹះស្ថានអប់រំ, ក្រុមជនជាតិដើមភាគតិច, សហគមព្រៃឈើ សហគមន៍ជលផល សហគមន៍តំបន់ការពារ និងវិស័យឯកជន។ |

## ឧបសម្ព័ន្ធទី២ ៖ គម្រោងពិស្តារសម្រាប់កម្មវិធីនីមួយៗ

<u>កម្មវិធីទី១៖ តើរេដបូកជាអ្វី ?</u>

ក. សេចក្តីផ្តើម (៦នាទី)

- ការណែនាំ និងចំណាប់អារម្មណ៍នៃកម្មវិធីដោយអ្នករៀបចំកម្មវិធី
- ការចាក់បញ្ចាំងវីដេអូឃ្លីប ស្តីពី "ការណែនាំអំពីរេដបូក" និង/ឬវីដេអូខ្លីៗអំពីព្រៃឈើកម្ពុជា

ខ. សំណួរ និងចំលើយ (២០នាទី)

- អ្នករៀបចំកម្មវិធី នឹងលើកសំណួរជាបន្តបន្ទាប់ទៅ ឯ.ប. ជា សំអាង / លោក អ៊ុយ កាម៉ាល

<u>សំណួរទី១៖ នាពេលបច្ចុប្បន្ន យើងបានឮជាច្រើនអំពីការប្រែប្រួលអាកាសធាតុពិភពលោក-- សូមលោកជួយពន្យល់ដោយសង្ខេបអំពីបញ្ហានេះបានឬទេ និងថាតើហេតុអ្វីបានជាយើងត្រូវគិតពីបញ្ហានេះនៅកម្ពុជា?</u>

ចំលើយ (ចំនុចដែលត្រូវពន្យល់)៖

- o ការប្រែប្រួលអាកាសធាតុជាលទ្ធផលនៃការកើនឡើងនៃឧស្ម័នផ្ទះកញ្ចក់ ជាពិសេសឧស្ម័នកាបូនិច នៅក្នុងបរិយាកាស
- o ឧស្ម័នផ្ទះកញ្ចក់ទាំងនេះចាប់យកកំដៅពីព្រះអាទិត្យ កាត់បន្ថយបរិមាណ (ចំណាំងផ្លាត) ពីផែនដីទៅលំហបរិយាកាសវិញ
- o វាមានន័យថា សីតុណ្ហភាពមធ្យមរបស់ផែនដីបានកើនឡើង ជាពិសេសក្នុងរយៈពេល ៥០ឆ្នាំកន្លងទៅ ជាលទ្ធផលធ្វើឱ្យមានការប្រែប្រួលទម្លាប់ធាតុអាកាសយ៉ាងខ្លាំង។ នៅកម្ពុជា ការសិក្សាគំរូបានបង្ហាញថា យើងអាចរងគ្រោះពីកំណើនគ្រោះរាំងស្ងួត ភ្លៀងកាន់តែខ្លាំងនៅពេលមានភ្លៀង ហើយបង្កឱ្យមានទឹកជំនន់ ការហូរច្រោះដី និងកំណើនទឹកសមុទ្រ បង្កគ្រោះថ្នាក់ដល់សហគមន៍តំបន់ឆ្នេរ។ ផលិតផលកសិកម្ម នឹងរងផលប៉ះពាល់ជាអវិជ្ជមាន ធ្វើឱ្យតម្លៃផលិតផលកសិកម្មកាន់តែថ្លៃ និងធ្វើឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់ជីវភាពរស់នៅរបស់កសិករ

- ប្រភពនៃឧស្ម័នផ្ទះកញ្ចក់ កើតមកពីការដុតប្រេងឥន្ទនៈផូស៊ីល ប្រេងធ្យូងថ្ម ជាដើម ដែលត្រូវបានប្រើជាច្រើននៅក្នុងវិស័យឧស្សាហកម្ម និងដឹកជញ្ជូន។ ប៉ុន្តែ រុក្ខជាតិក៏កើតឡើងពីកាបូនដែរ ដូច្នេះនៅពេលវាត្រូវបានគេកាប់ និងដុតបំផ្លាញ នៅពេលនោះវានឹងមានឧស្ម័នកាបូនិចជាច្រើនភាយចេញទៅក្នុងបរិយាកាស ដែលដូច្នេះការកាប់ព្រៃឈើ គឺអាចចូលរួមក្នុងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រមាណជា ១០ភាគរយ នៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបក្នុងពិភពលោក។

**<u>*សំណួរទី២៖ សូមលោកពន្យល់ឱ្យបានពិស្តារបន្តិចអំពី តួនាទីព្រៃឈើនៅក្នុងការប្រែប្រួលអាកាសធាតុ*</u>**

**ចំលើយ (ចំនុចដែលត្រូវពន្យល់) ៖**

- ដូចបានជម្រាបជូនខាងលើ នៅពេលព្រៃឈើត្រូវបានកាប់ឆ្ការចេញ និងនៅពេលដែលដើមឈើខ្លះត្រូវបានដកហូតពីព្រៃ ដោយការពុកដើមឈើ ស្លឹកឈើ និងរឹសវា គឺពេលនោះវានឹងមានការភាយចេញនៃឧស្ម័នកាបូនិចទៅក្នុងបរិយាកាស។ សហគមន៍អន្តរជាតិបានខិតខំដោះស្រាយបញ្ហាការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីវិស័យឧស្សាហកម្ម និងវិស័យដឹកជញ្ជូននៅពេលខ្លះ ប៉ុន្តែបច្ចុប្បន្នពួកគេបានចាប់ផ្តើមយកចិត្តទុកដាក់ក្នុងដោះស្រាយបញ្ហាខាងលើជាមួយវិស័យព្រៃឈើ។
- ប្រសិនបើយើងអាចកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីវិស័យឧស្សាហកម្ម ដឹកជញ្ជូន និងព្រៃឈើបាន នោះយើងអាចកំហិតការប្រែប្រួលអាកាសធាតុបាន។ នេះជាហេតុផលដែលថាព្រៃឈើមានសារសំខាន់ ពីព្រោះបន្ថែមលើការខិតខំដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ យើងក៏ត្រូវសិក្សាអំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុផងដែរ។ ព្រៃឈើបញ្ចេញកាបូនទៅក្នុងបរិយាកាសនៅពេលគេកាប់រំលំ ប៉ុន្តែវាស្រូបកាបូននៅពេលវាដុះលូតលាស់។ ព្រៃឈើ គឺអាចការពារតំបន់ឆ្នេរពីការកើនឡើងកម្ពស់ទឹកសមុទ្រ និងពីខ្យល់ព្យុះ ការពារជម្រាលជើងភ្នំពីការហូរច្រោះ និងការបាក់ស្រុតដី វាក៏ជួយយើងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដែរ។ ដូច្នេះការពារព្រៃ គឺជាជម្រើសឈ្នះឈ្នះ។

**<u>*សំណួរទី៣៖ សូមអរគុណដល់ការបកស្រាយដ៏ក្បោះក្បាយអំពីការប្រែប្រួលអាកាសធាតុ និងតួនាទីនៃព្រៃឈើក្នុងការកាត់បន្ថយផលប៉ះពាល់ និងការបន្សាំទៅការប្រែប្រួលអាកាសធាតុ។*</u>**

<u>ប៉ុន្តែ សូមលោកជួយពន្យល់ពីអត្ថន័យនៃពាក្យ "រេដបូក" និងថាតើអ្វីទៅជា "រេដបូក"? ដូចយើងបានឃើញនៅក្នុងខ្សែវីដេអូដែលចាក់បង្ហាញអម្បាញ់មិញ។</u>

ចំលើយ (ចំនុចដែលត្រូវពន្យល់)៖

- ដូចបានជម្រាបជូន មានកិច្ចព្រមព្រៀងជាអន្តរជាតិមួយសម្រាប់ដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ។ នៅក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) គឺថាបណ្តាប្រទេសជឿនលឿនបានទទួលស្គាល់ថា ពួកគេត្រូវទទួលខុសត្រូវលើការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ភាគច្រើន ហើយបានឯកភាពលើការបង់ថ្លៃក្នុងការការពារព្រៃឈើ ទៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍ ដូចជា ប្រទេសកម្ពុជា ជាដើម។
- ប៉ុន្តែការព្រមព្រៀងបង់ថ្លៃនេះ ពឹងផ្អែកលើសមត្ថភាពរបស់កម្ពុជា ក្នុងការបង្ហាញថាខ្លួនបានកាត់បន្ថយការបញ្ចេញឧស្ម័នពីវិស័យព្រៃឈើ។ ហើយនេះ គឺជាមូលដ្ឋានគ្រឹះនៃ "រេដបូក"។
- ទោះជាយ៉ាងណាក៏ដោយ គឺមានបញ្ហាប្រឈមជាច្រើនដោះស្រាយ ដើម្បីធ្វើឲ្យសម្រេចបានក្នុងការអនុវត្តយន្តការ ដែលអ្នកខ្លះគិតថាងាយស្រួលនេះ។
- ទីមួយ វាមិនមែនជាបញ្ហាសាមញ្ញទេក្នុងការបង្ហាញថា មានការកាត់បន្ថយការបញ្ចេញឧស្ម័នពីព្រៃឈើ។ លោកអ្នកមិនអាចមើលឃើញឧស្ម័នកាបូនិចនោះទេ ដូច្នេះដើម្បីបញ្ជាក់ថាមានការកាត់បន្ថយការបញ្ចេញឧស្ម័ន គឺទាមទារបច្ចេកទេសច្បាស់លាស់។ ទីពីរ មានសម្ពាធជាច្រើនដែលនាំឱ្យបាត់បង់ និងរេចរឹលព្រៃឈើ គឺមកពីវិស័យផ្សេង ដូចជា វិស័យកសិកម្ម ដូច្នេះវាត្រូវការកិច្ចសហការដែលកាន់តែសកម្មពីខាងគោលនយោបាយដែលប្រសើរជាងពីពេលមុនៗ។ ទីបី សហគមន៍អន្តរជាតិលើកឡើងថាបញ្ហាប្រព័ន្ធសុវត្ថិភាពជាមូលដ្ឋានត្រូវតែគោរព ដូចនេះយុទ្ធសាស្ត្រនានាត្រូវតែដាក់ចេញអនុវត្តនៅនឹងកន្លែង ដើម្បីធានាថាវាត្រូវបានដោះស្រាយ។ យើងនឹងពិភាក្សារាល់បញ្ហាទាំងនេះនៅក្នុងកម្មវិធីក្រោយៗទៀត។

<u>សំណួរទី៤៖ សូមអរគុណ។ ការបកស្រាយនេះ គឺពិតជាមានសារប្រយោជន៍ណាស់ តែសូមលោកជួយបន្យល់បន្ថែមបន្តិចអំពី ថាតើយើងត្រូវធ្វើអ្វីទៀតដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័ន និងដើម្បីទទួលបានមូលនិធិគាំទ្រពីបណ្តាប្រទេសអភិវឌ្ឍន៍?</u>

**ចំលើយ (ចំណុចត្រូវពន្យល់)៖**

- មានបទអន្តរាគមន៍ជាច្រើនដែលអាចអនុវត្តបាន។ ឧទាហរណ៍៖ យើងត្រូវការតឹងរឹងជាមួយសកម្មភាពខុសច្បាប់ ការវាតយកដីធ្លីខុសច្បាប់ ការកាប់ឈើខុសច្បាប់ជាដើម យើងអាចជំរុញការស្តារព្រៃឡើងវិញ និងការដាំដើមឈើឡើងវិញនៅលើដីទំនេរ។ យើងអាចបង្កើនលទ្ធភាពរបស់យើងក្នុងការបង្ការភ្លើងឆេះព្រៃ និងត្រូវពន្លត់វាមុនពេលវារីករាលដាលធំឡើង។ វាមានសកម្មភាពជាច្រើនទៀត ដែលយើងអាចធ្វើអន្តរាគមន៍បាន។

<u>**សំណួរទី៥៖ តើវាមានផលប៉ះពាល់អ្វីខ្លះទៅលើសហគមន៍ជនបទ? តើវាមានន័យថាជាការខុសច្បាប់ក្នុងការធ្វើសកម្មភាពផ្សេងៗក្នុងព្រៃឈើឬយ៉ាងណា?**</u>

**ចំលើយ (ចំនុចត្រូវបន្យល់)៖**

- មិនដូច្នេះទេ។ ប្រជាជននៅតាមសហគមន៍ជនបទនានា មានទម្លាប់ជាមួយព្រៃឈើដោយស្វែងរកចំណីអាហារ បន្លែបង្កា ប្រមូលអុស ឬ ឈើសម្រាប់ផលិតធ្យូង កាប់សាងសង់ និងជួសជុលផ្ទះសំបែង។ ប៉ុន្តែសកម្មភាពទាំងនេះ គឺមិនប៉ះពាល់ធំដុំទេ នៅពេលគិតអំពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។
- ដូចខ្ញុំបានជំម្រាបជូនខាងដើម យើងនឹងរឹតបន្តឹងលើសកម្មភាពខុសច្បាប់នានា ហើយការដកហូតឈើ ឬ ផលិតផលដទៃទៀតដែលខុសច្បាស់នៅក្នុងតំបន់ការពារនឹងមិនអនុញ្ញាតឡើយ ប៉ុន្តែប្រសិនបើសហគមន៍ទាំងនោះ មានព្រៃសហគមន៍ផ្ទាល់របស់ពួគគាត់ ឬក៏ ព្រៃឈើដែលប្រើប្រាស់តាមប្រពៃណី យើងមិនហាមឃាត់នោះទេ។
- ជាងនេះទៅទៀត ការផ្តោតនេះ គឺនឹងមើលទៅលើតែសកម្មភាពខុសច្បាប់ខ្នាតធំ និងការបង្ការការរីកដាលក្នុងការបាត់បង់ និងរេចរឹលព្រៃឈើ
- ជាការពិត សហគមន៍ជនបទនានា នឹងមានឱកាសក្នុងការទទួលបានផលប្រយោជន៍ដោយផ្ទាល់ពីរេដបូក ពីព្រោះប្រសិនបើពួកគាត់ចូលរួមកាត់បន្ថយការបញ្ចេញឧស្ម័នជាឧទាហរណ៍ ដោយដាំឈើលើដីទទេ ឬ ការល្បាតព្រៃឈើ ដើម្បីការពារពាល់សកម្មភាពខុសច្បាប់នានា នោះពួកគាត់នឹងទទួលផលប្រយោជន៍ដែលកើតចេញពីការបង់ថ្លៃពីបណ្តាប្រទេសជឿនលឿន។

**<u>សំណួរទី៦៖ តើផលទាំងនោះនឹងកើតមានប្រាកដមែនរឺ? សហគមជនបទបានលឺការសន្យាជាច្រើនប៉ុន្តែមិនដែលកើតមានរហូតមកដល់ឥឡូវ?</u>**

**ចំលើយ (ចំនុចត្រូវពន្យល់)៖**

- ចំនុចនេះ គឺដូចខ្ញុំបានលើកឡើងអំពីប្រព័ន្ធសុវត្ថិភាព។ ចំនុចមួយនៅក្នុងកិច្ចព្រមព្រៀង នៃអនុសញ្ញា UNFCCC បានបញ្ជាក់ថា ត្រូវមានការគ្រប់គ្រងរេដបូក ប្រកបដោយតម្លាភាព ហើយត្រូវមានការចូលរួមពេញលេញ និងប្រកបដោយប្រសិទ្ធភាពពីគ្រប់សមាជិកអ្នកពាក់ព័ន្ធ ដូច្នេះសហគមន៍ជនបទនឹងមានឱកាសប្រសើរជាងពីមុនក្នុងការធានានូវទាំងសិទ្ធិរបស់សហគមន៍ និងទាំងផលប្រយោជន៍ប្រកបដោយយុត្តិធម៌ និងសមធម៌។
- ជាថ្មីម្តងទៀត យើងនឹងជជែកវែកញែកយ៉ាងស៊ីជម្រៅបន្ថែមទៀតនៅក្នុងកម្មវិធីខាងមុខទៀត។

**ក. វគ្គសំណួរ និងចំលើយពីអ្នកស្តាប់ (១០នាទី)**

សមាជិកអ្នកចូលរួមស្តាប់ នឹងត្រូវបានអញ្ជើញឱ្យលើកជាសំណួរទៅវាគ្មិន។ សំណួរមួយចំនួន អាចមានដូចខាងក្រោម៖

- តើនរណាជាអ្នកគ្រប់គ្រងរេដបូកនៅកម្ពុជា?
- តើមានអ្វីកើតឡើង ប្រសិនបើព្រៃនៅផ្នែកខ្លះនៃប្រទេសកម្ពុជា ត្រូវបានគ្រប់គ្រងយ៉ាងល្អ តែនៅតំបន់ផ្សេងទៀតត្រូវបានបាត់បង់?
- តើរេដបូក នឹងចាប់ផ្តើមនៅពេលណានៅកម្ពុជា?
- តើគោលនយោបាយ ស្តីពី សម្បទានដីសេដ្ឋកិច្ចមានភាពស៊ីគ្នាជាមួយរេដបូកយ៉ាងដូចម្តេចដែរ?

**ខ. សរុប (៣នាទី)**

អ្នករៀបចំកម្មវិធីអញ្ជើញភ្ញៀវមានមតិយោបល់ និងសង្ខេបសារគន្លឹះៗ ដែលបានលើកឡើងក្នុងកម្មវិធី និងផ្សព្វផ្សាយអំពីកម្មវិធីនានា សម្រាប់ពេលខាងមុខទៀត។

## កម្មវិធីទី២៖ ការបាត់បង់ និងរេចរឹលព្រៃឈើ

### ក. សេចក្ដីផ្ដើម (៦នាទី)

- សេចក្ដីផ្ដើមពីអ្នករៀបចំកម្មវិធី៖ ក្នុងកម្មវិធីកន្លងទៅយើងបានយល់ដឹងអំពីមូលដ្ឋានគ្រឹះរបស់រេដបូក ប៉ុន្តែនៅក្នុងកម្មវិធីនេះ យើងនឹងស្វែងយល់បន្ថែមទៀតអំពីមូលហេតុនៃការបាត់បង់ និងរេចរឹលព្រៃឈើនៅកម្ពុជា។
- បញ្ចាំងវីដេអូ បង្ហាញអំពីការបាត់បង់ និងរេចរឹលព្រៃឈើ ដោយមានការពន្យល់បន្ថែមអំពីភាពខុសគ្នានៃពាក្យទាំងពីរ។

### ខ. អ្នកសម្របសម្រួលនៅក្នុងកិច្ចពិភាក្សា

- ជាសេចក្ដីបន្ថែម លោក អ៊ុយ កាម៉ាល នឹងសម្របសម្រួលអង្គពិធី
- អ្នកសម្របសម្រួល នឹងកត់ត្រាអំពីមតិយោបល់នៅក្នុងកិច្ចពិភាក្សា ហើយនឹងផ្ដល់យោបល់ជាបន្តបន្ទាប់។

### គ. វេទិកាជជែកពិភាក្សារបស់និស្សិត (២៥នាទី)

- សិស្សនិស្សិតមកពីសកលវិទ្យាល័យភូមិន្ទភ្នំពេញ និង សកលវិទ្យាល័យភូមិន្ទកសិកម្ម នឹងចូលរួមក្នុងវេទិកាជជែកពិភាក្សាអំពីមូលហេតុនៃការបាត់បង់ និងរេចរឹលព្រៃឈើនៅកម្ពុជា ព្រមទាំងមធ្យោបាយត្រួតពិនិត្យពីមូលហេតុដែលនាំឱ្យបាត់បង់ និងរេចរឹលព្រៃឈើនានាទាំងនោះ
- វេទិកាជជែកពិភាក្សា នឹងពិចារណាថាតើមូលហេតុចំបងទាំងនោះជាបញ្ហាសង្គម ឬក៏ជាបញ្ហាសេដ្ឋកិច្ច
- និស្សិតពីសកលវិទ្យាល័យភូមិន្ទភ្នំពេញ នឹងការពារអំពីមូលហេតុសង្គម តទល់ជាមួយនឹងនិស្សិតមកពីសកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលការពារបញ្ហាសេដ្ឋកិច្ច
- កិច្ចប្រជុំណែនាំតម្រង់ទិស នឹងត្រូវបានរៀបចំឡើងដោយលេខាធិការដ្ឋានរេដបូកសម្រាប់ទាំងពីរភាគី មុនពេលកម្មវិធី។

### ឃ. សង្ខេប (៨នាទី)

ម្ចាស់កម្មវិធី នឹងសម្ភាស លោក អ៊ុយ កាម៉ាល សួរនាំគាត់ឱ្យសង្ខេបចំណុចសំខាន់ៗ ពីវេទិកាជជែកពិភាក្សា ហើយលើកជាយោបល់ឡើងអំពីថាតើសាធារណជន អាចកែប្រែវាបានយ៉ាងណា។

## កម្មវិធីទី៣៖ សកម្មភាពរេដបូក តើយើងអាចធ្វើអ្វីបានខ្លះនៅថ្នាក់ជាតិ និងក្រោមជាតិ

### ក. សេចក្តីផ្តើម (៦នាទី)

- មតិចាប់ផ្តើមដោយម្ចាស់កម្មវិធី៖ នៅក្នុងកម្មវិធីមុនៗ យើងបានរៀនសូត្រអំពីមូលហេតុដែលត្រូវការរេដបូក ហើយថាតើវាអាចជួយដោះស្រាយបញ្ហាបាត់បង់ និងរេចរឹលព្រៃឈើបានយ៉ាងដូចម្តេច។ នៅក្នុងកម្មវិធីថ្ងៃនេះ យើងនឹងវែកញែកថាតើវាមានន័យពិតប្រាកដយ៉ាងដូចម្តេច។
- បញ្ចាំងវីដេអូបង្ហាញអំពីការបាត់បង់ និងរេចរឹលព្រៃឈើ ដោយមានបទអធិប្បាយពន្យល់ពីភាពខុសគ្នារវាងការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ។

### ខ. សំណួរ ចំលើយ (១៥នាទី)

- ម្ចាស់កម្មវិធីនឹងលើកសំណួរដល់លោក យុន វឌ្ឍនា

<u>សំណួរទី១៖ យើងបានជ្រាបអំពីមូលហេតុដែលធ្វើឱ្យបាត់បង់ និងរេចរឹលព្រៃឈើ តើយើងអាចដោះស្រាយបញ្ហាបាននេះយ៉ាងដូចម្តេច?</u>

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- ដូចយើងបានឃើញអំពីមូលហេតុនៃការបាត់បង់ និងរេចរឹលព្រៃឈើ គឺកើតឡើងដោយចលករនានា ហើយវាកើតឡើងនៅតាមទីកន្លែងជាក់លាក់ មូលហេតុនៃការបាត់បង់ និងរេចរឹលព្រៃឈើ គឺតែងតែកើតឡើងពីបញ្ហារួមគ្នានៃចលករទាំងនោះ។ ដូច្នេះដំណោះស្រាយ គឺក៏ត្រូវតែមានច្រើនផ្សេងៗគ្នាដែរ។ ឧទាហរណ៍៖ លោកអ្នកអាចជួយទប់ស្កាត់ភ្លើងឆេះព្រៃ ឬក៏ ការកាប់ឈើខុសច្បាប់ តាមរយៈការងារដើរល្បាតព្រៃ ប៉ុន្តែការងារនេះត្រូវការកម្រិតណា នរណាជាអ្នកទទួលខុសត្រូវ ហើយនៅទីកន្លែងណាដែលត្រូវការដើរល្បាត ដែលសកម្មភាពទាំងអស់នេះត្រូវរៀបចំឡើងដោយពិស្តារនៅនឹងកន្លែង។

<u>សំណួរទី២៖ តើនរណាត្រូវទទួលការងារដោះស្រាយបញ្ហាទាំងនេះ? រដ្ឋាភិបាល ឬ សាធារណជន?</u>

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- យើងត្រូវការទាំងពីរ។ ប្រកដណាស់ថាភ្នាក់ងាររដ្ឋាភិបាល ដូចជា រដ្ឋបាលព្រៃឈើ និង រដ្ឋបាលជលផល និងក្រសួងបរិស្ថាន មានការទទួលខុសត្រូវលើតំបន់ព្រៃទាំងនេះ ប៉ុន្តែដោយសារទំហំបញ្ហាដែលកើតឡើង ដំណោះស្រាយដែលជោគជ័យ គឺត្រូវការកិច្ចសហការរវាងភ្នាក់ងាររដ្ឋាភិបាលនានា និងសាធារណជន ជាពិសេស អ្នកទាំងឡាយដែលរស់នៅក្នុង និងនៅតំបន់ជុំវិញព្រៃឈើ។
- ប្រសិនបើយើងក្រលេកមើលករណីជោគជ័យមួយចំនួន នៅបណ្តាប្រទេសមួយចំនួន ស្ទើរគ្រប់ករណីទាំងអស់ គឺកត្តាជោគជ័យកើតឡើងតាមរយៈភាពជាដៃគូរវាងរដ្ឋាភិបាល និងសាធារណជន។ ឧទាហរណ៍៖ ប្រទេសឥណ្ឌូនេស៊ី តំបន់ព្រៃរងទឹកភ្លៀងដ៏ធំដែលស្ថិតក្រោមការគំរាមគំហែងយ៉ាងធ្ងន់ធ្ងរនោះ ត្រូវបានការពារអភិរក្សតាមរយៈកិច្ចសហការរវាងរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងកសិករតាមមូលដ្ឋាន ដោយប្រើប្រាស់វិធីសាស្ត្របច្ចេកទេសកសិកម្មប្រកបដោយនិរន្តភាពជាងមុន និងកសាងការគាំទ្រពីសហគមន៍ក្នុងការងារអភិរក្ស។ ប៉ុន្តែ នៅមានដៃគូដទៃទៀត ត្រូវចូលរួមក្នុងកិច្ចការនេះដែរ ដូចជា ដន្ត្រីករ អ្នកដឹកនាំសាសនា ដែលដើរតួសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មាន។
- នៅប្រទេសនេប៉ាល់ តំបន់ព្រៃទំនាបដ៏ធំមួយចំនួន ត្រូវបានអភិរក្សដោយមានការចូលរួមគ្រប់គ្រងយ៉ាងសកម្មពីសហគមន៍ក្នុងតំបន់។ ការធ្វើឱ្យមានជីវភាពរស់នៅតាមជនបទសម្បូរបែប ដើម្បីកាត់បន្ថយការពឹងផ្អែកលើធនធានព្រៃឈើ ក៏បានចូលរួមចំណែកក្នុងការការពារព្រៃឈើផងដែរ។
- នៅកម្ពុជា យើងមានឧទាហរណ៍ប្រហាក់ប្រហែលគ្នាដែរ ដូចជា ការលើកទឹកចិត្តប្រជាជនក្នុងតំបន់ ការបង្កើតសហគមន៍ព្រៃឈើ ការពឹងអាស្រ័យមេដឹកនាំសាសនា និងតន្ត្រីករ ដើម្បីជួយផ្សព្វផ្សាយសារសំខាន់ៗ ប៉ុន្តែយើងត្រូវការបង្កើនការងារទាំងនេះថែមទៀត ដើម្បីធានាថាវាមានប្រសិទ្ធភាពខ្ពស់ ក្នុងការផ្តោតលើការអភិរក្សព្រៃឈើក្នុងតំបន់ដែលមានលក្ខណៈស្មុគស្មាញ។

<u>**សំណួរទី៣៖ លោកបាននិយាយអំពីសហគមន៍ព្រៃឈើ សូមជួយបកស្រាយបន្ថែមបន្តិចទៀតបានទេ?**</u>

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- o សហគមន៍ព្រៃឈើ គឺជាតំបន់ព្រៃឈើដែលមានកិច្ចព្រមព្រៀងមួយរវាងសហគមន៍ក្នុងតំបន់ជាមួយរដ្ឋាភិបាល ហើយដែលសហគមន៍ព្រៃឈើ មានតួនាទីទទួលខុសត្រូវក្នុងការគ្រប់គ្រងព្រៃឈើ និងអាចទទួលបានផលប្រយោជន៍ផលិតផលព្រៃឈើ។ នាពេលថ្មីៗនេះ យើងមានសហគមន៍ច្រើនជាង ៤០០ នៅកម្ពុជា គ្របដណ្តប់លើផ្ទៃដី xxx ហិចតា ហើយគោលដៅរបស់យើង គឺឈានទៅដល់ ២លានហិចតា គឺប្រហែលជា២០%នៃផ្ទៃដីព្រៃឈើសរុប។
- o ប៉ុន្តែកម្ពុជា បន្ថែមពីលើសហគមន៍ព្រៃឈើ យើងក៏មានប្រភេទសហគមន៍ដទៃទៀតដែលគ្រប់គ្រងធនធានធម្មជាតិ ដូចជា សហគមន៍ជលផល ដែលសហគមន៍នេះ គឺពឹងផ្អែកលើព្រៃកោងកាង ឬ ព្រៃលិចទឹក ដោយសារព្រៃលិចទឹកទាំងនេះជាជម្រក សម្រាប់ត្រី និងសត្វសមុទ្របន្តពូជ។ យើងក៏មានសហគមន៍តំបន់ការពារដែលនៅជុំវិញតំបន់ការពារ មានទីតាំងនៅជុំវិញតំបន់ការពារ ហើយភាគច្រើនស្ថិតនៅក្នុងតំបន់ព្រៃ។
- o បទពិសោធរបស់យើងជាមួយសហគមន៍ព្រៃឈើគឺនៅមានកម្រិត ហើយយើងរៀនសូត្រពីបណ្តាប្រទេសដទៃទៀត ដើម្បីធ្វើឱ្យមានភាពប្រាដកប្រជា មិនត្រឹមតែការអភិរក្សព្រៃឈើ ប៉ុន្តែក៏ត្រូវផ្តល់ជាវិភាគទានក្នុងការធានានិរន្តភាពជីវភាពរស់នៅរបស់ប្រជាជនដែលភាគច្រើននៃពួកគាត់ជាអ្នកទាល់ក្រ។

**អ្នកកាន់កម្មវិធី៖ សូមអរគុណចំពោះសេចក្តីពន្យល់ដ៏ក្បោះក្បាយ។ យើងមានខ្សែវីដេអូខ្លីអំពីសហគមន៍ព្រៃឈើនៅខេត្តឧត្តមានជ័យ ដែលនិយាយអំពីបទពិសោធន៍របស់ពួកគាត់ក្នុងការអភិរក្សព្រៃឈើ។**

## គ. សំភាសន៍ជាមួយអង្គការមិនមែនរដ្ឋាភិបាល និងតំណាងសហគមន៍ (១៥នាទី)

អាចប្រើប្រាស់វីដេអូពីអង្គការ PACT ដែលសម្ភាសជាមួយសមាជិកសហគមន៍នៅខេត្តឧត្តមានជ័យ និងការសម្ភាសជាមួយមន្ត្រីជំនាញពីដៃគូនៃអង្គការមិនមែនរដ្ឋាភិបាល ដូចជា លោក យាង ដូណាល់ និង លោក គឹម ណារ៉ុង

## ឃ. ធ្វើការសរុប (៣នាទី)

អ្នកកាន់កម្មវិធី អញ្ជើញភ្ញៀវនានាឱ្យផ្តល់មតិចុងក្រោយ សង្ខេបសារគន្លឹះៗ ផ្សព្វផ្សាយអំពីកម្មវិធីបន្ទាប់។

## កម្មវិធីទី៤ ៖ ការចំណាយ និងផលប្រយោជន៍ពីរេដបូក

### ក. សេចក្តីផ្តើម (៦នាទី)

- សារណែនាំពីអ្នករៀបចំកម្មវិធី
- បញ្ចាំងវីដេអូឃ្លីបនៃកិច្ចសម្ភាសជាមួយអ្នកជំនាញ និងវីដេអូខ្លីៗពីតាមបណ្តាខេត្តគោលដៅនានា

### ខ. សំណួរ និងចម្លើយ (២០នាទី)

- អ្នករៀបចំកម្មវិធី នឹងសួរសំណួរបន្តបន្ទាប់ទៅកាន់ ឯកឧត្តមបណ្ឌិត ជា សំអាង

<u>សំណួរទី១៖ យើងធ្លាប់បានឮចមកហើយអំពីរេដបូក និងថាតើកម្ពុជាអាចទទួលបានការទូទាត់សម្រាប់ការកាត់បន្ថយការបាត់បង់ព្រៃឈើដោយរបៀបណា និងតើវារួមចំណែកយ៉ាងដូចម្តេចដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុ? តើឯកឧត្តមអាចជម្រាបទូរទស្សនិកជនបន្ថែមអំពីការចំណាយ និងផលប្រយោជន៍បានពីរេដបូក បានឬទេ?</u>

ចំលើយ (ចំនុចដែលត្រូវពន្យល់)៖

- បាទ ជាបឋមប្រសិនបើយើងផ្តោតទៅលើការចំណាយ យើងអាចបែងចែកការចំណាយជាប្រភេទផ្សេងៗពីគ្នា។ ដំបូងគេបង្អស់ គឺមានតម្លៃសម្រាប់ការធ្វើសកម្មភាពជាក់ស្តែង នេះអាចជាការចំណាយសម្រាប់យាមល្បាត ឬ ការចំណាយនៃការវិនិយោគក្នុងការធ្វើចង្ក្រានប្រសិទ្ធភាព ឬ ការចំណាយសម្រាប់ត្រួតពិនិត្យប្រសិទ្ធភាពនៃលំហូរឈើ ទៅនឹងការកាប់ឈើខុសច្បាប់។
- បន្ទាប់មកទៀត គឺការចំណាយទៅលើការចូលរួមក្នុងយន្តការរេដបូកអន្តរជាតិ។ យើងចាំបាច់ត្រូវមានការត្រួតពិនិត្យ និងរាយការណ៍អំពីវិសាលភាពនៃធនធានព្រៃឈើ ដើម្បីអាចបញ្ជាក់ថាយើងពិតជាអាចកាត់បន្ថយការកាប់បំផ្លាញព្រៃឈើបាន។
- ចុងក្រោយ យើងអាចនិយាយពីតម្លៃឱកាស។ នេះគឺជាការខុសគ្នាបន្តិចពីការចំណាយលើសកម្មភាពពីរខាងលើ ហើយវាមានន័យថាការចំណាយនៅពេលដែលយើងមិនបានធ្វើការកាប់បំផ្លាញព្រៃឈើ និងមិនប្រើប្រាស់ដីសម្រាប់ធ្វើអ្វីមួយផ្សេងទៀត។ វា

ប្រហែលជាមានការលំបាកបន្តិចក្នុងការយល់ ប៉ុន្តែសូមពិចារណាថាយើងមិនអាចមានព្រៃឈើ និងស្រូវអង្ករនៅលើផ្ទៃដីតែមួយ ឬ អ្វីមួយផ្សេងទៀតបានទេ។ ហើយប្រសិនបើយើងសម្រេចចិត្តដើម្បីរក្សាព្រៃឈើ ហើយមិនគិតពីការធ្វើស្រែបានស្រូវអង្ករ ពេលនោះយើងអាចនិយាយអំពីប្រាក់ចំណូលសុទ្ធ ដែលមានសក្តានុពលពីស្រូវអង្ករ គឺជាតម្លៃឱកាសរបស់យើង។ វាជាការលំបាកបន្តិចក្នុងការប៉ាន់ស្មាន ព្រោះយើងមិនដឹងពីតម្លៃស្រូវអង្ករនៅឆ្នាំក្រោយ និងឆ្នាំក្រោយៗទៀតបានទេ ហើយប្រហែលជាយើងមិនដឹងតម្លៃនៃការផលិតស្រូវអង្ករ ឬ យើងមិនប្រាកដថាគុណភាពដី និងស្រូវអង្ករប៉ុន្មានដែលយើងអាចផលិតបាន ។ល។ ប៉ុន្តែ ចូរគិតស្រមៃថា យើងរកឃើញមាសជាច្រើននៅខាងក្រោមផ្ទៃដីព្រៃឈើ។ ក្នុងករណីនេះ តម្លៃឱកាសនៃការមិនបង្កើតអណ្តូងរ៉ែមាសមួយនឹងមានថ្លៃខ្ពស់ ហើយប្រហែលជាប្រទេសទាំងអស់នឹងសម្រេចចិត្តកាប់ព្រៃឈើ រួចបង្កើតអណ្តូងរ៉ែមាសមួយជំនួសវិញមិនខាន។

**<u>សំណួរទី២ ៖ វាហាក់ដូចជាស្មុគស្មាញខ្លាំងណាស់។</u>**

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- ការចំណាយទៅលើការធ្វើសកម្មភាពនានាមិនស្មុគស្មាញខ្លាំងនោះទេ ហើយការរៀបចំផែនការប្រើប្រាស់ដីធ្លីដ៏ល្អ គឺចាំចាច់ត្រូវគិតគូរពីរបៀបដែលយើងអាចប្រើប្រាស់ដីធ្លីអោយបានប្រសើរ រួមទាំងដីព្រៃឈើផងដែរ។

**<u>សំណួរទី៣៖ ចុះចំណែកឯផលប្រយោជន៍មានអ្វីខ្លះ?</u>**

**ចំលើយ (ចំនុចដែលត្រូវពន្យល់)**

- ព្រៃឈើផ្តល់ផលប្រយោជន៍ជាច្រើន ហើយប្រសិនបើយើងបាត់បង់ព្រៃឈើ ពេលនោះយើងនឹងបាត់បង់ផលប្រយោជន៍ទាំងអស់នោះ។ ផលប្រយោជន៍ទាំងអស់នោះ អាចជាឈើ និងអនុផលព្រៃឈើ ហើយផលប្រយោជន៍ខ្លះនោះ គឺសម្រាប់សហគមន៍មូលដ្ឋាន ពីព្រោះវាពិតជាពឹងផ្អែកយ៉ាងខ្លាំងលើកម្លាំងពលកម្ម ដើម្បីប្រមូលផលិតផល។
- ប៉ុន្តែ វាមានផលប្រយោជន៍ខ្លះ គឺសម្រាប់តំបន់ទាំងមូល។ ឧទាហរណ៍៖ ព្រៃឈើអាចស្តុកទឹកភ្លៀងបានល្អប្រសើរជាងដីវាល និងកាត់បន្ថយហានិភ័យនៃទឹកជំនន់ដែលហូរ

ទៅកាន់ទន្លេ។ ជាងនេះទៅទៀត វាអាចកាត់បន្ថយការហូរច្រោះ មិនដូច្នេះទេ វាអាចបង្កើតឲ្យមានបញ្ហាទៅដល់វារីអគ្គីសនី និងកន្លែងផ្សេងៗទៀត នៅផ្នែកខាងក្រោមនៃខ្សែទឹក។

- នៅកម្ពុជា ផលប្រយោជន៍នេះ គឺសំខាន់ខ្លាំងណាស់។ ព្រៃឈើអាចជួយបង្កើតលំហូរទឹក ដែលស្អាត និងប្រកបដោយស្ថេរភាព ដែលទាំងសហគមន៍មូលដ្ឋាន និងប្រជាជនរស់នៅផ្នែកខាងក្រោម បានទទួលផលប្រយោជន៍ពីវាផងដែរ។ លើសពីនោះទៀត ព្រៃឈើផ្ដល់ជាជម្រក និងម្លប់ និងជួយរក្សារមីក្រូអាកាសធាតុ ដែលមិនសូវក្ដៅខ្លាំង និងល្អប្រសើរសម្រាប់មនុស្ស និងសត្វ។
- បើនិយាយពីសត្វ ព្រៃឈើផ្ដល់ទីជម្រកយ៉ាងសំខាន់សម្រាប់សត្វ និងដោយហេតុនេះហើយ ពួកវាក៏មានតម្លៃសម្រាប់ទេសចរណ៍ផងដែរ។ ទេសចរជាច្រើន ចូលចិត្តទស្សនាព្រៃឈើធម្មជាតិ ទៅដើរកំសាន្តក្នុងព្រៃ និងអាចមើលសត្វទោច ឬ អ្វីៗផ្សេងទៀតដែលមានចំណាប់អារម្មណ៍។ សកម្មភាពដូចបានរៀបរាប់ទាំងអស់នេះ អាចផ្ដល់ការងារ និងប្រាក់ចំណូលផងដែរ សម្រាប់ប្រជាជនមូលដ្ឋាន។

<u>សំណួរទី៤៖ អ្វីទៅជាអនុផលព្រៃឈើ?</u>

ចំលើយ (ចំនុចដែលត្រូវពន្យល់)៖

- អនុផលព្រៃឈើ អាចជាទឹកឃ្មុំដែលប្រមូលបានពីព្រៃឈើ វាអាចជាជ័រឈើដែលយកចេញពីដើមឈើ វាអាចជាផ្សិត ហើយនិងមានអនុផលព្រៃឈើជាច្រើនផ្សេងទៀត។

<u>សំណួរទី៥៖ តើអ្វីទៅជាការទូទាត់សម្រាប់ការកាត់បន្ថយការបាត់បង់ព្រៃឈើ?</u>

ចំលើយ (ចំនុចដែលត្រូវពន្យល់)

- ការទូទាត់ពិតជាត្រូវបានយកមកពិចារណា ប៉ុន្តែយើងមិនដឹងថាតើថ្លៃប៉ុន្មានយើងនឹងទទួលបាននោះទេ។ ចំណុចពិចារណាមុនគេ អាចជាការវិភាគទៅលើការចំណាយដូចដែលខ្ញុំបានបញ្ជាក់ពីពេលមុន និងលើផលប្រយោជន៍ដែលមានស្រាប់ ហើយមើលថាតើតុល្យភាពនេះអាចចេញបានទេ និងពិចារណាមើលថាតើយើងត្រូវការនៅក្នុងលក្ខខណ្ឌនៃការទូទាត់ មុនពេលដែលព្រៃឈើល្អប្រសើរជាងអ្វីមិនមែនជាព្រៃឈើទេ។

- បន្ទាប់មកយើងពិចារណាថាវាពិតជាប្រាកដដែរឬអត់ ហើយយើងអាចប្រើប្រភេទព័ត៌មាននេះ ដើម្បីកំណត់លទ្ធផលជាអាទិភាពរបស់យើងបាន ហើយផ្តោតការយកចិត្តទុកដាក់ដំបូងទៅលើព្រៃឈើ ដែលអាចផ្តល់ផលប្រយោជន៍ជាច្រើនដល់យើង ។ល។

## គ. វគ្គសំណួរ និងចម្លើយ ពីអ្នកចូលរួម (១០នាទី)

សមាជិកអ្នកចូលរួម នឹងត្រូវបានអញ្ជើញឲ្យសួរសំណួរបន្តបន្ទាប់ ដែលត្រូវបានឆ្លើយដោយវាគ្មិន។ សំណួរ រំពឹងទុកមួយចំនួនអាចជា៖

- នរណានឹងធ្វើការសម្រេចចិត្ត ថាតើផលប្រយោជន៍ណាខ្លះសំខាន់ជាងផលប្រយោជន៍ផ្សេងទៀត?
- តើមានអ្វីកើតឡើង ប្រសិនបើការចំណាយនៃការអនុវត្តរេដបូក គឺធំជាងតម្លៃនៃផលប្រយោជន៍ដែលនឹងបានមក?
- តើមានវិធីណាដែលយើងអាចកាត់បន្ថយការចំណាយ និងបង្កើនផលប្រយោជន៍បាន?
- តើសហាគមន៍ដែលរស់នៅក្នុង និងក្បែរព្រៃឈើ អាចបញ្ចេញគំនិត ឬ យោបល់ទៅលើការចំណាយ និងផលប្រយោជន៍ បានដែរឬទេ?

## ឃ. សង្ខេបឡើងវិញ (៣នាទី)

អ្នករៀបចំកម្មវិធី អញ្ជើញភ្ញៀវឲ្យមានយោបល់បញ្ចប់សង្ខេបពីសារសំខាន់ៗពីកម្មវិធី និងផ្សព្វផ្សាយកម្មវិធីបន្ទាប់ទៀត។

## កម្មវិធីទី៥៖ លទ្ធផលដោយផ្អែកលើការអនុវត្ត រេដបូក

### ក. សេចក្តីផ្តើម (៦នាទី)

- សារណែនាំពីអ្នករៀបចំកម្មវិធី
- បញ្ចាំងវីដេអូ ស្តីពី ការវាស់វែង ការរាយការណ៍ និងការផ្ទៀងផ្ទាត់ និងការត្រួតពិនិត្យ

### ខ. សំណួរ និងចម្លើយ (២០នាទី)

ម្ចាស់កម្មវិធី នឹងសួរសំណួរបន្តបន្ទាប់ទៅកាន់លោក ឃន សារ៉េត /លោក ឡេង ជីវិន។

<u>សំណួរទី១៖ យើងបានឮរួចមកហើយអំពីរបៀបដែលប្រទេសកំពុងអភិវឌ្ឍ អាចទទួលបានការទូទាត់ ប្រសិនបើពួកគេទទួលបានជោគជ័យក្នុងការកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ ដែលនេះនាំឲ្យមានការរួមចំណែកដល់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ តើលោកអាចប្រាប់ពួកយើងបន្ថែមពីរបៀបដំណើរការនេះធ្វើទៅយ៉ាងដូចម្តេច?</u>

ចំលើយ (ចំនុចដែលត្រូវពន្យល់)៖

- រេដបូក គឺជាលទ្ធផលមូលដ្ឋាន ដែលមានន័យថា យើងត្រូវតែបង្ហាញពីលទ្ធផលដែលយើងសម្រេចបាន។ នៅក្នុងការអនុវត្តនេះ មានន័យថាយើងត្រូវការត្រួតពិនិត្យព្រៃឈើរបស់យើង ទាំងនៅក្នុងលក្ខខណ្ឌតើព្រៃឈើប៉ុន្មានដែលយើងមាន ព្រៃឈើប្រភេទអ្វីខ្លះ និងថាតើបរិមាណកាបូនប៉ុន្មានដែលវាមាន។

<u>សំណួរទី២៖ តើអ្នកធ្វើដូចម្តេចដើម្បីពិចារណាថា ប្រទេសមួយធំ និងមានព្រៃឈើនៅគ្រប់ខេត្ត?</u>

ចំលើយ (ចំនុចដែលត្រូវពន្យល់)៖

- វិសាលភាពព្រៃឈើគិតជាហិកតា អាចត្រូវបានប៉ាន់ប្រមាណដោយការមើលទៅលើរូបភាពផ្កាយរណប។ នេះគឺជាចំណុចមួយដែលបច្ចេកវិទ្យាថ្មី បានធ្វើឲ្យប្រសើរឡើង នាពេលថ្មីៗនេះ ហើយរូបភាពផ្កាយរណបជាច្រើន អាចទទួលបានដោយមិនចំណាយលុយ។

ប្រភេទព្រៃឈើផ្សេងៗ មានដូចជា ព្រៃកោងកាង ព្រៃបៃតងជានិច្ច ឬ ក្នុងករណីភាគច្រើន ចំការព្រៃ អាចត្រូវបានរកឃើញដោយប្រើរូបភាពផ្កាយរណប។

- ដឹងបរិមាណកាបូន គឺមានការលំបាកជាង ហើយដែលបច្ចុប្បន្នយើងកំពុងរៀបចំផែនការសារពើភ័ណ្ឌព្រៃឈើជាតិមួយ ដែលនេះមានន័យថា យើងនឹងចុះមើលសំណាកព្រៃឈើតាមឡូត៍ និងកំណត់អត្តសញ្ញាណ និងវាស់វែងដើមឈើ។ នេះគឺជាភារកិច្ចចំបង និងវាចំណាយពេលច្រើន ហើយថ្លៃជាងការមើលដោយរូបភាពផ្កាយរណប ប៉ុន្តែវាអាចមានសារប្រយោជន៍ សម្រាប់ការងារផ្សេងទៀតជាជាងរេដូកបូក។

<u>សំណួរទី៣៖ ដូច្នេះតើលទ្ធផលដែលសម្រេចបានត្រូវ បានប៉ាន់ប្រមាណដោយផ្អែកលើការវាស់វែងមែនទេ?</u>

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- ត្រូវហើយ ប៉ុន្តែវាមិនដូចនោះទាំងអស់ទេ។ យើងគួរចាំបាច់មានអ្វីៗ ដើម្បីវាស់វែងធៀបនឹងលទ្ធផល។ យើងហៅ ការវាស់វែង ថាជា កម្រិតយោង។ កម្រិតយោង គឺជាការប៉ាន់ប្រមាណការបាត់បង់ព្រៃឈើក្នុងពេលកន្លងមក ដោយវាស់បរិមាណ $CO_2$ គិតជាតោនក្នុងមួយឆ្នាំ ហើយលទ្ធផលនឹងត្រូវបានវាស់វែង $CO_2$ ជាតោនក្នុងមួយឆ្នាំ។

<u>សំណួរទី៤៖ ហេតុអ្វីបានជាអ្នកប្រើ $CO_2$ ជាតោនក្នុងមួយឆ្នាំ?</u>

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- $CO_2$ គឺជាឧស្ម័នផ្ទះកញ្ចក់ និងនៅថ្នាក់សកល ការបាត់បង់ព្រៃឈើរួមចំណែកប្រហែល ១០% នៃការបំភាយ $CO_2$ សរុបជាសកល។ នេះគឺជាអ្វីដែលយើងអាចមើលព្រៃឈើរបស់យើងមានទំនាក់ទំនងផ្ទាល់ជាមួយការប្រែប្រួលអាកាសធាតុ និងជាមូលហេតុដែលថាកាត់បន្ថយការបាត់បង់ព្រៃឈើ អាចជួយកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

<u>សំណួរទី៥ ៖ តើមានបរិមាណ $CO_2$ ប៉ុន្មានក្នុង១ហិតតាព្រៃឈើ?</u>

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- នេះអាស្រ័យទាំងស្រុងទៅលើព្រៃឈើ និងបរិមាណកាបូនដែលស្តុកទុកក្នុងព្រៃឈើ។ វាអាចមានប្រមាណពី ៣០០តោន ទៅដល់ ១០០០តោន $CO_2$ ក្នុង ១ហិកតា។ នេះជា

មូលហេតុដែលយើងចាំបាច់ដឹងបន្ថែមអំពីប្រភេទព្រៃឈើ ពីព្រោះមានភាពខុសគ្នាជាច្រើនក្នុងបរិមាណកាបូន រវាងប្រភេទព្រៃឈើផ្សេងៗគ្នា។

<u>**សំណួរទី៦៖ តើនរណាទទួលខុសត្រូវលើការត្រួតពិនិត្យ?**</u>

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- នេះជាការខិតខំប្រឹងប្រែងរួមរបស់រដ្ឋាភិបាល។ យើងបានបង្កើតក្រុមបច្ចេកទេសមួយដើម្បីធ្វើការលើរបៀបបង្កើតកម្រិតយោង ហើយក្រុមនេះនឹងពិចារណាផងដែរ អំពីរបៀបដែលប្រព័ន្ធត្រួតពិនិត្យព្រៃឈើ អាចត្រូវបានបង្កើតឡើង។

<u>**សំណួរទី៧៖ តើនរណានឹងទទួលយករបាយការណ៍អំពីលទ្ធផលសម្រេចបានរបស់អ្នក?**</u>

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- អនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) បានបង្កើតឲ្យមានដំណើរការមួយ សម្រាប់វាយតម្លៃកម្រិតយោងដែលបានលើកឡើង និងជាដំណើរការមួយសម្រាប់រាយការណ៍លទ្ធផលទៅដល់កិច្ចប្រជុំ។ ព័ត៌មានទាំងអស់នេះ នឹងបានដល់សាធារណជនប្រើប្រាស់។

<u>**សំណួរទី៨៖ តើពេលណាអ្នកនឹងរាយការណ៍ពីលទ្ធផលបឋម?**</u>

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- យើងរំពឹងថានឹងដាក់ជូនកម្រិតយោង ដែលស្នើឡើងនៅឆ្នាំក្រោយ និងក្នុងពេលជាមួយគ្នា យើងនឹងរៀបចំបង្កើតឲ្យមានប្រព័ន្ធត្រួតពិនិត្យ ដែលនឹងផ្តល់ឲ្យយើងនូវរបាយការណ៍អំពីលទ្ធផល។

**គ. វគ្គសំណួរ និងចម្លើយ ពីអ្នកចូលរួម (១០នាទី)**

សមាជិកអ្នកចូលរួមទាំងអស់ នឹងត្រូវបានអញ្ជើញឲ្យសួរសំណួរបន្តបន្ទាប់ ដែលនឹងឆ្លើយដោយវាគ្មិន។ សំណួររំពឹងទុកមួយចំនួនអាចជា៖

- តើអ្នករាល់គ្នាអាចមានទំនុកចិត្តលើភាពពិតប្រាកដលើព័ត៌មាន ដែលបានរាយការណ៍យ៉ាងដូចម្តេច?
- តើមានអ្វីកើតឡើងប្រសិនបើលទ្ធផលវិជ្ជមាន អាចត្រូវទទួលបានក្នុងផ្នែកមួយនៃប្រទេស ប៉ុន្តែការបាត់បង់ព្រៃឈើកើនឡើងនៅកន្លែងផ្សេងទៀត?
- តើមានតែរដ្ឋាភិបាលតែប៉ុណ្ណោះ ដែលអាចចូលរួមក្នុងការប្រមូលទិន្នន័យមែនទេ?

**ឃ. សង្ខេបឡើងវិញ (៣នាទី)**

អ្នករៀបចំកម្មវិធី អញ្ជើញវាគ្មិន/ភ្ញៀវកិត្តិយសឲ្យផ្តល់នូវយោបល់ចុងក្រោយ សង្ខេបសារសំខាន់ៗពីកម្មវិធី និងផ្សព្វផ្សាយកម្មវិធីបន្តនាពេលក្រោយទៀត។

## កម្មវិធីទី៦៖ ការបែងចែកផលប្រយោជន៍

### ក. សេចក្ដីផ្ដើម (៦នាទី)

- សារណែនាំពីអ្នករៀបចំ
- បញ្ចាំងវីដេអូអំពីការលើកទឹកចិត្ត

### ខ. សំណួរចម្លើយ (២០នាទី)

អ្នករៀបចំកម្មវិធី នឹងសួរសំណួរដូចបន្តបន្ទាប់ទៅកាន់លោក ឡុង រតនៈកុមារ។

*<u>សំណួរទី១៖ សូមអ្នកពន្យល់អ្វីទៅជាការបែងចែកផលប្រយោជន៍?</u>*

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- មូលដ្ឋានរបស់យន្តការរេដបូក គឺថាកម្ពុជាអាចទទួលបានផលប្រយោជន៍ពីការទូទាត់ពីប្រទេសអភិវឌ្ឍ ប្រសិនបើខ្លួនទទួលបានជោគជ័យក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើ និងជោគជ័យក្នុងការអភិរក្ស និងគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព។
- ប៉ុន្តែច្បាស់លាស់ណាស់ អ្នកណាដែលសមនឹងទទួលបានផលប្រយោជន៍ច្រើន គឺជាអ្នកដែលបានខិតខំប្រឹងប្រែងចូលរួម ដល់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ដូច្នេះ វាចាំបាច់ត្រូវមានប្រព័ន្ធមួយ ដែលតាមរយៈនេះអាចពិចារណាថា នរណាដែលមានគុណសម្បត្តិ ដើម្បីទទួលបានផលប្រយោជន៍ និងធានាថាការទូទាត់ដែលទទួលបានពីប្រទេសអភិវឌ្ឍ ត្រូវបានប្រើដើម្បីផ្តល់ផលប្រយោជន៍ទាំងអស់នោះ។

*<u>សំនួរទី២៖ អ្នកនិយាយអំពីការទូទាត់ពីប្រទេសអភិវឌ្ឍ ដូច្នេះយើងកំពុងនិយាយអំពីផលប្រយោជន៍ជាសាច់ប្រាក់ តើពិតទេ?</u>*

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- ទេ មិនចាំបាច់ទេ។ ទោះជាការទូទាត់ដែលទទួលបានពីប្រទេសអភិវឌ្ឍ នឹងជាទម្រង់សាច់ប្រាក់ក្តី ប្រភេទនៃផលប្រយោជន៍បានទៅដល់អ្នកពាក់ព័ន្ធ អាចមានភាពខុសគ្នា និងចាំបាច់ឆ្លុះបញ្ចាំងសេចក្តីប្រាថ្នារបស់ពួកគេ។

- ឧទាហរណ៍៖ សហគមន៍ដែលរស់នៅក្នុង និងក្បែរព្រៃឈើ អាចប្រហែលទទួលបានផលប្រយោជន៍ក្នុងទម្រង់មូលនិធិភូមិ ដែលអាចត្រូវបានប្រើសម្រាប់គម្រោងផ្សេងៗ ដើម្បីកែលម្អសង្គម ឬ ពួកគេចង់ទទួលបានវគ្គបណ្តុះបណ្តាលក្នុងការបង្កើនជីវភាពថ្មី ឬបច្ចេកទេសកសិកម្មល្អៗ ឬ ពួកគេចង់ឃើញមានការកែលម្អអាគារសិក្សា។ ប្រសិនបើអ្នកចង់បានប្រជាជន ដើម្បីសហការជាមួយអ្នក ពេលនោះអ្នកច្បាស់ជាចាំបាច់ផ្តល់ឲ្យពួកគេនូវផលប្រយោជន៍ផ្សេងៗ ដែលពួកគេពិតជាចង់បាន។ ប្រសិនបើពួគគេចង់បានរបស់អ្វីមួយ ហើយអ្នកបែរជាផ្តល់ឲ្យរបស់ផ្សេង ពួកគេទំនងជាមិនខិតខំធ្វើការជាមួយអ្នកទេ។
- ដូច្នេះ ប្រព័ន្ធបែងចែកផលប្រយោជន៍មានប្រសិទ្ធភាព គឺចាំបាច់យកបំណងប្រាថ្នារបស់អ្នកពាក់ព័ន្ធផ្សេងៗមកពិចារណា ហើយអាចផ្តល់ឲ្យប្រភេទនៃផលប្រយោជន៍ផ្សេង ដែលពួគគេចង់បាន។

<u>សំណួរទី៣៖ ប៉ុន្តែ តើនេះពិតជានឹងកើតឡើងមែនទេ? បទពិសោធន៍កន្លងមកនៅកម្ពុជាធ្វើឲ្យមានការព្រួយបារម្ភណ៍ថា ផលប្រយោជន៍ទាំងអស់តាមពិតទៅនឹងធ្លាក់ទៅដល់មនុស្សដែលមានលទ្ធភាពខ្ពស់ និងជាពិសេស ប្រជាជនក្រីក្រនឹងមិនបានទទួលអ្វីសោះ។</u>

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- យើងចាំបាច់ទទួលស្គាល់ថា ហានិភ័យដូចនេះពិតជាមាន។ ប៉ុន្តែ វាមានហេតុផលសំខាន់ៗចំនួនបី ដែលយើងអាចធានាថាបញ្ហាដូចនោះមិនអាចធ្វើទៅបានទេក្នុងរេដបូក។ ជាបឋម យើងដឹងថា វានឹងមិនអាចទៅរួចទេដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នដោយគ្មានការជួយ និងកិច្ចសហការពីអ្នកពាក់ព័ន្ធជាច្រើន ហើយពួកគេនឹងតម្រូវឲ្យមានសំណងសមស្របសម្រាប់ការខិតខំប្រឹងប្រែងរបស់ពួកគេ។ ប្រសិនបើផលប្រយោជន៍ទាំងអស់ ត្រូវបានឆក់យកដោយមនុស្សដែលមានលទ្ធភាពខ្ពស់នោះ យើងនឹងមិនអាចជោគជ័យក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នបានទេ ហើយការទូទាត់នឹងមិនអាចធ្វើទៅកើត និងលឿនបានដែរ។
- ទីពីរ ពីព្រោះកម្ពុជាមានកត្តាព្វកិច្ច ដើម្បីរាយការណ៍អំពីការការពារសុវត្ថិភាព ដែលដាក់ចូលក្នុងរេដបូក ប្រសិនបើការអនុវត្តមានអំពើពុករលួយនោះ ពួកគេនឹងបានដឹងដោយសហគមន៍អន្តរជាតិយ៉ាងឆាប់រហ័ស។ ទីបី យើងបានបង្កើតយន្តការរួចមកហើយដើម្បីធានាឲ្យមានតម្លាភាព និងការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ឲ្យបានទូលំទូលាយ

ក្នុងរេដបូក ជាងគំនិតផ្តួចផ្តើមការគ្រប់គ្រងព្រៃឈើពីមុន។ យើងនឹងពិភាក្សាបន្ថែមអំពីកម្មវិធីអនាគត ដូចនេះការអនុវត្តដែលមានអំពើពុករលួយនឹងពិបាកលាក់បាំងខ្លាំងណាស់។

**សំណួរទី៤៖ តើប្រព័ន្ធនេះនឹងធ្វើការយ៉ាងដូចម្តេចតាមការអនុវត្ត?**

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- យើងកំពុងធ្វើការបញ្ចប់ នេះគឺជាបញ្ហាប្រឈមមួយសម្រាប់កម្ពុជា និងជាការពិបាកមួយ ដូចនេះយើងចង់ឲ្យប្រាកដថាយើងធ្វើវាបានត្រឹមត្រូវ។
- ប៉ុន្តែជាក់ស្តែង ប្រព័ន្ធនេះនឹងត្រូវបានពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនៅមូលដ្ឋាន។ នេះគឺជាជំហានចាំបាច់មួយ ពីព្រោះប្រសិនបើអ្នកនឹងរៀបចំផែនការធ្វើអ្វីមួយ ដើម្បីកាត់បន្ថយការបាត់បង់ព្រៃឈើ ឬ ការរេចរឹលព្រៃឈើ អ្នកចាំបាច់ពិភាក្សាផែនការទាំងនោះជាមួយប្រជាជនមូលដ្ឋានដែលអ្នកត្រូវការពួកគេឲ្យចូលរួម និងជួយអ្នក។
- ដើម្បីឲ្យមានការពិភាក្សាដែលមានលក្ខណៈគ្រប់គ្រាន់មួយ អ្នកពាក់ព័ន្ធនៅមូលដ្ឋាននឹងចង់ស្គាល់នូវអ្វីដែលពួកគេរំពឹង និងទទួលបានមកវិញជាថ្នូរនឹងការជួយរបស់ពួកគេ។ ដូច្នេះ ការពិគ្រោះយោបល់ទាំងនោះ នឹងមានប្រសិទ្ធភាពជាទម្រង់ការចរចារមួយដើម្បីឲ្យស៊ីជាមួយនឹងសកម្មភាពដែលបានលើកឡើងជាមួយផលប្រយោជន៍ទាំងឡាយ។
- ពេលដែលកិច្ចព្រមព្រៀងមួយបានសម្រាចហើយនោះ វានឹងត្រូវបានកត់ត្រាទុក។ ប៉ុន្តែគោលការណ៍សំខាន់ ដែលអាចអនុវត្តបានចំពោះរេដបូក គឺវាផ្អែកទៅលើការអនុវត្តជាមូលដ្ឋាន។ កម្ពុជានឹងមិនទទួលបានការទូទាត់ណាមួយទេ ប្រសិនបើវាមិនអាចកាត់បន្ថយឧស្ម័ន ហើយស្រដៀងគ្នានេះដែរ សហគមន៍មូលដ្ឋាននឹងទទួលបានតែផលប្រយោជន៍ដែលបានព្រមព្រៀងគ្នាប៉ុណ្ណោះ ប្រសិនបើពួកគេរួមចំណែកដល់សកម្មភាពដែលបានព្រមព្រៀង។ នេះមានន័យថា ក្នុងខណៈដែលផលប្រយោជន៍ខ្លះអាចត្រូវបានផ្តល់ឲ្យជាបន្ទាន់ រីឯផលប្រយោជន៍ផ្សេងទៀតនឹងត្រូវបានរក្សាទុកសិន រហូតដល់វាច្បាស់ថាសកម្មភាពទាំងនោះ កំពុងត្រូវបានចាប់ផ្តើមតាមការជាក់ស្តែង។

**<u>សំណួរទី៥៖ មានព័ត៌មានអវិជ្ជមានជាច្រើនអំពីបទពិសោធន៍របស់គម្រោងក្នុងខេត្តឧត្តរមានជ័យ។ ដូចនេះ ហេតុអ្វីបានជាមានភាពខុសគ្នាយ៉ាងនេះ?</u>**

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- បទពិសោធន៍ក្នុងខេត្តឧត្តរមានជ័យគឺជារឿងអកុសល ប៉ុន្តែយើងក៏ត្រូវការប្រើបទពិសោធន៍ដើម្បីរៀនសូត្រដែរ។ ដូច្នេះយើងអាចធ្វើបានល្អប្រសើរជាងមុនសម្រាប់រេដបូក។
- គម្រោងក្នុងខេត្តឧត្តរមានជ័យ បានព្យាយាមដើម្បីទទួលបានការទូទាត់ពីទីផ្សារកាបូនស្ម័គ្រចិត្ត។ បើទោះបីជាគោលដៅរបស់គម្រោងរេដបូក និងទីផ្សារកាបូនស្ម័គ្រចិត្តគឺដូចគ្នា ដែលមានឈ្មោះថា ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ រេដបូកគឺជាយន្តការខុសគ្នាឆ្ងាយពីនេះណាស់។
- ផ្នែកមួយនៃបញ្ហានៅខេត្តឧត្តរមានជ័យ ដែលទាក់ទងនឹងភាពជាម្ចាស់នៃការកាត់បន្ថយការបញ្ចេញឧស្ម័ន។ វាមិនអាចអនុវត្តបាននៅក្រោមរេដបូកទេ ដោយសារតែប្រតិបត្តិការកើតឡើងនៅថ្នាក់ជាតិ។
- បញ្ហាមួយទៀត គឺជាតម្រូវការសម្រាប់ទីផ្សារកាបូនស្ម័គ្រចិត្តនេះ បានធ្លាក់ចុះយ៉ាងខ្លាំងនៅគ្រាដែលគម្រោងខេត្តឧត្តរមានជ័យ បានត្រៀមខ្លួនរួចរាល់ហើយក្នុងការលក់ការកាត់បន្ថយការបំភាយឧស្ម័ន។ នេះជារឿងអកុសល។ ហើយបើទោះបីជាវាជាការឆាប់ពេកក្នុងការនិយាយ តើនឹងត្រូវមានការកាត់បន្ថយប៉ុន្មានតាមរយៈរេដបូក។ វាទំនងយ៉ាងខ្លាំងដែលការផ្តល់មូលនិធិនេះ នឹងត្រូវអាចជឿទុកចិត្តបានច្រើនជាងនេះ។
- ជាការពិតណាស់ ដរាបណាកម្ពុជាទទួលបានជោគជ័យក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័ន។

**គ. វគ្គសំណួរ និងចម្លើយ ពីអ្នកចូលរួម (១០នាទី)**

សមាជិកអ្នកចូលរួម នឹងត្រូវបានអញ្ជើញឲ្យសួរសំណួរបន្តបន្ទាប់ ដែលមានវាគ្មិនឆ្លើយ។ សំណួររំពឹងទុកមួយចំនួន អាចមានដូចខាងក្រោម៖

- នរណានឹងទទួលបន្ទុកក្នុងការបែងចែកផលប្រយោជន៍?
- ប្រសិនបើនរណាមួយមានអារម្មណ៍ថា ពួកគេមិនទទួលបាននូវអ្វីដែលពួកគេសមនឹងទទួលបាន តើពួកគេអាចលើកបញ្ហានេះដោយរបៀបណា?
- នរណានឹងសម្រេចចិត្ត ប្រសិនបើសហគមន៍មូលដ្ឋានកំពុងអនុវត្តសកម្មភាពនានាដែលពួកគេបានព្រមព្រៀងនោះ?
- តើផលប្រយោជន៍ទាំងនោះ អាចមានលំហូរលឿនយ៉ាងណា?

**ឃ. សង្ខេប (៣នាទី)**

អ្នករៀបចំកម្មវិធី អញ្ជើញភ្ញៀវផ្តល់យោបល់ចុងក្រោយ ដោយសង្ខេបសារសំខាន់ៗពីកម្មវិធី និងផ្សព្វផ្សាយកម្មវិធីបន្ទាប់ទៀត។

## កម្មវិធីទី៧៖ ការពារសុវត្ថិភាព

### ក. សេចក្តីផ្តើម (៦នាទី)

- សារណែនាំពីអ្នករៀបចំ
- បញ្ចាំងវីដេអូពីការការពារ និង FPIC

### ខ. សំណួរចម្លើយ (២០នាទី)

អ្នករៀបចំកម្មវិធីនឹងចោទសួរទៅកាន់លោក ឈុន ជីលុច

<u>សំណួរទី១៖ សូមលោកពន្យល់ តើមានការការពារសុវត្ថិភាពអ្វីខ្លះ ហើយហេតុអ្វីបានជាពួកវាមាន សារសំខាន់សម្រាប់រេដបូក?</u>

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- ដោយសារព្រៃឈើផ្តល់សេវាកម្មជាច្រើន និងដោយសារតែប្រជាជនពឹងផ្អែកលើសេវាកម្មនានា វាជាការចាំបាច់ដើម្បីធានាក្នុងការលើកកម្ពស់សេវាកម្មមួយ ដូចជា អភិរក្សកាបូន និងសេវាកម្មផ្សេងទៀតមិនចាំបាច់សម្របសម្រួលទេ។
- លើសពីនេះទៀត ដោយសារតែរេដបូកគឺជាយន្តការមួយតាមរយៈដែលតម្លៃនៃព្រៃឈើត្រូវបានធ្វើឲ្យប្រសើរឡើង។ វាមានហានិភ័យនៃអំពើពុករលួយមួយចំនួន ដែលនាំឱ្យមានអត្ថប្រយោជន៍របស់រេដបូក កំពុងទាញយកដោយបុគ្គលដែលមិនត្រូវបានផ្តល់សិទ្ធិឲ្យ។
- សម្រាប់ហេតុផលទាំងនេះ សហគមន៍អន្តរជាតិបានបញ្ជាក់ពីតម្រូវការ ដើម្បីធានាថា ខណៈជាប្រទេសដែលរៀបចំ និងអនុវត្តកម្មវិធីរេដបូក ពួកគេមិនត្រូវមានផលប៉ះពាល់អវិជ្ជមានទៅលើប្រជាជនដែលរស់នៅក្នុង និងនៅជុំវិញតំបន់ព្រៃឈើទេ ឬ ទៅលើសក្តានុពលសម្រាប់ព្រៃឈើ ដើម្បីផ្តល់សេវាកម្មបរិស្ថានផ្សេងទៀតទេ។

**សំណួរទី២ ៖ តើមានការការពារសុវត្ថិភាពមានអ្វីខ្លះ?**

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- ការចរចារអន្តរជាតិស្តីពី រេដបូកបានកំណត់ការពារសុវត្ថិភាពសរុបចំនួនប្រាំពីរ។ ការពារសុវត្ថិភាពខ្លះ ផ្តោតលើបញ្ហាគោលនយោបាយ ដូចជា ការធានាថាសកម្មភាពរេដបូកស្របទៅតាមផែនការទូលំទូលាយ សម្រាប់ការគ្រប់គ្រងព្រៃឈើរបស់ប្រទេស។ ការពារ

សុវត្ថិភាពផ្សេងទៀត ជាប់ទាក់ទងជាមួយបញ្ហាសង្គម ដូចជា ការធានាការចូលរួមពេញលេញ និងមានប្រសិទ្ធិភាពនៃភាគីពាក់ព័ន្ធទាំងអស់ និងគោរពសិទ្ធិរបស់ជនជាតិភាគតិច និងសហគមន៍មូលដ្ឋាន។ បន្ទាប់មកមានការការពារសុវត្ថិភាពទាក់ទងនឹងបញ្ហាបរិស្ថាន ដូចជា ការធានាថាសត្វព្រៃត្រូវបានអភិរក្ស ហើយសកម្មភាពដែលបានអនុវត្តនៅក្នុងទីតាំងមួយ មិនបណ្តាលឲ្យមានសកម្មភាពអវិជ្ជមាននៅក្នុងទីតាំងមួយផ្សេងទៀតទេ។ ឧទាហរណ៍៖ ប្រសិនបើកិច្ចខំប្រឹងប្រែងត្រូវបានធ្វើឡើង ដើម្បីកាត់បន្ថយការកាប់ឈើខុសច្បាប់នៅក្នុងតំបន់មួយ ប៉ុន្តែបែរជាមានលទ្ធផលដែលងាយក្នុងការកាប់ឈើកាន់តែច្រើន កើតមាននៅក្នុងទីតាំងមួយផ្សេងទៀត ពេលនោះគឺគ្មានផលប្រយោជន៍នោះទេ។

- ការការពារសុវត្ថិភាពមួយចំនួនទៀត មានលក្ខណៈទូលំទូលាយណាស់ ហើយចាំបាច់ត្រូវបំបែកទៅជាសកម្មភាពជាក់ស្តែងបន្ថែមទៀត។ ឧទាហរណ៍៖ ការចូលរួមពេញលេញ និងមានប្រសិទ្ធិភាពរបស់អ្នកពាក់ព័ន្ធទាំងអស់គ្របដណ្តប់បញ្ហាជាច្រើន ដូចជា ការធានាថា ភាគីពាក់ព័ន្ធ មានសំឡេងនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការអនុវត្តរេដបូក និងសិទ្ធិដើម្បីមានសេរីភាព អាទិភាព និងការយល់ព្រមដែលបានផ្តល់ដំណឹង។

<u>**សំណួរទី៣៖ តើអ្វីទៅជាសេរីភាព អាទិភាព និងការយល់ព្រមដែលផ្តល់ដំណឹង?**</u>

**ចំលើយ (ចំនុចដែលត្រូវពន្យល់) ៖**

- នេះសំដៅទៅលើសិទ្ធិរបស់ប្រជាជនដែលនឹងត្រូវបានជូនដំណឹងអំពីផែនការ ដើម្បីចាត់វិធានការដែលអាចប៉ះពាល់ដល់ធនធានដែលពួកគេមានសិទ្ធិ និងដើម្បីផ្តល់ការយល់ព្រមរបស់ពួកគេមុនពេលដែលសកម្មភាពទាំងនោះ ត្រូវបានចាប់ផ្តើម។ ឧទាហរណ៍ជាក់ស្តែងបំផុតនោះ គឺប្រសិនបើបុគ្គលម្នាក់ជាម្ចាស់ដីមួយកន្លែង ហើយរដ្ឋាភិបាលចង់ប្រើដីនោះ។ ឧទាហរណ៍៖ ដើម្បីសាងសង់ផ្លូវថ្មីមួយ បន្ទាប់មកម្ចាស់ដីមានសិទ្ធិពិភាក្សាអំពីផែនការនេះ និងដើម្បីផ្តល់ឲ្យ ឬ កាត់ទុកការយល់ព្រមរបស់គាត់ និងត្រូវបានសងសំណងវិញ ប្រសិនបើគាត់បានផ្តល់ការយល់ព្រមនោះ។
- ខណៈពេលដែលសេរីភាព អាទិភាព និងការព្រមព្រៀងដែលផ្តល់ដំណឹង (FPIC) គឺមានភាពច្បាស់លាស់ណាស់ នៅក្នុងករណីដូចតទៅនេះ។ វាក្លាយជារឿងពិបាកជាងមុនក្នុងករណីព្រៃឈើ ពីព្រោះតែជនជាតិភាគតិចជាច្រើន ឬ សហគមន៍មូលដ្ឋាន បានទាមទារសិទ្ធិដើម្បីមានព្រៃឈើ ឬ ប្របមូលផលពីព្រៃឈើ ប៉ុន្តែសិទ្ធិទាំងនេះមិនត្រូវ

បានធ្វើទៅផ្លូវការទេ ហើយដូច្នេះវាមិនតែងតែជាក់លាក់ទេនៅក្នុងលក្ខខណ្ឌនៃកន្លែងដែលពួកគេបានអនុវត្ត។

- ជាលទ្ធផលមានការដាក់សម្ពាធអន្តរជាតិ ទៅលើបណ្តាប្រទេសនានា ឲ្យអនុវត្តវិធីសាស្ត្រអភិរក្សទៅនឹងបញ្ហានេះ នៅពេលដែលរៀបចំផែនការរេដបូក និងដើម្បីអភិវឌ្ឍនីតិវិធីច្បាស់លាស់ និងយុត្តិធម៌ ដើម្បីអនុញ្ញាតជនជាតិភាគតិច និងសហគមន៍មូលដ្ឋាន បានចូលក្នុងដំណើរការពី សិទ្ធិសេរីភាព អាទិភាព និងការយល់ព្រមដែលជូនដំណឹង (FPIC)។

<u>*សំណួរទី៤៖ តើវាពិតជាអាចធ្វើទៅបានទេនៅប្រទេសកម្ពុជា?*</u>

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- ជាការពិត វាជាការអាចធ្វើបាន ប្រសិនបើមានឆន្ទៈនយោបាយដើម្បីបង្កើតវាដូច្នេះ។ ហើយយើងពិតជាមើលឃើញឆន្ទៈនយោបាយ ដែលទាក់ទងទៅនឹងដំណើរការគោលនយោបាយជារួមនៅក្នុងប្រទេសនេះ ដើម្បីឆ្ពោះទៅរកប្រជាធិបតេយ្យភាវូបនីយកម្មកាន់តែប្រសើរ។ ក្នុងខណៈនេះ ដោយមានជំនួយពីដៃគូអង្គការ មិនមែនរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ រដ្ឋាភិបាលកំពុងបង្កើតនីតិវិធីនានា ដើម្បីធានាថាសិទ្ធិដើម្បីទទួលបានសេរីភាព អាទិភាព និង ការយល់ព្រមដែលផ្តល់ដំណឹង ត្រូវបានគោរព។

<u>*សំណួរទី៥ ៖ និយាយអំពីការពារសុវត្ថិភាពបរិស្ថាន តើហេតុអ្វីចាំបាច់ពិចារណាទៅលើការអភិរក្សសត្វព្រៃ?*</u>

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- ជាមូលដ្ឋាន ដោយសារតែព្រៃឈើដែលមានសុខភាពល្អ គឺជាព្រៃដែលពេញទៅដោយសត្វព្រៃ។ មានប្រភេទអន្តរកម្មផ្សេងៗក្នុងចំណោមរុក្ខជាតិ និងសត្វនៅក្នុងព្រៃ។ ឧទាហរណ៍៖ ដើមឈើមួយចំនួនទាមទារឲ្យមានប្រភេទជាក់លាក់របស់សត្វ ដើម្បីពាំនាំលំអងផ្ការបស់ពួកវា និងប្រភេទផ្សេងទៀត មិនអាចធ្វើបានដូចនេះទេ ឬ ប្រភេទសត្វមួយចំនួន គឺពឹងផ្អែកលើសត្វមួយចំនួនដើម្បីបំបែកផ្លែឈើរបស់ពួកវា។ ដូច្នេះ ប្រសិនបើព្រៃឈើបាត់បង់សត្វព្រៃ វាក៏នឹងចាប់ផ្តើមបាត់បង់រុក្ខជាតិ ហើយព្រៃឈើទាំងមូលនឹងធ្លាក់ចុះ។
- វាមានសារសំខាន់ដើម្បីធានាថា ព្រៃឈើដែលមានសុខភាពល្អដោយផ្អែកលើហេតុផលមួយចំនួន។ ដំបូងជាការពិតណាស់ ប្រជាជនជាច្រើនពឹងផ្អែកលើផលិតផលកើតចេញ

ពីព្រៃឈើ មិនត្រឹមតែឈើប៉ុណ្ណោះទេ ប៉ុន្តែក៏ជាម្ហូបអាហារ និងផលិតផលដែលមានប្រយោជន៍ផ្សេងទៀត ដូចជា ផ្តៅ និងឫស្សី ជាដើម។ ព្រៃឈើដែលមានសុខភាពល្អអាចបន្តបង្កើតផលិតផលទាំងនេះ ចំណែកឯព្រៃឈើដែលគ្មានសុខភាពល្អ ធ្វើឲ្យស្ងួតយ៉ាងឆាប់រហ័ស ។

- ប៉ុន្តែ មានហេតុផលមួយផ្សេងទៀតដែលមានទំនាក់ទំនងទៅនឹងការប្រែប្រួលអាកាសធាតុ។ បើទោះបីជាកិច្ចខិតខំប្រឹងប្រែងជាអន្តរជាតិកំពុងព្យាយាមបន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ វាមិនអាចធ្វើទៅបានដើម្បីបញ្ចៀសផលប៉ះពាល់ទាំងស្រុងនោះ។ អាកាសធាតុរបស់យើងនឹងផ្លាស់ប្តូរ ហើយនេះនឹងបណ្តាលឲ្យមានផលប៉ះពាល់ជាច្រើន ដូចជា ភ្លៀងធ្លាក់ខ្លាំង និងគ្រោះរាំងស្ងួតអូសបន្លាយយូរ។ ព្រៃឈើដែលមានសុខភាពល្អ អាចជួយយើងឱ្យសម្របខ្លួនទៅនឹងការប្រែប្រួលទាំងនេះបាន ដូចជា ព្រៃឈើដែលមានសុខភាពល្អអាចជួយបញ្ចៀសការរអិលបាក់ដី និងកាត់បន្ថយទឹកជំនន់ធ្ងន់ធ្ងរ។ នៅតាមបណ្តោយឆ្នេរសមុទ្រព្រៃកោងកាងដែលមានសុខភាពល្អអាចកាត់បន្ថយផលប៉ះពាល់នៃការកើនឡើងកម្ពស់ទឹកសមុទ្រ និងខ្យល់ព្យុះបាន។ ដូច្នេះ វាជាការសំខាន់ណាស់ដែលយើងមិនគ្រាន់តែផ្តោតទៅលើការអភិរក្សកាបូន នៅក្នុងព្រៃរបស់យើងប៉ុណ្ណោះទេ តែថែមទាំងអាចអភិរក្សសត្វព្រៃបានផងដែរ។

<u>សំណួរទី៦ ៖ វាពិតជាល្អខ្លាំងណាស់និយាយអំពីការពារសុវត្ថិភាព ប៉ុន្តែតើធ្វើដូចម្តេចឲ្យប្រជាជនបានដឹង ប្រសិនបើពួកគេពិតជាបានកំពុងត្រូវបានអនុវត្តនោះ?</u>

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- នៅប្រទេសកម្ពុជា ក៏ដូចជាបណ្តាប្រទេសផ្សេងទៀតដែលអនុវត្តរេដបូកដែរ នឹងមានរាយការណ៍ជាប្រចាំដល់សហគមន៍អន្តរជាតិ អំពីរបៀបដែលពួកគេកំពុងដំណើរការទៅមុខ និងរបាយការណ៍ទាំងនេះ ក៏ត្រូវមានការពារសុវត្ថិភាព ការផ្តល់ពត៌មានស្តីអំពីរបៀបការពារសុវត្ថិភាព កំពុងត្រូវបានអនុវត្ត និងគោរពផងដែរ។
- នេះមានន័យថាប្រព័ន្ធមួយនេះ នឹងត្រូវបានអនុវត្តដើម្បីប្រមូល និងរាយការណ៍ព័ត៌មានពីការការពារសុវត្ថិភាព។ នៅក្នុងកម្មវិធីមុន វាត្រូវបានគេលើកឡើងថា រដ្ឋាភិបាលមិនអាចអភិរក្សព្រៃឈើដោយខ្លួនឯងបានទេ។ ពួកគេត្រូវការជំនួយរបស់ភាគីពាក់ព័ន្ធផ្សេងទៀតនៅក្នុងកិច្ចខិតខំប្រឹងប្រែង ហើយក៏ដូចជាការអនុវត្តការការពារសុវត្ថិភាពបូន

នេះដែរ។ ខណៈពេលដែលវានៅតែត្រូវការរៀបចំបង្កើតឡើងវិញនោះ ប្រព័ន្ធប្រមូលព័ត៌មានស្តីពី ការការពារសុវត្ថិភាព នឹងតម្រូវឲ្យមានការចូលរួមចំណែកយ៉ាងសកម្ម ពីអ្នកពាក់ព័ន្ធនានា។ ដូច្នេះ អ្នកទាំងអស់គ្នាអាចរកព័ត៌មាននេះបាន សម្រាប់ការពិនិត្យមើល។

### គ. សំណួរ និងចម្លើយ ពីអ្នកចូលចរួម (១០នាទី)

សមាជិកអ្នកចូលរួម នឹងត្រូវបានអញ្ជើញឲ្យសួរសំណួរបន្តបន្ទាប់ដែលវាគ្មិននឹងធ្វើការឆ្លើយតប។ សំណួររំពឹងទុកមួយចំនួនអាចជា៖

- តើនរណានឹងទទួលខុសត្រូវ ដើម្បីធានាថាការការពារសុវត្ថិភាពត្រូវបានគោរព?
- តើអ្វីអាចកើតឡើង ប្រសិនបើវាត្រឡប់ទៅជាការការពារសុវត្ថិភាព មិនត្រូវបានគោរពនោះ?
- តើយើងអាចប្រាកដថា ទិន្នន័យដែលគេកំពុងរាយការណ៍នោះត្រឹមត្រូវ ដែរឬទេ?

### ឃ. សង្ខេប (៣នាទី)

អ្នករៀបចំកម្មវិធី អញ្ជើញភ្ញៀវឲ្យផ្តល់យោបល់បញ្ចប់ សង្ខេបសារសំខាន់ៗពីកម្មវិធី និងផ្សព្វផ្សាយកម្មវិធីបន្តបន្ទាប់ទៀត។

## កម្មវិធីទី៨៖ ផលប្រយោជន៍មិនមែនជាកាបូន

### ក. សេចក្ដីផ្ដើម (៦នាទី)

- ការណែនាំខ្លឹមសារពីអ្នកកាន់កម្មវិធី
- បញ្ចាំងវីដេអូ ស្ដីអំពី សហផលប្រយោជន៍

### ខ. សំនួរ និងចម្លើយ (២០នាទី)

អ្នកកាន់កម្មវិធី នឹងលើកសំណួរទៅកាន់ កញ្ញា តេងរឹទ្ធីនី (NGOF) និងលោក យាង ដូណាល (FFI)។

<u>សំនួរទី១៖ យើងបានដឹងថា ព្រៃឈើផ្ដល់គុណប្រយោជន៍ច្រើន មិនត្រឹមតែការអភិរក្សកាបូនទេ ដូច្នេះ តើយើងអាចសម្រេចថា តើផលប្រយោជន៍ណាខ្លះដែលសំខាន់បំផុត?</u>

ចំលើយ (ចំនុចដែលត្រូវពន្យល់)៖

- o វាមិនមែនជាករណីចំណោញ ឬ ខាតមួយនោះទេ ពីព្រោះព្រៃឈើមិនមែនផ្ដល់ប្រយោជន៍តែមួយមុខនោះទេ។ ព្រៃឈើទាំងអស់ផ្ដល់ផលប្រយោជន៍គ្រប់យ៉ាង ដោយគ្រាន់តែក្នុងសមាមាត្រខុសគ្នា។ ឧទាហរណ៍៖ ព្រៃឈើដែលមានប្រភេទឈើច្រើនយ៉ាងនៅជាមួយគ្នា មានឈើប្រភេទច្រើនបានផ្ដល់សេវាកម្មខាងការអភិរក្សជីវចម្រុះយ៉ាងខ្ពស់បំផុត ប៉ុន្តែប្រហែលជាមិនមែនតម្លៃខ្ពស់នៅក្នុងន័យឈើហ៊ុបទេ ប្រសិនបើប្រភេទឈើល្អៗមិនមាននៅទីនោះ។ ព្រៃនៅតំបន់ខ្ពង់រាបនៃទីជម្រាល នឹងផ្ដល់តម្លៃក្នុងការអភិរក្សគុណភាពទឹកយ៉ាងច្រើន។
- o ដូច្នោះ ប្រសិនបើអ្នកចង់ពិនិត្យលើតម្លៃព្រៃឈើជាទូទៅ លោកអ្នកគួរស្វែងយល់ថាតើប្រភេទព្រៃឈើណាដែលអាចផ្ដល់តម្លៃណាមួយ ហើយត្រូវយកចិត្តទុកដាក់ខ្ពស់លើប្រភេទព្រៃនោះ។

<u>សំនួរទី២៖ ប៉ុន្តែ យើងបានដឹងថា រេដបូកអនុវត្តបានគ្រប់ប្រភេទព្រៃនៅកម្ពុជា។ តើវាមានន័យថា យើងយកចិត្តទុកដាក់តែទៅលើការអភិរក្សកាបូន?</u>

ចំលើយ (ចំនុចដែលត្រូវពន្យល់)៖

- ទេ មិនអញ្ចឹងទេ។ ចំណុចដែលរេដបូកគ្របដណ្តប់រាល់ព្រៃឈើនៅប្រទេសកម្ពុជា គឺមានន័យថា យើងត្រូវតែធ្វើរបាយការណ៍ ស្តីពី ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីគ្រប់ប្រភេទព្រៃឈើទាំងអស់។ វាមិនមែនមានន័យថា រាល់ប្រភេទព្រៃទាំងអស់ត្រូវតែបានគ្រប់គ្រងសម្រាប់ការអភិរក្សកាបូននោះទេ។ ប្រសិនបើអ្នកមានព្រៃឈើដែលមិនបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដោយសារមិនមានការបាត់បង់ ឬរេចរឹលព្រៃឈើ អ្នកអាចគ្រប់គ្រងព្រៃឈើនោះសម្រាប់តម្លៃផ្សេងៗទៀត។

<u>**សំនួរទី៣៖ ខ្ញុំប្រាកដណាស់ថា មិនមាននណាម្នាក់ នឹងយល់ស្របថាតម្លៃណាខ្លះដែលសំខាន់បំផុតនោះ។ កសិករប្រហែលជាយល់ថា ការអភិរក្សទឹកគឺសំខាន់បំផុត ចំណែកឯអង្គការក្រៅ រដ្ឋាភិបាលប្រហែលជាយល់ថាការអភិរក្សជីវចម្រុះគឺសំខាន់បំផុត?**</u>

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- ជាថ្មីម្តងទៀត វាគឺមិនមែនជាករណីដែលថាការយកចិត្តទុកដាក់លើការអភិរក្សធនធានទឹកនោះ អ្នកនឹងបូកបញ្ចូលការអភិរក្សជីវចម្រុះនោះទេ។ ជារួម ព្រៃឈើដែលមានគុណភាពល្អ គឺជាការប្រសើរបំផុតក្នុងការផ្តល់គ្រប់សេវាកម្មដែលយើងបានឱ្យតម្លៃដល់។ ដូច្នោះក្នុងការគ្រប់គ្រងព្រៃឈើ ប្រសិនបើអ្នកគ្រប់គ្រងវាឲ្យមានភាពប្រសើរឡើង ព្រៃឈើទាំងនោះនឹងមានប្រសិទ្ធភាពខ្ពស់ក្នុងការអភិរក្សធនធានទឹក ការអភិរក្សជីវចម្រុះ និងការអភិរក្សកាបូនផងដែរ។ វាគឺជាស្ថានភាពឈ្នះ-ឈ្នះ-ឈ្នះ។

<u>**សំនួរទី៤៖ ព្រៃឈើរបស់ប្រទេសកម្ពុជាភាគច្រើន គឺរេចរឹលយ៉ាងខ្លាំងរួចទៅហើយ។ តើយើងគួរដោះស្រាយយ៉ាងណា?**</u>

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- ព្រៃឈើ ក៏ដូចជាប្រព័ន្ធអេកូឡូស៊ីដទៃទៀតដែរ គឺមានលក្ខណៈធន់ខ្លាំងតាមបែបធម្មជាតិ។ ប្រសិនបើអ្នកដកហូតអ្វីមួយដែលបណ្តាលឱ្យរេចរឹលព្រៃឈើ វាអាចជួសជុលឡើងវិញយ៉ាងលឿន ជាពិសេសបើមានការគាំទ្រផ្នែកគ្រប់គ្រងយ៉ាងសកម្ម។ ករណីនេះ គេបានឃើញជាឧទាហរណ៍ព្រៃឈើនៃតំបន់ភាគខាងជើងប្រទេសនេប៉ាល់ កន្លែងមួយដែលពេលមួយនោះព្រៃឈើដែលរេចរឹលខ្លាំងនោះ ត្រូវបានប្រគល់ឲ្យសហគមន៍គ្រប់គ្រង វាបានស្តារឡើងវិញយ៉ាងឆាប់ គេអាចមើលឃើញមានការផ្លាស់ប្តូរ តាមរយៈរូបភាពផ្កាយរណប ក្នុងរយៈពេលប៉ុន្មានឆ្នាំបន្ទាប់។

- ដូច្នោះ ករណីខ្លះ វាជាការគ្រប់គ្រាន់ដោយគ្រាន់តែលុបបំបាត់ការគំរាមគំហែងទាំងនោះ។ ក្នុងករណីផ្សេងទៀត អ្នកប្រហែលជាត្រូវការភាពសកម្មជាងមុន ឧទាហរណ៍៖ ការដាំដើមឈើឡើងវិញនៅកន្លែងដែលមិនមែនគ្រាប់រុក្ខជាតិនៅសេសសល់ ឬក៏ ការកសាងរបាំងត្រួតពិនិត្យកន្លែងដែលសំណើមដីជាកត្តាសំខាន់។
- ប៉ុន្តែ ប្រការដែលអាក្រក់បំផុតនោះ គឺកាប់ព្រៃឈើឱ្យអស់រលីងពីដីតែម្តង ព្រោះនៅពេលអស់ព្រៃ វាកម្រនឹងវិលមករកសភាពដើមវិញណាស់ ហើយនៅក្រោមប្រព័ន្ធសុវត្ថិភាព រេដបូក បើទោះជាអ្នកដាំដើមឈើថ្មីក៏ដោយ អ្នកមិនអាចគិតពីកាបូនដែលវាស្រូបពីបរិយាកាសបានទេ ពីព្រោះអ្នកបានបំលែងព្រៃធម្មជាតិទៅជាព្រៃដាំ។

<u>សំនួរទី៥៖ តើអ្វីទៅជាចក្ខុវិស័យរបស់អ្នកសម្រាប់ព្រៃឈើកម្ពុជា រយៈពេល ១០ ឬ ២០ឆ្នាំ ទៅមុខ?</u>

**ចំលើយ (ចំនុចដែលត្រូវពន្យល់)៖**

- ចក្ខុវិស័យរបស់ខ្ញុំគឺថា បើទោះបីជាផ្ទៃដីព្រៃឈើសរុបប្រហែលជាតិចជាងទំហំដីព្រៃ ដែលមាននាពេលបច្ចុប្បន្នក្តី ប៉ុន្តែព្រៃឈើដែលនៅសេសសល់គឺមិនស្ថិតក្នុងការគំរាមគំហែង ហើយមានគុណភាពកាន់តែប្រសើរឡើងជាប្រចាំ។ ព្រៃឈើ គឺកំពុងតែផ្តល់នូវចំណូលយ៉ាងសំខាន់ដល់សហគមន៍ជាច្រើនដែលនៅក្នុង និងនៅជុំវិញតំបន់ព្រៃឈើ បើទោះជាចំនួនប្រជាជនកម្ពុជាដែលរស់នៅក្នុងតំបន់ទីក្រុង និងប្រជុំជន មានអត្រាខ្ពស់ជាងខ្លាំងក៏ដោយ។ ចំនុចមួយសំខាន់បំផុតសម្រាប់ខ្ញុំ មិនថាអ្នករស់នៅទីជនបទ ឬ ទីក្រុង ក្មេង និងចាស់ ត្រូវទទួលស្គាល់តម្លៃព្រៃឈើ រួមគ្នាការពារ និងអភិរក្សព្រៃឈើ។
- ចក្ខុវិស័យរបស់ខ្ញុំ ខ្ញុំក៏បានឃើញដើមឈើជាច្រើននៅលើដី ដែលបច្ចុប្បន្នមិនមានព្រៃ។ ប្រសិនបើអ្នកធ្វើទស្សនកិច្ចនៅសហរដ្ឋអាមេរិច ឬ អ៊ឺរ៉ុបខាងលិច នៅពេលអ្នកបើករថយន្តតាមបណ្តោយមហាវិថី វាហាក់ដូចជាបើកបរក្នុងព្រៃពីព្រោះតាមបណ្តោយផ្លូវ ទីកន្លែងដែលមិនប្រើការ គឺត្រូវបានគេដាំដើមឈើ។

## គ. វគ្គសំណួរ និងចម្លើយ សម្រាប់ភ្ញៀវដែលចូលរួម (១០នាទី)

ភ្ញៀវចូលរួម ត្រូវបានអញ្ជើញឱ្យសួរសំណួរ។ សំណួរដែលអាចរំពឹងទុកខ្លះៗ មានដូចជា៖

- ប្រាកដណាស់ថា អ្នកដែលឲ្យតម្លៃខ្លាំងទៅលើការអភិរក្សកាបូន គឺជាប្រទេសជឿនលឿន ពីព្រោះប្រសិនបើប្រទេសកម្ពុជាអាចកាត់បន្ថយការបញ្ចេញឧស្ម័ន ពួកគេនៅតែអាចបន្តបំពុលបរិយាកាសបន្ថែមទៀត។ ដូច្នោះហើយ តើហេតុអ្វីបានជាយើងគួរតែខ្វល់ខ្វាយ?
- ប្រទេសកម្ពុជាបានបាត់បង់រួចទៅហើយនូវសត្វព្រៃដ៏ច្រើន ឧទាហរណ៍៖ មានអ្នកខ្លះបានប៉ាន់ប្រមាណថាសត្វខ្លានៅមានប្រហែល ៣០ក្បាល ប៉ុណ្ណោះ។ តើនៅមានក្តីសង្ឃឹមអ្វីខ្លះទៀត សម្រាប់ប្រភេទសត្វទាំងនេះ?
- តើមានឧទាហរណ៍ខ្លះពីកន្លែងដទៃក្នុងពិភពលោក ដែលអ្នកកំពុងរស់នៅក្នុង និងជុំវិញតំបន់ព្រៃឈើ គឺមានជីវភាពធូធារដូចអ្នកដែលរស់នៅក្នុងតំបន់ទីប្រជុំជន និងទីក្រុង?

### ឃ. សរុប (៣នាទី)

អ្នករៀបចំកម្មវិធី បានអញ្ជើញភ្ញៀវដែលបានចូលរួមផ្តល់មតិនៅនាទីបញ្ចប់ សង្ខេបខ្លឹមសារសំខាន់ៗពីកម្មវិធី និងផ្សព្វផ្សាយនូវកម្មវិធីបន្ទាប់។

## កម្មវិធីទី៩ ៖ ការប្រឈមពីរេដបូក

### ក. សេចក្តីផ្តើម (៦នាទី)

- ការណែនាំសារពីអ្នកកាន់កម្មវិធី
- ការបញ្ចាំងតំបន់ព្រៃឈើនៅក្នុងខេត្តគោលដៅ និងសម្ភាសជាមួយប្រជាជនក្នុងសហគមន៍

### ខ. សំណួរ និងចម្លើយ (២០នាទី)

អ្នកដឹកនាំកម្មវិធី និងលើកសួរសំណួរទៅកាន់គណៈកម្មាការ រួមមាន៖ ឯកឧត្តម បណ្ឌិត ជា សំអេង, លោក វ៉ា មឿន (ម្លប់បៃតង) និងលោក គឹម ណុង (ក្រសួងបរិស្ថាន)។

<u>សំនួរទី១៖ បើទោះជាមានការខិតខំប្រឹងប្រែងលើការងាររេដបូកក៏ដោយ តើមានអ្វីកើតឡើង ប្រសិនបើការបាត់បង់ និងរេចរឹលព្រៃឈើនៅតែបន្ត?</u>

**ចំលើយ (ចំនុចដែលត្រូវបកស្រាយដោយគណៈកម្មការ)៖**

- ជាប្រការសំខាន់គឺត្រូវចាំថា គោលដៅរបស់រេដបូក គឺដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីព្រៃឈើ គឺមិនកាត់ផ្តាច់ការបញ្ចេញឧស្ម័នទាំងស្រុងទេ។ នៅក្នុងការចរចារស្តីពីរេដបូក សហគមន៍អន្តរជាតិបានទទួលស្គាល់ថា ប្រទេសកំពុងអភិវឌ្ឍដូចកម្ពុជាត្រូវការប្រើប្រាស់ធនធានព្រៃឈើរបស់ខ្លួនក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ អាស្រ័យហេតុនេះ ប្រសិនបើព្រៃឈើត្រូវបានឈូសឆាយសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម ឬក៏ សម្រាប់គម្រោងរចនាសម្ព័ន្ធថ្មីៗនោះគឺមិនមានបញ្ហាទេ។
- គោលដៅរបស់រេដបូក គឺដើម្បីកាត់បន្ថយការបញ្ចេញដោយប្រៀបធៀបជាមួយនឹងកម្រិតយោង (Reference level) របស់កម្ពុជា ដូចបានពិភាក្សានៅក្នុងកម្មវិធីមុន។ ដូច្នេះ ប្រសិនបើការបញ្ចេញមានការកើនឡើងដោយប្រៀបធៀបជាមួយកម្រិតយោង នោះចម្លើយដ៏សាមញ្ញ គឺថាប្រទេសកម្ពុជានឹងមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលផលប្រយោជន៍ពីបណ្តាប្រទេសអភិវឌ្ឍទេ។
- យ៉ាងណាក៏ដោយ ភាពជំពាក់ជំពិនពិតប្រាកដនៃសេនារីយ៉ូបែបនេះ គឺថាយើងបានទទួលភាពបរាជ័យនៅក្នុងធ្វើផែនការសម្រាប់រេដបូក។ វាគួរតែជាបញ្ហាសាមញ្ញមួយដែលត្រូវសម្រេចថាកន្លែងណាដែលពិតប្រាកដ ក្នុងការកាត់បន្ថយឧស្ម័ន ហើយថាតើមូលហេតុ(ចលករ)ណាមួយ ដែលមើលឃើញអាចត្រូវដោះស្រាយបាន។ ប្រសិនបើ

យើងពិតជាបានព្យាយាមកាត់បន្ថយការបញ្ចេញឧស្ម័ន នៅក្នុងកន្លែងដែលមិនប្រាកដប្រជា នោះមានន័យថាយើងបានរៀបចំផែនការមិនល្អ។ ហេតុនេះហើយបានជាដំណាក់កាលថ្មីៗនេះក្នុងការត្រៀមខ្លួនសម្រាប់រេដបូក គឺមានសារៈសំខាន់ណាស់។ ប្រសិនបើយើងយកចិត្តទុកដាក់ខ្ពស់ក្នុងការកសាងភាពត្រៀមជាស្រេច នោះកម្រិតបរាជ័យគឺមានតិចតួចបំផុត។

<u>សំនួរទី២៖ តើយើងអាចប្រកដទេថា ប្រទេសអភិវឌ្ឍពិតជា និងផ្តល់រង្វាន់ដល់កម្ពុជា ប្រសិនបើយើងទទួលបានជោគជ័យ--ជាចុងក្រោយ បទពិសោធន៍ជាមួយគម្រោងនៅខេត្តឧត្តមានជ័យគឺមិនត្រូវបានលើកទឹកចិត្ត ទេឬ?</u>

ចំលើយ (ចំនុចដែលត្រូវបកស្រាយដោយគណៈកម្មការ)៖

- ស្ថានភាពសម្រាប់រេដបូកនៅកម្ពុជា គឺមានលក្ខណៈខុសស្រឡះពីស្ថានភាពគម្រោងរេដបូកនៅខេត្តឧត្តរមានជ័យ។ យើងនឹងធ្វើការចរចារលើកិច្ចព្រមព្រៀងនានា ជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍ មុនពេលអនុវត្តវិធីសាស្រ្តកាត់បន្ថយការបញ្ចេញឧស្ម័ន។ ក្នុងករណីគម្រោងរេដបូកនៅខេត្តឧត្តរមានជ័យ គឺគម្រោងពឹងផ្អែកលើការស្វែងរកអ្នកទិញកាបូន បន្ទាប់ពីគម្រោងសម្រេចបានជោគជ័យ។ កិច្ចព្រមព្រៀងក្រោមកម្មវិធីរេដបូកនឹងមានលក្ខខណ្ឌដែលយើងនឹងទទួលបានការបង់ថ្លៃ តែក្នុងករណីយើងសម្រេចបានលទ្ធផល។ ប៉ុន្តែយើងនឹងមានលក្ខខណ្ឌជាមុន មុននឹងឈានដល់កិច្ចព្រមព្រៀងនេះ។
- ការរៀបចំបែបនេះ បានអនុវត្តរួចហើយនៅបណ្តាប្រទេសមួយចំនួន។ ឧទាហរណ៍៖ នៅប្រទេសប្រេស៊ីល ឥណ្ឌូនេស៊ី និងវៀតណាម មានកិច្ចព្រមព្រៀងជាមួយប្រទេសណ័រវេ ហើយប្រទេសកូស្តារីកា មានកិច្ចព្រមព្រៀងជាមួយធនាគារពិភពលោក។

<u>សំនួរទី៣៖ ការវាស់វែងការបញ្ចេញឧស្ម័ន ការប្រមូលព័ត៌មាន ស្តីពី ប្រព័ន្ធការពារសុវត្ថិភាព ការចែករំលែកគុណប្រយោជន៍ប្រកបដោយយុត្តិធម៌ និងសមធម៌ ទាំងនេះគឺជាកិច្ចការដែលកំពុងប្រឈម តើប្រទេសកម្ពុជាពិតជាមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីដោះស្រាយរឿងរាវទាំងនេះ ប្រកបដោយប្រសិទ្ធភាព ដែរឬទេ?</u>

ចំលើយ (ចំនុចដែលត្រូវបកស្រាយដោយគណៈកម្មការ)៖

- តាមពិត ពួកគេគឺកំពុងតែមានភាពប្រឈម! ហេតុនេះហើយបានជាយើងត្រូវស្វែងរកជំនួយពីដៃគូអន្តរជាតិនានាៗ រួមមាន៖ អង្គការសហប្រជាជាតិ ប្រទេសជប៉ុន និងសហគមន៍អឺរ៉ុប ក្នុងការជួយយើងក្នុងការរៀបចំការងារទាំងនេះ ឲ្យបានល្អប្រសើរ។
- វាក៏ជាហេតុមួយដែលយើងបានស្វែងរកជំនួយយ៉ាងសកម្មពីដៃគូនានា នៅក្នុងប្រទេស ដូចជា៖ អង្គការក្រៅរដ្ឋាភិបាល គ្រឹស្ថានសិក្សាអប់រំ និងស្ថាប័នផ្សេងៗទៀត។ យើងទទួលស្គាល់ថា រដ្ឋាភិបាលតែម្នាក់ឯងមិនអាចរំពឹងទុកថានឹងមិនសម្រេចបានលទ្ធផលទាំងនេះទេ យើងត្រូវការធ្វើការជាមួយគ្នា។ ហេតុនេះហើយ បានជាយើងស្វែងព្យាយាមលើកទឹកចិត្តអ្នកពាក់ព័ន្ធនានាមកចូលរួមក្នុងកម្មវិធីនេះ ច្រើនជាងក្នុងកម្មវិធីការពារអភិរក្សធនធានធម្មជាតិមុនៗ។

<u>សំនួរទី៩៖ ព័ត៌មានដឹងឮសុះសាយថា បរិមាណឈើដ៏ច្រើនសម្បើម ត្រូវបានកាប់ដោយខុសច្បាប់នៅក្នុងប្រទេសកម្ពុជា ហើយដឹកជញ្ជូននៅកាន់ប្រទេសវៀតណាម ថៃ និងកាត់តាមប្រទេសឡាវទៅចិន។ វាគឺជាករណីដែលជំរុញឱ្យប្រជាជនទទួលបានផលពីសកម្មភាពទាំងនេះដែរ។ តើយើងពិតជាអាចដោះស្រាយបញ្ហានេះ ប្រកបដោយប្រសិទ្ធភាព ដែរឬទេ?</u>

**ចំលើយ (ចំនុចដែលត្រូវបកស្រាយដោយគណៈកម្មការ)៖**

- យើងត្រូវតែមានការប្រុងប្រយ័ត្ន ក្នុងការសំឡឹងមើលទៅលើរេដបូកដូចជាគ្រាប់កាំភ្លើងប្រាក់មួយ ដែលបាញ់ចេញអាចដោះស្រាយគ្រប់បញ្ហាទាក់ទងជាមួយព្រៃឈើ។ បញ្ហាដែលអ្នកបានបរិយាយ គឺមានការប្រឈមពិតប្រាកដនោះទេ ប៉ុន្តែគេអាចដោះស្រាយបាន រេដបូក អាចដើរតួនាទីសំខាន់មួយ ជាមួយនឹងដំណោះស្រាយផ្សេងៗទៀត។
- ឧទាហរណ៍៖ សហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប អូស្ត្រាលី និងប្រទេសជាច្រើនផ្សេងទៀតនៅប៉ុន្មានឆ្នាំថ្មីៗនេះ បានណែនាំពង្រឹងបញ្ញត្តិទាក់ទងនឹងការនាំឈើហ៊ុបចូល ដូច្នោះ វាគឺកំពុងចាប់ផ្តើមដំបូងនៃការលំបាក សម្រាប់ឧស្សាហកម្មនៅតាមបណ្តាប្រទេសនាំចេញក្នុងការប្រើប្រាស់ឈើខុសច្បាប់។ នាពេលបច្ចុប្បន្ន ចលនាសកម្មភាពអន្តរជាតិឆ្លើយតបបញ្ហានេះ គឺមានការកើនឡើង។ ដូច្នេះ យើងសង្ឃឹមថានឹងឃើញមានការត្រួតពិនិត្យដ៏តឹងតែងកើតមានឡើងនាពេលអនាគត។
- ស្រដៀងគ្នានោះដែរ បច្ចេកវិទ្យាដែលមានសម្រាប់ត្រួតពិនិត្យឈើ ដែលត្រូវបានប្រមូលដោយខុសច្បាប់នោះ គឺត្រូវបានគេប្រើប្រាស់កាន់តែច្រើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។

ឧទាហរណ៍៖ បច្ចុប្បន្ន គេអាចប្រើប្រាស់ប្រដាប់វិភាគហ្សែន ដើម្បីឱ្យដឹងថាតើឈើនោះ មានប្រភពមកពីប្រទេសណា។

- ដូច្នោះ តើរេដបូកអាចផ្ដល់ជាវិភាគទានយ៉ាងដូចម្ដេច? តើនាំឲ្យសម្រេចបានយ៉ាងដូចម្ដេច? យន្ដការជាច្រើនដែលយើងកំពុងតែអនុវត្តនៅនឹងកន្លែង គឺដើម្បីអនុញ្ញាតពពួកស្ថាប័នដែលពាក់ព័ន្ធ ជួយឲ្យបានសម្រេចទៅកាន់រេដបូកក៏អាចជួយផងដែរ ដើម្បីដោះស្រាយបញ្ហាជាច្រើន ដូចជា ការកាប់បំផ្លាញព្រៃឈើខុសច្បាប់។ ដោយការផ្ដល់នូវមធ្យោបាយមួយសម្រាប់សហគមន៍ក្នុងតំបន់ ដើម្បីលើកឡើងនូវភាពភ័យអាសន្ន ប្រសិនបើពួកគេបង្ហាញការកាប់បំផ្លាញព្រៃឈើខុសច្បាប់ ដោយពុំមានភាពភ័យខ្លាចលើការដាក់ទោស យើងអាចធ្វើវាឲ្យកាន់តែលំបាក សម្រាប់អ្នកកាប់បំផ្លាញព្រៃឈើខុសច្បាប់។
- ដោយសារវាជាបញ្ហាដ៏លំបាកមួយ យើងមិនអាចដោះស្រាយវាភ្លាមៗបានទេ ប៉ុន្តែយើងដោះស្រាយជាជំហានៗ ធ្វើឱ្យផលចំណេញពីការជួយដូរឈើខុសច្បាប់កាន់តែលំបាក និងរហូតដល់ធ្វើឱ្យហានិភ័យមានខ្លាំងជាងផលចំណេញ។

<u>សំណួរទី៥៖ លោកបានលើកឡើងអំពីការប្រឈមផ្សេងទៀត នៅពេលដែលលោកបាននិយាយអំពីសហគមន៍ក្នុងការលើកឡើងអំពីកង្វល់ដោយគ្មានការភ័យខ្លាចជាប់ទោស។ វាគឺជាការពិតជាក់ស្ដែងដែលថា ការភ័យខ្លាចនេះធ្វើឲ្យអ្នកស្រុកមិនហ៊ាននិយាយ។ បើដូច្នោះ តើរឿងនោះនឹងដំណើរការបានយ៉ាងដូចម្ដេច?</u>

ចំលើយ (ចំនុចដែលត្រូវបកស្រាយដោយគណៈកម្មការ)៖

- ត្រូវហើយ វាគឺជាការប្រឈមមួយ ទាំងនៅក្នុងការរៀបចំយន្ដការមួយដែលមានប្រសិទ្ធភាព និងក្នុងការជម្រុញឱ្យអ្នកស្រុកចូលរួមអនុវត្តការងារ។
- ផ្នែកទីមួយនៃបញ្ហាប្រឈម គឺការរៀបចំយន្ដការមួយប្រកបដោយប្រសិទ្ធភាព។ យើងគឺកំពុងតែធ្វើការជាមួយ UNDP លើរឿងនេះ។ យើងដឹងថានៅតាមមូលដ្ឋាន មានយន្ដការដោះស្រាយជម្លោះប្រកបដោយប្រសិទ្ធភាពរួចហើយ សម្រាប់ប្រជាជនសហគមន៍។ នៅពេលមានជម្លោះជាមួយភាគីដទៃទៀត ដូចជា ក្រុមហ៊ុនពាណិជ្ជកម្ម យន្ដការដោះស្រាយនោះមិនអាចដោះស្រាយបានទេ។ យើងកំពុងតែសិក្សាបទពិសោធន៍ពីប្រទេសដទៃ ដែលអាចដោះស្រាយបញ្ហាជម្លោះប្រភេទនេះបាន។

- ចំនុចល្អមួយដែលយើងមាន និងអាចជួយក្នុងការរៀបចំប្រព័ន្ធដោះស្រាយមួយ ប្រកបដោយប្រសិទ្ធភាព គឺយើងមានបណ្តាញការងារជាមួយអ្នកពាក់ព័ន្ធកាន់តែច្រើន ដូចជា បណ្តាញការងារសហគមន៍ព្រៃឈើ បណ្តាញការងារសហគមន៍នេសាទ បណ្តាញការងារអង្គការក្រៅរដ្ឋាភិបាល និងបណ្តាញការងារជនជាតិភាគតិច។ សមាជិករបស់ក្រុមប្រឹក្សាយោបល់នៅទីនេះ នឹងពិភាក្សាអំពីបទពិសោធន៍របស់ពួកគេនៅក្នុងកម្មវិធីបន្ទាប់។ ដូច្នេះ យើងបានកសាងធាតុសំខាន់ៗជាច្រើន ដែលយើងអាចប្រើប្រាស់វាបាន។
- ការប្រឈមទីពីរ ការលើកទឹកចិត្ត ជម្រុញឱ្យប្រជាជនសហគមន៍ហ៊ាននិយាយ ចូលរួមក្នុងការងារកសាងចំណេះដឹង និងមានទំនុកចិត្ត។ ហើយដែលមិនអាចជៀសរួច ការងារនេះនឹងអនុវត្តបានទៅមុខដោយយឺតៗ ប៉ុន្តែយើងសង្ឃឹមថាកម្មវិធីនេះអាចផ្តល់ជាវិភាគទានដល់ការងាររបស់យើង។ យើងក៏មានគម្រោងបោះពុម្ពផ្សាយអំពីបទពិសោធន៍ដំបូងៗឲ្យបានទូលំទូលាយ នៅតាមទីកន្លែងដែលបណ្តាញការងារដំណើរការ។ តាមរយៈសកម្មភាពនេះ យើងកសាងទំនុកចិត្តដល់អ្នកពាក់ព័ន្ធ ដើម្បីឱ្យពួកគេចូលរួមផ្តល់យោបល់កាន់តែច្រើនឡើង។

## គ. វគ្គសំណួរ និងចម្លើយ (១០នាទី)

សមាជិកចូលរួមជាច្រើន នឹងត្រូវបានអញ្ជើញដើម្បីលើកជាសួរ ទៅវាគ្មិនដើម្បីឆ្លើយតប។ សំនួរខ្លះៗដែលអាចមាន ដូចជា៖

- តើយើងមិននៅក្នុងការប្រគួតប្រជែងជាមួយប្រទេសដទៃ ក្នុងការទាក់ទាញឱ្យមានកិច្ចព្រមព្រៀងជាមួយបណ្តាប្រទេសអភិវឌ្ឍន៍ ទេឬ? តើហេតុអ្វីបានជាប្រទេសទាំងនោះគាំទ្រប្រទេសកម្ពុជា ជាងប្រទេសផ្សេងៗទៀត?
- មានគំរូជាច្រើននៃការផ្តួចផ្តើមរបស់រដ្ឋាភិបាល ដែលជាព័ត៌មានគួរឱ្យចាប់អារម្មណ៍ក្នុងរយៈពេលដំបូង ប៉ុន្តែវាបាត់ទៅវិញដោយស្ងៀមស្ងាត់។ តើរឿងនេះនឹងកើតឡើងដែរឬទេ នៅក្នុងការអនុវត្តរេដបូក?
- តើនៅពេលណាដែលយើងអាចទទួលដំណឹងល្អថា ផលប្រយោជន៍នានាត្រូវបានធានា និងចែករំលែក?

## ឃ. សរុប (៣នាទី)

អ្នករៀបចំកម្មវិធី អញ្ជើញភ្ញៀវកិត្តិយសឱ្យមានមតិយោបល់ចុងក្រោយ សង្ខេបខ្លឹមសារសំខាន់ពីកម្មវិធី និងផ្សព្វផ្សាយនូវកម្មវិធីបន្ទាប់។

## កម្មវិធីទី១០៖ ការលើកទឹកចិត្តអ្នកពាក់ព័ន្ធ

### ក. សេចក្តីផ្តើម (៣នាទី)

- ការណែនាំខ្លឹមសារពីអ្នកកាន់កម្មវិធី

### ខ. គណៈកម្មការពិភាក្សា (២៥នាទី)

អ្នកគ្រប់គ្រងនៃកម្មវិធី នឹងណែនាំសមាជិកពី ៨ ទៅ ៩នាក់ ក្នុងក្រុមប្រឹក្សាយោបល់ រួមមាន៖ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ, អង្គការសង្គមស៊ីវិល(ថ្នាក់ខេត្ត), គ្រឹះស្ថានសិក្សាអប់រំ, ក្រុមជនជាតិដើមភាគតិច, បណ្តាញសហគមន៍ព្រៃឈើ, បណ្តាញសហគមន៍ជលផល, បណ្តាញសហគមន៍តំបន់ការពារ និងស្ថាប័នឯកជន។ គាត់នឹងដឹកនាំការពិភាក្សាអំពីតួនាទីរបស់ពួកគេនៅក្នុងរេដបូក ក្នុងចំណោមសមាជិកក្រុមប្រឹក្សាយោបល់ទាំងនោះ។ កាពិភាក្សានឹងប្រព្រឹត្តទៅដោយសេរី ឆ្លើយតបទៅនឹងសំណួរដែលលើកឡើងដោយបុគ្គលម្នាក់ៗ។ សំណួរនាំមុខពីអ្នកកាន់កម្មវិធី អាចមានដូចខាងក្រោម៖

- សូមប្រាប់យើងអំពីក្រុមប្រឹក្សាយោបល់ តើមានអណត្តិយ៉ាងដូចម្តេចដែរ? តើវាប្រព្រឹត្តទៅយ៉ាងដូចម្តេច?
- តើតម្លៃរបស់ក្រុមប្រឹក្សាយោបល់ស្ថិតនៅត្រង់ណា? តើក្រុមប្រឹក្សាយោបល់នេះ អាចជួយឱ្យរេដបូកនៅកម្ពុជា មានកល្លណៈកាន់តែខ្លាំងយ៉ាងដូចម្តេច?
- ក្នុងនាមជាសមាជិកក្រុមប្រឹក្សាយោបល់ម្នាក់ តើអ្នកទំនាក់ទំនងជាមួយនឹងសមាជិករបស់អ្នកយ៉ាងដូចម្តេច?
- ដោយសារការសម្រេចចិត្តអំពីរេដបូក ត្រូវធ្វើឡើងដោយក្រុមការងាររេដបូកកម្ពុជា តើអ្នកយល់ថាមតិរបស់អ្នកមានឥទ្ធិពលលើការសម្រេចចិត្តនោះ ដែរឬទេ?
- ប្រសិនបើអ្នកត្រួតពិនិត្យចង់ចូលរួមនៅក្នុងរេដបូក តើគេគួរធ្វើដូចម្តេច?
- តើអ្នកមានទំនុកចិត្តទេថា រេដបូកនឹងផ្តល់ផលប្រយោជន៍ពិតប្រាកដ សម្រាប់ប្រជាជនសាមញ្ញនៅក្នុងប្រទេសកម្ពុជា?

### គ. វគ្គសំនួរ និងចម្លើយពីអ្នកចូលរួម (១០នាទី)

អ្នកចូលរួមម្នាក់ៗ នឹងត្រូវអញ្ជើញឱ្យសួរទៅកាន់គណៈកម្មាការពិភាក្សា។ សំណួរអាចមាន៖

- តើអ្នកណាបានជ្រើសរើសអ្នកធ្វើជាសមាជិកក្រុមប្រឹក្សាយោបល់?
- តើដំណើរប្រឹក្សាយោបល់នៅកម្ពុជា អាចប្រៀបធៀបបានជាមួយនឹងដំណើរការនៅប្រទេសដទៃទៀត បានយ៉ាងដូចម្តេច?
- តើអ្នកណាត្រួតពិនិត្យលើការងាររបស់អ្នក ក្នុងនាមជាសមាជិកក្រុមប្រឹក្សាយោបល់ម្នាក់?
- តើហេតុអ្វីបានជាមានតំណាងជាស្ត្រីតិចតួច នៅក្នុងដំណើរការនេះ?

ឃ. សរុប (៥នាទី)

អ្នករៀបចំកម្មវិធី បានអញ្ជើញភ្ញៀវកិត្តិយសចូលរួមឱ្យមានមតិយោបល់ចុងក្រោយ សង្ខេបខ្លឹមសារសំខាន់ៗពីកម្មវិធី។

# សំណួរដែលតែងសួរជាប្រចាំ អំពី រេដបូក

## ១. តើព្រៃឈើមានទំនាក់ទំនងទៅនឹងការប្រែប្រួលអាកាសធាតុយ៉ាងដូចម្តេច?

ការប្រែប្រួលអាកាសធាតុ គឺកើតចេញពីឧស្ម័នផ្ទះកញ្ចក់យ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលកំពុងបញ្ចេញទៅក្នុងបរិយាកាស ដោយសារលទ្ធផលនៃសកម្មភាពនានារបស់មនុស្ស។ ឧស្ម័នផ្ទះកញ្ចក់ទាំងនោះ ស្រូបយកថាមពលពីព្រះអាទិត្យ ដែលជាកម្តៅ ហើយទង្វើនេះបែរជាបណ្តាលឲ្យមានឥទ្ធិពលទៅលើអាកាសធាតុសកល។ ឧស្ម័នកាបូនិក ($CO_2$) គឺជាឧស្ម័នផ្ទះកញ្ចក់មួយ ក្នុងចំណោមឧស្ម័នផ្ទះកញ្ចក់សំខាន់ៗជាច្រើន។ ដោយសារតែដើមឈើ និងរុក្ខជាតិដទៃទៀតកើតឡើងដោយសារតែកាបូនយ៉ាងច្រើន នៅពេលព្រៃឈើត្រូវបានបំផ្លាញ កាបូនត្រូវបានបញ្ចេញទៅក្នុងបរិយាកាសក្នុងទម្រង់ជាឧស្ម័ន $CO_2$។ ម្យ៉ាងវិញទៀត ព្រៃឈើដែលមានសុខភាពល្អ និងកំពុងលូតលាស់ស្រូបយក $CO_2$ ពីបរិយាកាស ដែលនេះនាំឲ្យមានការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ការអភិរក្ស និងគ្រប់គ្រងព្រៃឈើ ប្រកបដោយនិរន្តរភាព ទាំងការជៀសវាងបញ្ចេញឧស្ម័ន $CO_2$ ទៅក្នុងបរិយាកាស និងជួយស្រូបយក $CO_2$ ចេញពីបរិយាកាស។

## ២. តើព្រៃឈើផ្តល់ផលប្រយោជន៍ដល់សង្គមយ៉ាងដូចម្តេច?

ព្រៃឈើផ្តល់ផលិតផល និងសេវាកម្មអេកូឡូស៊ីជាច្រើន បន្ថែមទៅលើតួនាទីរបស់វាមួយទៀតក្នុងការស្តុកទុកកាបូន។ តាមធម្មតាសេវាកម្មនេះ មានភាពផ្សេងៗគ្នាពីកន្លែងមួយទៅកន្លែងមួយទៀត ហើយអាចរួមបញ្ចូលទាំង ឈើសម្រាប់សំណង់ ការកំណត់នូវរបបទឹក ការការពារដី អនុផលព្រៃឈើរួមទាំងអាហារ និងហ្វាយបឺ (Fiber) ការកំណត់របបអាកាសធាតុ និងការអភិរក្សជីវចម្រុះ។ សេវាកម្មអេកូឡូស៊ី និងផលប្រយោជន៍សេដ្ឋកិច្ចសង្គម ទាំងនេះអាចត្រូវបានថែរក្សាតាមរយៈការអភិរក្ស និងការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព។

## ៣. តើ UNFCCC គឺជាអ្វី?

**UNFCCC** មានពាក្យពេញថា **United Nations Framework Convention on Climate Change** ជាអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ វាគឺជាអនុសញ្ញាអន្តរជាតិមួយដែលបានឯកភាពដំបូងនៅឆ្នាំ១៩៩២ ដែលមានប្រទេសកម្ពុជា និងបណ្តាប្រទេសជាច្រើនទៀតស្ទើតែទាំងអស់ក្នុងពិភពលោកជាសមាជិក។ តាមរយៈវេទិការបស់ **UNFCCC** ប្រទេសនានាគឺចរចារលើកិច្ចព្រមព្រៀងនានា ដើម្បីឲ្យមានសហគមន៍ជាសកលមួយ ដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុ ព្រមទាំងបន្សាំទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

## ៤. តើរេដបូកគឺជាអ្វី?

រេដបូក គឺជាយន្តការមួយដែលរៀបចំឡើងដោយ **UNFCCC** ដើម្បីផ្តល់រង្វាន់ដល់បណ្តាប្រទេសកំពុងអភិវឌ្ឍ ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើ។ វានឹងបង្កើតឲ្យមានការលើកទឹកចិត្តមួយសម្រាប់ប្រទេសកំពុងអភិវឌ្ឍ ដើម្បីការពារគ្រប់គ្រងឲ្យបានល្អប្រសើរ

និងការប្រើប្រាស់ធនធានព្រៃឈើរបស់ពួកគេប្រកបដោយនិរន្តរភាព និងតាមរយៈការធ្វើដូចនេះ នឹងចូលរួមចំណែកដល់ការអភិរក្សជីវចម្រុះ និងកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

## ៥. តើអ្វីជាការជម្រុញឲ្យមានការកាប់បំផ្លាញព្រៃឈើ និងការរិចរិលព្រៃឈើ?

កត្តាជម្រុញ គឺជាដំណើរការ និងជាតួអង្គបណ្តាលឲ្យមានការកាប់បំផ្លាញព្រៃឈើ និងការរេចរឹលព្រៃឈើ។ ដំណើរការទាំងនោះ អាចចាត់ចូលទៅក្នុងមូលហេតុផ្ទាល់ ដូចជា ការពង្រីកវិស័យកសិកម្ម និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ អគ្គីភ័យ និងការដកហូតឈើ ព្រមទាំងមូលហេតុប្រយោល ដូចជា ភាពក្រីក្រ ការអប់រំទាប តម្លៃទំនិញ និងការឧបត្ថម្ភធន ការរៀបចំផែនការប្រើប្រាស់ដីធ្លីមិនសមស្រប ឬ គ្មានប្រសិទ្ធភាព និងគោលនយោបាយ។ ដោយអនុវត្តតាមគោលនយោបាយ និងវិធានការ ដើម្បីដោះស្រាយកត្តាជម្រុញទាំងផ្ទាល់ និងប្រយោល ដោយមានការផ្តល់ការលើកទឹកចិត្តដើម្បីផ្លាស់ប្តូរឥរិយាបថនៅថ្នាក់មូលដ្ឋាននោះ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីព្រៃឈើនេះ អាចត្រូវបានកាត់បន្ថយ។

## ៦.តើអ្វីទៅជាការត្រៀមខ្លួនជាស្រេចសម្រាប់រេដបូក?

ការត្រៀមខ្លួនជាស្រេចសម្រាប់រេដបូក គឺទាក់ទងនឹងកិច្ចខិតខំប្រឹងប្រែងនានា ដែលប្រទេសមួយរៀបចំឲ្យមានការកសាងសមត្ថភាព និងប្រព័ន្ធប្រត្តិបត្ត ដែលចាំបាច់ដើម្បីអនុវត្តរេដបូកក្នុងបរិបទរបស់ **UNFCCC** ។ ការគាំទ្រឲ្យមានការត្រៀមខ្លួនសម្រាប់រេដបូក ត្រូវបានផ្តល់ឲ្យប្រទេសនានា តាមរយគំនិតផ្តួចផ្តើមទ្វេភាគី និងពហុភាគី ដោយរួមមាន កម្មវិធីរេដរបស់អង្គការសហប្រជាជាតិ (UN-REDD) ។ នេះរួមបញ្ចូលទាំងការគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេសជួយដល់ប្រទេសនានា ដើម្បីរៀបចំសមាសធាតុបួន ដែលបានកំណត់តាមរយៈការចរចារក្នុង **UNFCCC** ៖ យុទ្ធសាស្រ្តរេដបូកជាតិ កម្រិតការបញ្ចេញឧស្ម័នយោងថ្នាក់ជាតិ (ឬកម្រិតយោង) ប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិ និងប្រព័ន្ធផ្តល់ព័ត៌មាន អំពី គោលការណ៍ការពារសុវត្ថិភាព (សូមមើលសំណួរទី១៣)។

## ៧. តើវិធីសាស្រ្តជាដំណាក់កាលចំពោះរេដបូកគឺជាអ្វី?

**UNFCCC** បានសម្រេចនៅឆ្នាំ២០១០ថា រេដបូក គួរត្រូវបានណែនាំជាជំហានៗ។ នៅក្នុងជំហានទីមួយ គឺយុទ្ធសាស្រ្តជាតិ (ឬផែនការសកម្មភាព) គួរត្រូវបានរៀបចំដោយកំណត់ពីសកម្មភាព ដែលបានស្នើឡើង និងការកសាងសមត្ថភាពគួរត្រូវបានធ្វើឡើង។ ជំហានទី២ រួមមាន ការអនុវត្តគោលនយោបាយជាតិ និងវិធានការណ៍ផ្សេងៗនៅក្រោមយុទ្ធសាស្រ្តជាតិ ឬ ផែនការសកម្មភាព ដោយរួមផ្សំជាមួយការកសាងសមត្ថភាព សកម្មភាពបង្ហាញ ដែលចូលរួមកាត់បន្ថយការបញ្ចេញឧស្ម័ន។ នៅជំហានទីបី សកម្មភាពនានាដែលនាំឲ្យមានការកាត់បន្ថយការបញ្ចេញឧស្ម័ន គួរត្រូវបានវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់។

## ៨. តើរេដបូកនឹងត្រូវបានអនុវត្តដោយរបៀបណា?

ការសម្រេចចិត្តរបស់ **UNFCCC** មានន័យថា រដ្ឋាភិបាលថ្នាក់ជាតិ នឹងទទួលខុសត្រូវចំពោះការរៀបចំ និងអនុវត្តកម្មវិធីរេដបូក។ វាមានសារសំខាន់ដោយសារតែវិធីសាស្រ្តជាតិតែប៉ុណ្ណោះ ដែលមានសក្តានុពលដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅកម្រិតមួយ ដែលនឹងមានសារសំខាន់ជាសកល។ រេដបូក

អាចត្រូវបានអនុវត្តប្រកបដោយភាពជោគជ័យបាន ដោយមានការចូលរួមពីភាគីទាំងឡាយ ដែលមានសកម្មភាពទាំងនោះមានផលប៉ះពាល់ដល់ព្រៃឈើ។ ប្រទេសនានាត្រូវបានទាមទារឲ្យរៀបចំយុទ្ធសាស្ត្ររេដបូកថ្នាក់ជាតិ ដោយរៀបរាប់អំពីការបញ្ចេញឧស្ម័ននឹងត្រូវបានកាត់បន្ថយដោយរបៀបណា។ យុទ្ធសាស្ត្រទាំងនេះ ក៏គួរតែកំណត់ថានរណានឹងត្រូវទទួលខុសត្រូវ ចំពោះការអនុវត្តគោលនយោបាយ និងវិធានការនានា ដែលតម្រូវឲ្យមានការកាត់បន្ថយការបំភាយឧស្ម័នបាន។

## ៩. តើរេដបូកនឹងត្រូវបានផ្តល់ហិរញ្ញប្បទានដោយរបៀបណា?

មានប្រភពផ្សេងៗគ្នានៃការផ្តល់ហិរញ្ញប្បទាន មានទាំងការត្រៀមខ្លួនជាស្រេចសម្រាប់រេដបូក និងសម្រាប់ការអនុវត្តពេញលេញនៃរេដបូក។ ចំពោះការត្រៀមខ្លួនសម្រាប់រេដបូក ការផ្តល់មូលនិធិភាគច្រើនត្រូវបានផ្តល់ឲ្យតាមរយៈកម្មវិធីអភិវឌ្ឍន៍ ឬ កម្មវិធីជំនួយ ដោយ ឬ ពី ប្រទេសអភិវឌ្ឍព្រមទាំងតាមរយៈទីភ្នាក់ងារពហុភាគី ដូចជា ប្រព័ន្ធអង្គការសហប្រជាជាតិ និងធនាគារពិភពលោក។ ការផ្តល់ហិរញ្ញប្បទានសម្រាប់អនុវត្តគម្រោងរេដបូកពេញលេញ ត្រូវបានរំពឹងថាបានជាភាគច្រើនមកពីប្រទេសអភិវឌ្ឍដែលចង់ប្រើប្រាស់ការកាត់បន្ថយការបញ្ចេញឧស្ម័នពីរេដបូក ដើម្បីសម្រេចបានតាមគោលដៅដែលបានកំណត់ដោយ **UNFCCC** ។ មូលនិធិអាកាសធាតុបៃតង **(Green Climate Fund)** ដែលបានបង្កើតឡើងដោយ **UNFCCC** ត្រូវបានគេរំពឹងផងដែរថា នឹងមានសារៈសំខាន់នៅក្នុងការផ្តល់ហិរញ្ញប្បទាន ចំពោះការអនុវត្តរេដបូក។ វិធីសាស្ត្រទីផ្សារ និងហិរញ្ញវត្ថុវិស័យឯកជន ក៏អាចដើរតួយ៉ាងសំខាន់មួយផងដែរ។ កម្មវិធីទ្វេភាគីជាច្រើន និងធនាគារពិភពលោក ផ្តល់នូវឱកាសសម្រាប់ការផ្តល់ហិរញ្ញប្បទាន ដល់ការកាត់បន្ថយការបំភាយឧស្ម័នសម្រាប់ប្រទេសដែលផ្លាស់ប្តូរទៅការអនុវត្តរេដបូកយ៉ាងឆាប់រហ័ស។

## ១០. តើប្រទេសនានានឹងបង្ហាញថា ពួកគេបានកាត់បន្ថយការបញ្ចេញឧស្ម័ន ដោយរបៀបណា? តើការវាស់វែង ការរាយការណ៍ និងផ្ទៀងផ្ទាត់ គឺជាអ្វី?

ការវាស់វែង ការរាយការណ៍ និងការផ្ទៀងផ្ទាត់ (MRV) សម្រាប់រេដបូកសំដៅទៅលើការប៉ាន់ស្មានកម្រិតថ្នាក់ជាតិ និងការរាយការណ៍អន្តរជាតិ ពីការបញ្ចេញឧស្ម័នពីព្រៃឈើ និងការស្រូបឧស្ម័នដោយប្រើវិធីសាស្ត្រដែលព្រមព្រៀងគ្នាជាអន្តរជាតិ។ ការវាស់វែងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ គឺផ្អែកទៅលើសមាសធាតុបីសំខាន់ៗ ៖ ១. ប្រព័ន្ធត្រួតពិនិត្យដីដោយផ្កាយរណប (SLMS), ២. សារពើភ័ណ្ឌព្រៃឈើជាតិ (NFI) ឬទិន្នន័យសារពើភ័ណ្ឌពីទីកន្លែងដ៏ទូលំទូលាយ និង ៣. សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ជាតិ (GHG) ។ SLMS និង NFI ត្រូវបានប្រើប្រាស់ដើម្បីផ្តល់លទ្ធផលទៅដល់វិស័យព្រៃឈើ នូវសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ ដើម្បីប៉ាន់ស្មានការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការស្រូបយកឧស្ម័ន (ការស្រូបយក) ពីវិស័យព្រៃឈើ។ ប្រទេសនានា ត្រូវបានលើកទឹកចិត្តដើម្បីរៀបចំ និងដាក់ឲ្យដំណើរការប្រព័ន្ធទាំងនេះក្នុងលក្ខណៈជាជំហានៗដ៏វៃឆ្លាត និងចែករំលែកលទ្ធផលរបស់ពួកគេដោយតម្លាភាព។

## ១១. តើអ្វីទៅជា កម្រិតយោងនៃការបញ្ចេញឧស្ម័ន ក្នុងវិស័យព្រៃឈើ? តើអ្វីទៅជាកម្រិតយោង?

កម្រិតយោងនៃការបញ្ចេញឧស្ម័នក្នុងវិស័យព្រៃឈើ (REL) និង/ឬ កម្រិតយោង (RLs) គឺជាស្តង់ដាគោលសម្រាប់វាយតម្លៃការអនុវត្តមុខងាររបស់ប្រទេសមួយ ក្នុងការអនុវត្តសកម្មភាពនានារបស់រេដបូក។ RELs

អនុវត្តចំពោះសកម្មភាព ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ ខណៈពេលដែល RLs អនុវត្តចំពោះការអភិរក្ស និងការគ្រប់គ្រងព្រៃឈើ ប្រកបដោយនិរន្តភាព។ ទាំង RELs និង RLs ត្រូវបានបង្កើតឡើង ដោយផ្អែកលើប្រវត្តិការបញ្ចេញឧស្ម័នទៅតាមរយៈពេលវេលាតាមកម្រិតយោងមួយដែលបានផ្តល់ឱ្យ។ និន្នាការការបញ្ចេញឧស្ម័នជាប្រវត្តិសាស្ត្រ ត្រូវបានប៉ាន់ស្មានដើម្បីបង្កើតឲ្យមានស្តង់ដាគោលមួយ ទប់ទល់ទៅនឹងការវិវត្តក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័ន ពីការបាត់បង់ និងរេចរឹលព្រៃឈើត្រូវបានវាស់វែង។ ប្រទេសនានា អាចទទួលយកវិធីសាស្ត្រជាជំហានៗ ដោយចាប់ផ្តើមជាមួយនឹង RELs ដ៏សាមញ្ញ និងធ្វើឲ្យប្រសើរឡើងនូវគុណភាព ទៅតាមពេលវេលានៅពេលដែលវិធីសាស្ត្រថ្មី និងទិន្នន័យត្រូវបានដាក់បញ្ចូលគ្នា។

## ១២. តើនរណានឹងទទួលបានផលប្រយោជន៍ពីរេដបូក?

រេដបូក ត្រូវបានផ្អែកលើការផ្តល់ការលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធក្នុងការផ្លាស់ប្តូរឥរិយាបទរបស់ពួកគេ ដើម្បីកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ និងការរេចរឹលព្រៃឈើ និងលើកកម្ពស់ការអភិរក្ស និងការគ្រប់គ្រងព្រៃឈើ ប្រកបដោយនិរន្តភាព។ ដូច្នេះ រេដបូក អាចធ្វើការបានប្រសិនបើការលើកទឹកចិត្តត្រឹមត្រូវបានផ្តល់ជូនដល់អ្នកពាក់ព័ន្ធ ដោយតម្លាភាព យុត្តិធម៌ និងប្រកបដោយសមធម៌។ ដូច្នេះ នេះវាគឺជាទិដ្ឋភាពដ៏មានសារសំខាន់របស់រេដបូក។ ប្រសិនបើអត្ថប្រយោជន៍បានមកពីការផ្តល់ហិរញ្ញប្បទាន ដែលបានរៀបរាប់ក្នុងសំណួរទី៩ មិនត្រូវបានប្រើក្នុងលក្ខណៈសមធម៌ និងយុត្តិធម៌នោះ អ្នកពាក់ព័ន្ធនឹងមិនចូលរួម ហើយការបញ្ចេញឧស្ម័ននឹងមិនត្រូវបានកាត់បន្ថយ។

## ១៣. តើមានគោលការណ៍ការពារសុវត្ថិភាពអ្វីខ្លះធានាថា រេដបូក គឺត្រូវបានអនុវត្តត្រឹមត្រូវ?

UNFCCC បានសម្រេចចិត្តក្នុងឆ្នាំ២០១០ថា ពេលដែលប្រទេសនានាអនុវត្តរេដបូក ពួកគេគួរតែគោរពគោលការណ៍ការពារសុវត្ថិភាពបរិស្ថាន និងសង្គមសំខាន់ៗមួយចំនួន។ គោលការណ៍ការពារសុវត្ថិភាពទាំងនេះរួមបញ្ចូលទាំង ការគោរពចំពោះចំណេះដឹង និងសិទ្ធិរបស់ជនជាតិដើមភាគតិច និងសមាជិកសហគមន៍មូលដ្ឋាន ការចូលរួមពេញលេញ និងមានប្រសិទ្ធិភាពរបស់អ្នកពាក់ព័ន្ធ រចនាសម្ព័ន្ធអភិបាលកិច្ចព្រៃឈើជាតិមានតម្លាភាព និងមានប្រសិទ្ធិភាព និងធានាការអភិរក្សព្រៃធម្មជាតិ និងជីវចម្រុះ ហើយជាពិសេស ជៀសវាងការបម្លែងពីព្រៃធម្មជាតិទៅជាចំការ ឬ សម្រាប់ការប្រើប្រាស់ដីផ្សេងទៀត។

## ១៤. ដូច្នេះតើប្រទេសកម្ពុជាកំពុងអនុវត្តអ្វីខ្លះក្នុងរេដបូក?

ប្រទេសកម្ពុជា បានកំពុងអនុវត្តសកម្មភាពការត្រៀមខ្លួនជាស្រេចសម្រាប់រេដបូកជាច្រើនឆ្នាំមកហើយ ហើយកំពុងរៀបចំយុទ្ធសាស្ត្ររេដបូកជាតិរបស់ខ្លួន។ ក្នុងពេលឆាប់ខាងមុខ កម្ពុជានឹងត្រូវបានត្រៀមខ្លួនរួចជាស្រេច ដើម្បីបន្តទៅក្នុងដំណាក់កាលទីពីររបស់រេដបូក និងចាប់ផ្តើមអនុវត្តសកម្មភាពដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័ន។

# Misperception About REDD+

| | |
|---|---|
| **1. If Cambodia implements REDD+, people living in or near the forest will no longer be able to harvest vegetables or other products from the forest.**<br>១. ប្រសិនបើប្រទេសកម្ពុជាអនុវត្តន៍រេដបូក ប្រជាពលរដ្ឋដែលរស់នៅក្នុង ឬ នៅជិតព្រៃឈើ នឹងមិនអាចធ្វើទាញផលបន្លែបង្កា ឬ ធនធានផ្សេងៗ ពីព្រៃឈើបានទៀតទេ។ | TT BDS |
| **2. In a Cambodia REDD+ programme, no trees can be cut.**<br>២. នៅក្នុងការអនុវត្តកម្មវិធីរេដបូកកម្ពុជា ដើមឈើមិនត្រូវបានអនុញ្ញាតឲ្យកាប់នោះទេ។ | TT Demonstration |
| **3. There is no role for communities in REDD+.**<br>៣. សហគមន៍មិនមានតួនាទីអ្វីនោះទេ នៅក្នុងការអនុវត្តរេដបូក។ | TT Safeguards |
| **4. All benefits from REDD+ will go to the government.**<br>៤. រាល់ផលប្រយោជន៍ពីការអនុវត្តរេដបូក នឹងបានទៅតែរដ្ឋាភិបាលតែប៉ុណ្ណោះ។ | TT BDS |
| **5. It is impossible to stop illegal logging or land grabbing by powerful people.**<br>៥. វាមិនអាចទៅរួចនោះទេក្នុងការបញ្ឈប់ការកាប់ព្រៃឈើ ឬ ការយកដីខុសច្បាប់ ដោយអ្នកមានអំណាច។ | TT Demonstration |
| **6. If local people’s rights are not respected, there is nothing they can do about it.**<br>៦. ប្រសិនបើសិទ្ធិមនុស្សមិនត្រូវបានគោរព ពួកគេនឹងមិនអាចធ្វើអ្វីបាននោះទេទៅលើបញ្ហាទាំងនេះ។ | TT Safeguards |
| **7. Implementing REDD+ will have a negative impact on biodiversity (wildlife)**<br>៧. ការអនុវត្តរេដបូក នឹងមានផលប៉ះពាល់អវិជ្ជមានទៅលើជីវចម្រុះ (សត្វព្រៃ)។ | TT Safeguards |
| **8. REDD+ will never happen in Cambodia because the government will not agree to “selling” credits**<br>៨. រេដបូក នឹងមិនអាចអនុវត្តន៍ទៅបាននោះទេនៅប្រទេសកម្ពុជា ពីព្រោះរដ្ឋាភិបាលនឹងមិនយល់ព្រមក្នុងការ "លក់" ឥណទាន។ | TT BDS |

## TV and Radio Programme

**Annex 1: Outline of topics for broadcasts**

| No | Topic | TT assigned |
|---|---|---|
| 1 | What is REDD+<br>តើរេដបូកជាអ្វី | N/A |
| 2 | Deforestation and Forest Degradation<br>ការបាត់បង់ និងរេចរឹលព្រៃឈើ | N/A |
| 3 | REDD+ activities<br>សកម្មភាពរេដបូក | TT Demonstration |
| 4 | Costs and benefits of REDD+<br>ការចំណាយ និងផលចំណេញ ពីរេដបូក | TT BDS |
| 5 | Results-based REDD+<br>រេដបូកផ្អែកលើលទ្ធផល | TT MRV |
| 6 | Benefit sharing<br>ការបែងចែកផលប្រយោជន៍ | TT BDS |
| 7 | Safeguards<br>ប្រព័ន្ធការពារសុវត្ថិភាព | TT Safeguards |
| 8 | Non-carbon benefits<br>ផលប្រយោជន៍មិនមែនជាកាបូន (ក្រៅពីកាបូន) | TT BDS |
| 9 | Challenges with REDD+<br>បញ្ហាប្រឈមក្នុងការអនុវត្តរេដបូក | TT Demonstration |
| 10 | Stakeholders Engagement<br>កាចូលរួមរបស់ភាគីអ្នកពាក់ព័ន្ធ | TT Safeguards |

# Frequently Asked Questions (FAQs) on REDD+

| | |
|---|---|
| 1. How are forests related to climate change?<br>១. តើព្រៃឈើមានទំនាក់ទំនងទៅនឹងការប្រែប្រួលអាកាសធាតុយ៉ាងដូចម្តេច? | **TT MRV** |
| 2. How do forests benefit society?<br>២. តើព្រៃឈើផ្តល់ផលប្រយោជន៍ដល់សង្គមយ៉ាងដូចម្តេច? | **TT BDS** |
| 3. What is the UNFCCC?<br>៣. តើ UNFCCC គឺជាអ្វី? | **N/A** |
| 4. What is REDD+?<br>៤. តើរេដបូកគឺជាអ្វី? | **TT Safeguards** |
| 5. What are drivers of deforestation and forest degradation?<br>៥. តើអ្វីជាការជម្រុញឲ្យមានការកាប់បំផ្លាញព្រៃឈើ និងការរិចរិលព្រៃឈើ? | **TT Demonstration** |
| 6. What is REDD+ readiness?<br>៦.តើអ្វីទៅជាការត្រៀមខ្លួនជាស្រេចសម្រាប់រេដបូក? | **TT Safeguards** |
| 7. What is the phased approach to REDD+?<br>៧. តើវិធីសាស្ត្រជាដំណាក់កាលចំពោះរេដបូកគឺជាអ្វី? | **TT Demonstration** |
| 8. How will REDD+ be implemented?<br>៨. តើរេដបូកនឹងត្រូវបានអនុវត្តដោយរបៀបណា? | **TT Demonstration** |
| 9. How will REDD+ be financed?<br>៩. តើរេដបូកនឹងត្រូវបានផ្តល់ហិរញ្ញប្បទានដោយរបៀបណា? | **TT BDS** |
| 10. How will countries demonstrate that they have reduced emissions?  What is MRV?<br>១០. តើប្រទេសនានានឹងបង្ហាញថា ពួកគេបានកាត់បន្ថយការបញ្ចេញឧស្ម័ន ដោយរបៀបណា? តើការវាស់វែង ការរាយការណ៍ និងផ្ទៀងផ្ទាត់ គឺជាអ្វី? | **TT MRV** |
| 11. What are forest reference emission levels?  What are forest RELs and RLs?<br>១១. តើអ្វីទៅជា កម្រិតយោងនៃការបញ្ចេញឧស្ម័ន ក្នុងវិស័យព្រៃឈើ? តើអ្វីទៅជាកម្រិតយោង? | **TT MRV** |
| 12. Who will benefit from REDD+?<br>១២. តើនរណានឹងទទួលបានផលប្រយោជន៍ពីរេដបូក? | **TT BDS** |
| 13. What safeguards ensure that REDD+ is implemented properly?<br>១៣.  តើមានគោលការណ៍ការពារសុវត្ថិភាពអ្វីខ្លះធានាថា រេដបូក គឺត្រូវបានអនុវត្តត្រឹមត្រូវ? | **TT Safeguards** |
| 14. So what is Cambodia doing on REDD+?<br>១៤. ដូច្នេះតើប្រទេសកម្ពុជាកំពុងអនុវត្តអ្វីខ្លះក្នុងរេដបូក? | **N/A** |